( ៣០៥ ) ចិត្ត ដែលប្រកបដោយវេទនា ។ បេ ។ ប្រកបដោយសញ្ញា ។ បេ ។ ប្រកបដោយចេតនា ។ បេ ។ ប្រកបដោយបញ្ញា រួចស្រឡះ ចុះបញ្ញានិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អើ ។ ចិត្ត ដែលប្រកបដោយមោហៈ រួចស្រឡះ ចុះមោហៈនិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣០៦ ) ចិត្ត ដែលប្រកបដោយផស្សៈ ប្រកបដោយមោហៈ រួចស្រឡះ ចុះផស្សៈនិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អើ ។ មោហៈនិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣០៧) សវេទនំ សមោហំ ។ បេ ។ សសញ្ញំ សមោហំ ។ បេ ។ សចេតនំ សមោហំ ។ បេ ។ សបញ្ញំ សមោហំ ចិត្តំ វិមុច្ចតិ បញ្ញា ច ចិត្តញ្ច ឯកតោ វិមុច្ចន្តីតិ ។ អាមន្តា ។ មោហោ ច ចិត្តញ្ច ឯកតោ វិមុច្ចន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣០៨) ន វត្តព្វំ[១] សរាគំ សទោសំ សមោហំ ចិត្តំ វិមុច្ចតីតិ ។ អាមន្តា ។ វីតរាគំ វីតទោសំ វីតមោហំ និក្កិលេសំ ចិត្តំ វិមុច្ចតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ[២] សរាគំ សទោសំ សមោហំ ចិត្តំ វិមុច្ចតីតិ ។

វិមុត្តិកថា ។

## វិមុច្ចមានកថា

(៣០៩) វិមុត្តំ វិមុច្ចមានន្តិ ។ អាមន្តា ។ ឯកទេសំ វិមុត្តំ ឯកទេសំ អវិមុត្តន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

---

១ ម. ន វត្តព្វន្តិ អយមេវ បាឋោ ន វិជ្ជតិ ។ ២ ម. ឯត្ថន្តរេ ន វត្តព្វន្តិ ទិស្សតិ ។

( ៣០៧ ) ចិត្ត ដែលប្រកបដោយវេទនា ប្រកបដោយមោហៈ ។ បេ ។ ប្រកបដោយសញ្ញា ប្រកបដោយមោហៈ ។ បេ ។ ប្រកបដោយចេតនា ប្រកបដោយមោហៈ ។ បេ ។ ប្រកបដោយបញ្ញា ប្រកបដោយមោហៈ រួចស្រឡះ ចុះបញ្ញានិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អើ ។ មោហៈនិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣០៨ ) បុគ្គលមិនគួរនិយាយថា ចិត្ត ដែលប្រកបដោយរាគៈ ប្រកបដោយទោសៈ ប្រកបដោយមោហៈ រួចស្រឡះទេឬ ។ អើ ។ ចិត្ត ដែលប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មិនមានកិលេស រួចស្រឡះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ ចិត្ត ដែលប្រកបដោយរាគៈ ប្រកបដោយទោសៈ ប្រកបដោយមោហៈ រមែងរួចស្រឡះ ( ចាកអាសវៈ ) ។

ចប់ វិមុត្តិកថា ។

## វិមុច្ចមានកថា

( ៣០៩ ) ចិត្តរួចស្រឡះហើយ ចិត្តកំពុងរួចស្រឡះ មែនឬ ។ អើ ។ ចិត្តរួចស្រឡះហើយ មួយផ្នែក ចិត្តមិនទាន់រួចស្រឡះហើយ មួយផ្នែក មែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣១០) ឯកទេសំ វិមុត្តំ ឯកទេសំ អវិមុត្តន្តិ ។ អាមន្តា ។ ឯកទេសំ សោតាបន្នោ ឯកទេសំ ន សោតាបន្នោ ឯកទេសំ សោតាបត្តិផលប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ឯកទេសំ ន កាយេន ផុសិត្វា វិហរតិ ឯកទេសំ សត្តក្ខត្តុំ(១)បរមោ កោលំកោលោ ឯកពីជី ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ធម្មេ ។ បេ ។ សង្ឃេ ។ បេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ឯកទេសំ អរិយកន្តេហិ សីលេហិ ន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣១១) ឯកទេសំ វិមុត្តំ ឯកទេសំ អវិមុត្តន្តិ ។ អាមន្តា ។ ឯកទេសំ សកទាគាមី ឯកទេសំ ន សកទាគាមី ឯកទេសំ សកទាគាមិផលប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ឯកទេសំ ន កាយេន ផុសិត្វា វិហរតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

---

១ ម. សត្តក្ខត្តុបរមោ ។

( ៣១០ ) ចិត្តរួចស្រឡះហើយ មួយផ្នែក ចិត្តមិនទាន់រួចស្រឡះហើយ មួយផ្នែក មែនឬ ។ អើ ។ បុគ្គល ជាសោតាបន្នៈ មួយផ្នែក មិនមែនជាសោតាបន្នៈ មួយផ្នែក បុគ្គលដល់នូវសោតាបត្តិផល ដែលបានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ មួយផ្នែក មិនពាល់ត្រូវដោយនាមកាយ មួយផ្នែក សត្តក្ខត្តុំបរមបុគ្គល កោលំកោលបុគ្គល ឯកពីជិបុគ្គល ប្រកបដោយសេចក្ដីជ្រះថ្លាមិនកម្រើក ក្នុងព្រះពុទ្ធ ក្នុងព្រះធម៌ ។ បេ ។ ក្នុងព្រះសង្ឃ ។ បេ ។ ប្រកបដោយសីលជាទីត្រេកអរនៃព្រះអរិយៈទាំងឡាយ មួយផ្នែក មិនប្រកបដោយសីលជាទីត្រេកអរនៃព្រះអរិយៈទាំងឡាយ មួយផ្នែក មែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣១១ ) ចិត្តរួចស្រឡះហើយ មួយផ្នែក ចិត្តមិនទាន់រួចស្រឡះហើយ មួយផ្នែក មែនឬ ។ អើ ។ បុគ្គល ជាសកទាគាមី មួយផ្នែក មិនមែនជាសកទាគាមី មួយផ្នែក បុគ្គល ដល់នូវសកទាគាមិផល ដែលបានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ មួយផ្នែក មិនពាល់ត្រូវដោយនាមកាយ មួយផ្នែក មែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣១២) ឯកទេសំ វិមុត្តំ ឯកទេសំ អវិមុត្តន្តិ ។ អាមន្តា ។ ឯកទេសំ អនាគាមី ឯកទេសំ ន អនាគាមី ឯកទេសំ អនាគាមិផលប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ឯកទេសំ ន កាយេន ផុសិត្វា វិហរតិ ឯកទេសំ អន្តរាបរិនិព្វាយី ឧបហច្ចបរិនិព្វាយី អសង្ខារបរិនិព្វាយី សសង្ខារបរិនិព្វាយី ឧទ្ធំសោតោ អកនិដ្ឋគាមី ឯកទេសំ ន ឧទ្ធំសោតោ ន[១] អកនិដ្ឋគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣១៣) ឯកទេសំ វិមុត្តំ ឯកទេសំ អវិមុត្តន្តិ ។ អាមន្តា ។ ឯកទេសំ អរហា ឯកទេសំ ន អរហា ឯកទេសំ អរហត្តប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ឯកទេសំ ន កាយេន ផុសិត្វា វិហរតិ ឯកទេសំ វីតរាគោ វីតទោសោ វីតមោហោ ។ បេ ។ ឯកទេសំ សច្ឆិកាតព្វំ សច្ឆិកតំ ឯកទេសំ សច្ឆិកាតព្វំ ន សច្ឆិកតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

---

១ ម. នសោត្ថេ នត្ថិ ។

វិមុច្ចមានកថា

( ៣១២ ) ចិត្តរួចស្រឡះហើយ មួយផ្នែក ចិត្តមិនទាន់រួចស្រឡះហើយ មួយផ្នែក មែនឬ ។ អើ ។ បុគ្គល ជាអនាគាមី មួយផ្នែក មិនមែនជាអនាគាមី មួយផ្នែក បុគ្គលដល់នូវអនាគាមិផល ដែលបានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ មួយផ្នែក មិនពាល់ត្រូវដោយនាមកាយ មួយផ្នែក ជាអន្តបរិនិព្វាយី ជាឧបហច្ចបរិនិព្វាយី ជាអសង្ខារបរិនិព្វាយី ជាសសង្ខារបរិនិព្វាយី ជាឧទ្ធំសោតៈ អកនិដ្ឋគាមី មួយផ្នែក មិនមែនជាឧទ្ធំសោតៈ មិនមែនជាអកនិដ្ឋគាមី មួយផ្នែក មែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣១៣ ) ចិត្តរួចស្រឡះហើយ មួយផ្នែក ចិត្តមិនទាន់រួចស្រឡះហើយ មួយផ្នែក មែនឬ ។ អើ ។ បុគ្គល ជាអរហន្ត មួយផ្នែក មិនមែនជាអរហន្ត មួយផ្នែក បុគ្គលដល់នូវអរហត្ត ដែលបានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ មួយផ្នែក មិនពាល់ត្រូវដោយនាមកាយ មួយផ្នែក បុគ្គល ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មួយផ្នែក ។ បេ ។ សច្ចិកាតព្វកិច្ច លោកបានធ្វើឲ្យជាក់ច្បាស់ហើយ មួយផ្នែក សច្ចិកាតព្វកិច្ច លោកមិនបា ធ្វើឲ្យជាក់ច្បាស់ហើយ មួយផ្នែក មែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេឬ ។ បេ ។

(៣១៤) វិមុត្តំ វិមុច្ចមានន្តិ ។ អាមន្តា ។ ឧប្បាទក្ខណេ វិមុត្តំ វយក្ខណេ វិមុច្ចមានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣១៥) ន វត្តព្វំ វិមុត្តំ វិមុច្ចមានន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា តស្ស ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ វិមុត្តំ វិមុច្ចមានន្តិ ។

(៣១៦) វិមុត្តំ វិមុច្ចមានន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញ្ញាណាយ ចិត្តំ អភិនិន្នាមេតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ វិមុត្តំ វិមុច្ចមានន្តិ ។

( ៣១៤ ) ចិត្តរួចស្រឡះហើយ ចិត្តកំពុងរួចស្រឡះ មែនឬ ។ អើ ។ ចិត្តដែលរួចស្រឡះហើយ ក្នុងខណៈដែលកើតឡើង ចិត្តកំពុងរួចស្រឡះ ក្នុងខណៈសាបសូន្យ មែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣១៥ ) បុគ្គលមិនគួរពោលថា ចិត្តរួចស្រឡះហើយ ចិត្តកំពុងរួចស្រឡះ មែនឬ ។ អើ ។ ក្រែង ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា កាលបុគ្គលនោះ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តរមែងរួចស្រឡះ ចាកកាមាសវៈផង ចិត្តរួចស្រឡះ ចាកភវាសវៈផង ចិត្តរួចស្រឡះ ចាកអវិជ្ជាសវៈផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ចិត្ត ឈ្មោះថារួចស្រឡះហើយ ឈ្មោះថាកំពុងរួចស្រឡះ ។

( ៣១៦ ) ចិត្តរួចស្រឡះហើយ ចិត្តកំពុងរួចស្រឡះ (ឈ្មោះថារួច) មែនឬ ។ អើ ។ ក្រែង ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា កាលដែលចិត្ត ខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកសេចក្ដីសៅហ្មង ជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រ យ៉ាងនេះហើយ បុគ្គលនោះ រមែងបង្អោនចិត្ត ដើម្បីញាណជាហេតុឲ្យអស់ទៅ នៃអាសវៈទាំងឡាយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គល មិនគួរពោលថា ចិត្តរួចស្រឡះហើយ ចិត្តកំពុងរួចស្រឡះទេ ។

[៣១៧] អត្ថិ ចិត្តំ វិមុច្ចមានន្តិ ។ អាមន្តា ។ អត្ថិ ចិត្តំ រជ្ជមានំ ទុស្សមានំ មុយ្ហមានំ កិលិស្សមានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ រត្តញ្ច អរត្តញ្ច ទុដ្ឋញ្ច អទុដ្ឋញ្ច មូឡ្ហញ្ច អមូឡ្ហញ្ច ឆិន្នញ្ច អច្ឆិន្នញ្ច ភិន្នញ្ច អភិន្នញ្ច កតញ្ច អកតញ្ចាតិ ។ អាមន្តា ។ ហញ្ចិ រត្តញ្ច អរត្តញ្ច ទុដ្ឋញ្ច អទុដ្ឋញ្ច មូឡ្ហញ្ច អមូឡ្ហញ្ច ឆិន្នញ្ច អច្ឆិន្នញ្ច ភិន្នញ្ច អភិន្នញ្ច កតញ្ច អកតញ្ច តេន វត រេ វត្តព្វេ អត្ថិ ចិត្តំ វិមុច្ចមានន្តិ ។

វិមុច្ចមានកថា ។

# អដ្ឋមកកថា

[៣១៨] អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ បហីនន្តិ ។ អាមន្តា ។ អដ្ឋមកោ បុគ្គលោ សោតាបន្នោ សោតាបត្តិផលប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

### វិមុច្ចមានកថា

( ៣១៧ ) ចិត្តកំពុងរួចស្រឡះ មានឬ ។ អើ ។ ចិត្តកំពុងត្រេកអរ កំពុងខឹង កំពុងវង្វេង កំពុងសៅហ្មង មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងចិត្ត ដែលត្រេកអរផង មិនត្រេកអរផង ខឹងផង មិនខឹងផង វង្វេងផង មិនវង្វេងផង ដាច់ផង មិនដាច់ផង បែកផង មិនបែកផង ធ្វើផង មិនធ្វើផង មានឬ ។ អើ ។ ប្រសិនបើចិត្ត ត្រេកអរផង មិនត្រេកអរផង ខឹងផង មិនខឹងផង វង្វេងផង មិនវង្វេងផង ដាច់ផង មិនដាច់ផង បែកផង មិនបែកផង ធ្វើផង មិនធ្វើផង មានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្តកំពុងរួចស្រឡះ មានទេ ។

ចប់ វិមុច្ចមានកថា ។

## អដ្ឋមកកថា

( ៣១៨ ) ទិដ្ឋិបរិយុដ្ឋានៈ ( ការស្ទាក់ដំណើរគឺទិដ្ឋិ ) គឺបុគ្គលទី ៨[១] លះបង់ហើយឬ ។ អើ ។ បុគ្គលទី ៨ ជាសោតាបន្នៈ ដល់សោតាបត្តិផល បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេចពាល់ត្រូវដោយនាមកាយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

---

១ អរិយបុគ្គល ៨ ពួក បុគ្គលដែលឋិតនៅក្នុងសោតាបត្តិមគ្គ រាប់ថាជាបុគ្គលទី ៨ ក្នុងទីនេះ ។

(៣១៩) អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆាបរិយុដ្ឋានំ បហីនន្តិ ។ អាមន្តា ។ អដ្ឋមកោ បុគ្គលោ សោតាបន្នោ សោតាបត្តិផលប្បត្តោ ។ បេ ។ កាយេន ផុសិត្វា វិហរតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣២០) អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ បហីនន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋានុសយោ បហីនោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ បហីនន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆានុសយោ ។ បេ ។ សីលព្វតបរាមាសោ បហីនោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣២១) អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆាបរិយុដ្ឋានំ បហីនន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆានុសយោ បហីនោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆាបរិយុដ្ឋានំ បហីនន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋានុសយោ ។ បេ ។ សីលព្វតបរាមាសោ បហីនោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៣១៩ ) វិចិកិច្ឆាបរិយុដ្ឋានៈ បុគ្គលទី ៨ លះបង់ហើយឬ ។ អើ ។ បុគ្គលទី ៨ ជាសោតាបន្នៈ ដល់នូវសោតាបត្តិផល ។ បេ ។ ពាល់ត្រូវដោយនាមកាយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣២០ ) ទិដ្ឋិបរិយុដ្ឋានៈ បុគ្គលទី ៨ លះបង់ហើយឬ ។ អើ ។ ទិដ្ឋានុស័យ បុគ្គលទី ៨ លះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ទិដ្ឋិបរិយុដ្ឋានៈ បុគ្គលទី ៨ លះបង់ហើយឬ ។ អើ ។ វិចិកិច្ឆានុស័យ បុគ្គលទី ៨ លះបង់ហើយ ។ បេ ។ សីលព្វតបរាមាសៈ លោកលះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣២១ ) វិចិកិច្ឆាបរិយុដ្ឋានៈ បុគ្គលទី ៨ លះបង់ហើយឬ ។ អើ ។ វិចិកិច្ឆានុស័យ បុគ្គលទី ៨ លះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិចិកិច្ឆាបរិយុដ្ឋានៈ បុគ្គលទី ៨ លះបង់ហើយឬ ។ អើ ។ ទិដ្ឋានុស័យ បុគ្គលទី ៨ លះបង់ហើយ ។ បេ ។ សីលព្វតបរាមាសៈ លោកលះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

## អដ្ឋមកកថា

(៣២២) អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋានុសយោ អប្បហីនោតិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ អប្បហីនន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋានុសយោ អប្បហីនោតិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆាបរិយុដ្ឋានំ អប្បហីនន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆានុសយោ ។ បេ ។ សីលព្វតបរាមាសោ អប្បហីនោតិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ អប្បហីនន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋមកស្ស បុគ្គលស្ស សីលព្វតបរាមាសោ អប្បហីនោតិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆាបរិយុដ្ឋានំ អប្បហីនន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣២៣) អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ បហីនន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានប្បហានាយ មគ្គោ ភាវិតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ បហីនន្តិ ។

[ ៣២២ ] ទិដ្ឋានុស័យ បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អើ ។ ទិដ្ឋិបរិយុដ្ឋានៈ បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ទិដ្ឋានុស័យ បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អើ ។ វិចិកិច្ឆាបរិយុដ្ឋានៈ បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិចិកិច្ឆានុស័យ បុគ្គលទី ៨ មិនបានលះបង់ទេ ។ បេ ។ សីលព្វតបរាមាសៈ បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អើ ។ ទិដ្ឋិបរិយុដ្ឋានៈ បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សីលព្វតបរាមាសៈ បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អើ ។ វិចិកិច្ឆាបរិយុដ្ឋានៈ បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣២៣ ] ទិដ្ឋិបរិយុដ្ឋានៈ បុគ្គលទី៨ បានលះបង់ហើយឬ ។ អើ ។ បុគ្គលទី៨ បានចម្រើនមគ្គ ដើម្បីលះបង់ទិដ្ឋិបរិយុដ្ឋានៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលទី៨ បានលះបង់ទិដ្ឋិបរិយុដ្ឋានៈឬ ។

អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានប្ប-
ហានាយ សតិប្បដ្ឋានា ភាវិតា ។ បេ ។ សម្មប្បធានា
។ បេ ។ ពោជ្ឈង្គា ភាវិតាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣២៤) អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆាបរិ-
យុដ្ឋានំ បហីនន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គ-
លស្ស វិចិកិច្ឆាបរិយុដ្ឋានប្បហានាយ មគ្គោ ភាវិតោ
។ បេ ។ ពោជ្ឈង្គា ភាវិតាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣២៥) អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋា-
នប្បហានាយ មគ្គោ អភាវិតោតិ ។ អាមន្តា ។ អ-
មគ្គេន បហីនំ លោកិយេន សាសវេន ។ បេ ។ សង្កិ-
លេសិកេនាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋម-
កស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានប្បហានាយ សតិប្ប-
ដ្ឋានា ។ បេ ។ ពោជ្ឈង្គា អភាវិតាតិ ។ អាមន្តា ។
អមគ្គេន បហីនំ លោកិយេន សាសវេន ។ បេ ។
សង្កិលេសិកេនាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣២៦) អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆាបរិ-
យុដ្ឋានប្បហានាយ មគ្គោ អភាវិតោ ។ បេ ។
សតិប្បដ្ឋានា ។ បេ ។ ពោជ្ឈង្គា អភាវិតាតិ ។

អើ ៗ បុគ្គលទី៨ បានចម្រើនសតិប្បដ្ឋាន ៗ បេ ៗ សម្មប្បធាន ៗ បេ ៗ បានចម្រើនពោជ្ឈង្គៈ ដើម្បីលះបង់ទិដ្ឋិបរិយុដ្ឋានៈឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ៗ បេ ៗ

(៣៦៤) វិចិកិច្ឆាបរិយុដ្ឋានៈ បុគ្គលទី ៨ បានលះបង់ហើយឬ ៗ អើ ៗ បុគ្គលទី៨ បានចម្រើនមគ្គ ៗ បេ ៗ បានចម្រើនពោជ្ឈង្គៈ ដើម្បីលះបង់វិចិកិច្ឆាបរិយុដ្ឋានៈឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ៗ បេ ៗ

(៣៦៥) បុគ្គលទី៨ មិនបានចម្រើនមគ្គ ដើម្បីលះបង់ទិដ្ឋិបរិ-យុដ្ឋានៈទេឬ ៗ អើ ៗ បរិយុដ្ឋានកិលេស គឺលោកលះបង់ហើយ ដោយធម៌មិនមែនជាមគ្គ ជាលោកិយៈ ប្រកបដោយអាសវៈ ៗ បេ ៗ ប្រកបដោយសេចក្តីសៅហ្មង មែនឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ៗ បេ ៗ បុគ្គលទី៨ មិនបានចម្រើនសតិប្បដ្ឋាន ៗ បេ ៗ មិនបានចម្រើនពោជ្ឈង្គៈ ដើម្បីលះបង់ទិដ្ឋិបរិយុដ្ឋានៈទេឬ ៗ អើ ៗ (បរិយុដ្ឋានកិលេស) គឺលោកលះបង់ហើយ ដោយធម៌មិនមែនជាមគ្គ ជាលោកិយៈ ប្រកបដោយអាសវៈ ៗ បេ ៗ ប្រកបដោយសេចក្តីសៅហ្មង មែនឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ៗ បេ ៗ

(៣៦៦) បុគ្គលទី៨ មិនបានចម្រើនមគ្គ ៗ បេ ៗ សតិប្បដ្ឋាន ៗ បេ ៗ មិនបានចម្រើនពោជ្ឈង្គៈ ដើម្បីលះបង់វិចិកិច្ឆាបរិយុដ្ឋានៈទេឬ ៗ

អាមន្តា ។ អមគ្គេន បហីនំ លោកិយេន សាសវេន ។ បេ ។ សង្កិលេសិកេនាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៦៧) ន វត្តព្វំ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ បហីនន្តិ ។ អាមន្តា ។ ឧប្បជ្ជិស្សតីតិ ។ នុប្បជ្ជិស្សតីតិ ។ ហញ្ចិ នុប្បជ្ជិស្សតិ តេន វត រេ វត្តព្វេ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ បហីនន្តិ ។

(៣៦៨) ន វត្តព្វំ អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆាបរិយុដ្ឋានំ បហីនន្តិ ។ អាមន្តា ។ ឧប្បជ្ជិស្សតីតិ ។ នុប្បជ្ជិស្សតីតិ ។ ហញ្ចិ នុប្បជ្ជិស្សតិ តេន វត រេ វត្តព្វេ អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆាបរិយុដ្ឋានំ បហីនន្តិ ។

(៣៦៩) អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ នុប្បជ្ជិស្សតីតិ កត្វា បហីនន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋានុសយោ នុប្បជ្ជិស្សតីតិ កត្វា បហីនោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

តើ ៗ (បរិយុដ្ឋានក្កិលេស) គឺលោកលះបង់ហើយ ដោយធម៌មិនមែនជាមគ្គ ជាលោកិយៈ ប្រកបដោយអាសវៈ ៗ បេ ៗ ប្រកបដោយសេចក្តីសៅហ្មង មែនឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ៗ បេ ៗ

(៣២៧) បុគ្គលមិនគួរពោលថា ទិដ្ឋិបរិយុដ្ឋានៈ បុគ្គលទី ៨ បានលះបង់ហើយឬ ៗ អើ ៗ ទិដ្ឋិបរិយុដ្ឋានៈ នឹងកើតឡើងឬ ៗ ទិដ្ឋិ-បរិយុដ្ឋានៈ នឹងមិនកើតឡើងទេ ៗ ប្រសិនបើ ទិដ្ឋិបរិយុដ្ឋានៈ នឹងមិនកើតឡើងទេ មាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ទិដ្ឋិបរិយុដ្ឋានៈ បុគ្គលទី ៨ បានលះបង់ហើយ ៗ

(៣២៨) បុគ្គលមិនគួរពោលថា វិចិកិច្ឆាបរិយុដ្ឋានៈ បុគ្គលទី ៨ បានលះបង់ហើយឬ ៗ អើ ៗ វិចិកិច្ឆាបរិយុដ្ឋានៈ នឹងកើតឡើងឬ ៗ វិចិកិច្ឆាបរិយុដ្ឋានៈ នឹងមិនកើតឡើងទេ ៗ ប្រសិនបើ វិចិកិច្ឆា-បរិយុដ្ឋានៈ នឹងមិនកើតឡើងទេ មាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វិចិកិច្ឆាបរិយុដ្ឋានៈ បុគ្គលទី ៨ បានលះបង់ហើយ ៗ

(៣២៩) បុគ្គលទី ៨ ធ្វើសេចក្តីចូលចិត្តថា ទិដ្ឋិបរិយុដ្ឋានៈ នឹងមិនកើតឡើង ឈ្មោះថាលះបង់ហើយឬ ៗ អើ ៗ បុគ្គលទី ៨ ធ្វើសេចក្តីចូលចិត្តថា ទិដ្ឋានុស័យ នឹងមិនកើតឡើង ឈ្មោះថាលះបង់ហើយឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ៗ បេ ៗ

(៣៣០) អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ នុប្បជ្ជិស្សតីតិ កត្វា បហីនន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆានុសយោ ។បេ។ សីលព្វតបរាមាសោ នុប្បជ្ជិស្សតីតិ កត្វា បហីនោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣៣១) អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆាបរិយុដ្ឋានំ នុប្បជ្ជិស្សតីតិ កត្វា បហីនន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆានុសយោ ។បេ។ សីលព្វតបរាមាសោ នុប្បជ្ជិស្សតីតិ កត្វា បហីនោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣៣២) អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ នុប្បជ្ជិស្សតីតិ កត្វា បហីនន្តិ ។ អាមន្តា ។ គោត្រភុនោ បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ នុប្បជ្ជិស្សតីតិ កត្វា បហីនន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣៣៣) អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆាបរិយុដ្ឋានំ នុប្បជ្ជិស្សតីតិ កត្វា បហីនន្តិ ។ អាមន្តា ។ គោត្រភុនោ បុគ្គលស្ស វិចិកិច្ឆាបរិយុដ្ឋានំ នុប្បជ្ជិស្សតីតិ កត្វា បហីនន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

អដ្ឋមកកថា ។

[ ៣៣០ ] បុគ្គលទី ៨ ធ្វើសេចក្តីបួលចិត្តថា ទិដ្ឋិបរិយុដ្ឋានៈ នឹងមិនកើតឡើង ឈ្មោះថាលះបង់ហើយឬ ។ អើ ។ បុគ្គលទី ៨ ធ្វើសេចក្តីបួលចិត្តថា វិចិកិច្ឆានុស័យ ។ បេ ។ សីលព្វតបរាមាសៈ នឹងមិនកើតឡើង ឈ្មោះថាលះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣៣១ ] បុគ្គលទី ៨ ធ្វើសេចក្តីបួលចិត្តថា វិចិកិច្ឆាបរិយុដ្ឋានៈ នឹងមិនកើតឡើង ឈ្មោះថាលះបង់ហើយឬ ។ អើ ។ បុគ្គលទី ៨ ធ្វើសេចក្តីបួលចិត្តថា វិចិកិច្ឆានុស័យ ។ បេ ។ សីលព្វតបរាមាសៈ នឹងមិនកើតឡើង ឈ្មោះថាលះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣៣២ ] បុគ្គលទី ៨ ធ្វើសេចក្តីបួលចិត្តថា ទិដ្ឋិបរិយុដ្ឋានៈ នឹងមិនកើតឡើង ឈ្មោះថាលះបង់ហើយឬ ។ អើ ។ បុគ្គលជាគោត្រភូ ធ្វើសេចក្តីបួលចិត្តថា ទិដ្ឋិបរិយុដ្ឋានៈ នឹងមិនកើតឡើង ឈ្មោះថាលះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣៣៣ ] បុគ្គលទី ៨ ធ្វើសេចក្តីបួលចិត្តថា វិចិកិច្ឆាបរិយុដ្ឋានៈ នឹងមិនកើតឡើង ឈ្មោះថាលះបង់ហើយឬ ។ អើ ។ បុគ្គលជាគោ-ត្រភូ ធ្វើសេចក្តីបួលចិត្តថា វិចិកិច្ឆាបរិយុដ្ឋានៈ នឹងមិនកើតឡើង ឈ្មោះថាលះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ អដ្ឋមកកថា ។

# អដ្ឋមកស្ស ឥន្ទ្រិយកថា

(៣៣៤) អដ្ឋមកស្ស បុគ្គលស្ស នត្ថិ សទ្ធិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស នត្ថិ សទ្ធាតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣៣៥) អដ្ឋមកស្ស បុគ្គលស្ស នត្ថិ វីរិយិន្ទ្រិយំ ។បេ។ នត្ថិ សតិន្ទ្រិយំ ។បេ។ នត្ថិ សមាធិន្ទ្រិយំ ។បេ។ នត្ថិ បញ្ញិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស នត្ថិ បញ្ញាតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣៣៦) អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សទ្ធាតិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សទ្ធិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ វីរិយំ ។បេ។ អត្ថិ សតិ អត្ថិ សមាធិ ។បេ។ អត្ថិ បញ្ញាតិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ បញ្ញិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

# អដ្ឋមកឥន្ទ្រិយកថា

(៣៣៤) បុគ្គលទី ៨ មិនមានសទ្ធិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ មិនមានសទ្ធាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៣៥) បុគ្គលទី ៨ មិនមានវីរិយិន្ទ្រិយ ។ បេ ។ មិនមានសតិន្ទ្រិយ ។ បេ ។ មិនមានសមាធិន្ទ្រិយ ។ បេ ។ មិនមានបញ្ញិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ មិនមានបញ្ញាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៣៦) បុគ្គលទី ៨ មានសទ្ធាដែរឬ ។ អើ ។ បុគ្គលទី ៨ មានសទ្ធិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលទី ៨ មានវីរិយៈ ។ បេ ។ មានសតិ មានសមាធិ ។ បេ ។ មានបញ្ញាដែរឬ ។ អើ ។ បុគ្គលទី ៨ មានបញ្ញិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៣៧) អដ្ឋមកស្ស បុគ្គលស្ស អត្ថិ មនោ អត្ថិ មនិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សទ្ធា អត្ថិ សទ្ធិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ មនោ អត្ថិ មនិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ បញ្ញា អត្ថិ បញ្ញិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៣៨) អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សោមនស្សំ អត្ថិ សោមនស្សិន្ទ្រិយំ ។ បេ ។ អត្ថិ ជីវិតំ អត្ថិ ជីវិតិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សទ្ធា អត្ថិ សទ្ធិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ ជីវិតំ អត្ថិ ជីវិតិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ វីរិយំ ។ បេ ។ អត្ថិ បញ្ញា អត្ថិ បញ្ញិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៣៩) អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សទ្ធា នត្ថិ សទ្ធិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ មនោ នត្ថិ មនិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៣៣៧ ) បុគ្គលទី ៨ មានមនោ មានមនិន្ទ្រិយដែរឬ ។ អើ ។ បុគ្គលទី ៨ មានសទ្ធា មានសទ្ធិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលទី ៨ មានមនោ មានមនិន្ទ្រិយដែរឬ ។ អើ ។ បុគ្គលទី ៨ មានបញ្ញា មានបញ្ញិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៣៨ ) បុគ្គលទី ៨ មានសោមនស្ស មានសោមនស្សិន្ទ្រិយ ។ បេ ។ មានជីវិត មានជីវិតិន្ទ្រិយដែរឬ ។ អើ ។ បុគ្គលទី ៨ មានសទ្ធា មានសទ្ធិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលទី ៨ មានជីវិត មានជីវិតិន្ទ្រិយដែរឬ ។ អើ ។ បុគ្គលទី ៨ មានវីរិយៈ ។ បេ ។ មានបញ្ញា មានបញ្ញិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៣៩ ) បុគ្គលទី ៨ មានតែសទ្ធា មិនមានសទ្ធិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ មានតែមនោ មិនមានមនិន្ទ្រិយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

## អដ្ឋមកស្ស ឥន្ទ្រិយកថា

(៣៤០) អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សទ្ធា នត្ថិ សទ្ធិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សោមនស្សំ នត្ថិ សោមនស្សិន្ទ្រិយំ ។ បេ ។ អត្ថិ ជីវិតំ នត្ថិ ជីវិតិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៤១) អដ្ឋមកស្ស បុគ្គលស្ស អត្ថិ បញ្ញា នត្ថិ បញ្ញិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ មនោ នត្ថិ មនិន្ទ្រិយន្តិ ។ បេ ។ អត្ថិ សោមនស្សំ នត្ថិ សោមនស្សិន្ទ្រិយន្តិ ។ បេ ។ អត្ថិ ជីវិតំ នត្ថិ ជីវិតិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៤២) អដ្ឋមកស្ស បុគ្គលស្ស នត្ថិ សទ្ធិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកោ បុគ្គលោ អសទ្ធោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋមកស្ស បុគ្គលស្ស នត្ថិ វីរិយិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកោ បុគ្គលោ កុសីតោ ហីនវីរិយោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋមកស្ស បុគ្គលស្ស នត្ថិ សតិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកោ បុគ្គលោ មុដ្ឋស្សតិ អសម្បជានោតិ ។

អដ្ឋមកឥន្ទ្រិយកថា

[៣៤០] បុគ្គលទី ៨ មានតែសទ្ធា មិនមានសទ្ធិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ មានតែសោមនស្ស មិនមានសោមនស្សិន្ទ្រិយ ។ បេ ។ មានតែជីវិត មិនមានជីវិតិន្ទ្រិយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៤១] បុគ្គលទី ៨ មានតែបញ្ញា មិនមានបញ្ញិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ មានតែមនោ មិនមានមនិន្ទ្រិយ ។ បេ ។ មានតែសោមនស្ស មិនមានសោមនស្សិន្ទ្រិយ ។ បេ ។ មានតែជីវិត មិនមានជីវិតិន្ទ្រិយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៤២] បុគ្គលទី ៨ មិនមានសទ្ធិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ ជាអ្នកមិនមានសទ្ធាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលទី ៨ មិនមានវីរិយិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ ជាអ្នកខ្ជិលច្រអូស មិនមានព្យាយាមទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលទី ៨ មិនមានសតិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ ជាអ្នកភ្លេចស្មារតី មិនដឹងខ្លួនឬ ។

ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋមកស្ស បុគ្គលស្ស នត្ថិ សមាធិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកោ បុគ្គលោ អសមាហិតោ វិព្ភន្តចិត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៤៣) អដ្ឋមកស្ស បុគ្គលស្ស នត្ថិ បញ្ញិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកោ បុគ្គលោ ទុប្បញ្ញោ ឯឡមូគោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៤៤) អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សទ្ធា សា ច សទ្ធា និយ្យានិកាតិ ។ អាមន្តា ។ ហញ្ចិ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សទ្ធា សា ច សទ្ធា និយ្យានិកា តេន វត រេ វត្តព្វេ អដ្ឋមកស្ស បុគ្គលស្ស នត្ថិ សទ្ធិន្ទ្រិយន្តិ ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ វីរិយំ តញ្ច វីរិយំ និយ្យានិកំ ។ បេ ។ អត្ថិ សតិ សា ច សតិ និយ្យានិកា ។ បេ ។ អត្ថិ សមាធិ សោ ច សមាធិ និយ្យានិកោ ។ បេ ។ អត្ថិ បញ្ញា សា ច បញ្ញា និយ្យានិកាតិ ។ អាមន្តា ។ ហញ្ចិ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ បញ្ញា សា ច បញ្ញា និយ្យានិកា តេន វត រេ វត្តព្វេ អដ្ឋមកស្ស បុគ្គលស្ស នត្ថិ បញ្ញិន្ទ្រិយន្តិ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលទី ៨ មិនមានសមាធិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ ជាអ្នកមានចិត្តមិនខ្ជាប់ខ្ជួន មានចិត្តរាយមាយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៤៣) បុគ្គលទី ៨ មិនមានបញ្ញិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ ជាអ្នកឥតប្រាជ្ញា ជាមនុស្សល្ងង់ខ្លៅឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៤៤) បើបុគ្គលទី ៨ មានសទ្ធា ចុះសទ្ធានោះ ជាធម្មជាតិនាំសត្វចេញចាកទុក្ខដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលទី ៨ មានសទ្ធា សទ្ធានោះឯង ជាធម្មជាតិនាំសត្វចេញចាកទុក្ខមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលទី ៨ មិនមានសទ្ធិន្ទ្រិយទេ ។ បុគ្គលទី ៨ មានវីរិយៈ ចុះវីរិយៈនោះ ជាធម្មជាតនាំសត្វចេញចាកទុក្ខ ។ បេ ។ មានសតិ ចុះសតិនោះ ជាធម្មជាតិនាំសត្វចេញចាកទុក្ខ ។ បេ ។ មានសមាធិ ចុះសមាធិនោះ ជាធម៌នាំសត្វចេញចាកទុក្ខ ។ បេ ។ មានបញ្ញា ចុះបញ្ញានោះ ជាធម្មជាតិនាំសត្វចេញចាកទុក្ខដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលទី ៨ មានបញ្ញា បញ្ញានោះឯង ជាធម្មជាតិនាំសត្វចេញចាកទុក្ខមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលទី ៨ មិនមានបញ្ញិន្ទ្រិយទេ ។

(៣៤៥) សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស អត្ថិ សទ្ធា អត្ថិ សទ្ធិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សទ្ធា អត្ថិ សទ្ធិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស អត្ថិ បញ្ញា អត្ថិ បញ្ញិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ បញ្ញា អត្ថិ បញ្ញិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៤៦) អនាគាមិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស ។ បេ ។ អរហត្តសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស អត្ថិ សទ្ធា អត្ថិ សទ្ធិន្ទ្រិយំ ។ បេ ។ អត្ថិ បញ្ញា អត្ថិ បញ្ញិន្ទ្រិយន្តិ ។ អាមន្តា ។ អដ្ឋមកស្ស បុគ្គលស្ស អត្ថិ បញ្ញា អត្ថិ បញ្ញិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៤៧) អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សទ្ធា នត្ថិ សទ្ធិន្ទ្រិយន្តិ ។ អាមន្តា ។ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស អត្ថិ សទ្ធា នត្ថិ សទ្ធិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អដ្ឋមកឥន្ទ្រិយកថា

(៣៤៥) បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល មានសទ្ធា មានសទ្ធិន្ទ្រិយដែរឬ ។ អើ ។ បុគ្គលទី ៨ មានសទ្ធា មានសទ្ធិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល មានបញ្ញា មានបញ្ញិន្ទ្រិយដែរឬ ។ អើ ។ បុគ្គលទី ៨ មានបញ្ញា មានបញ្ញិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៤៦) បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ។ បេ ។ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត មានសទ្ធា មានសទ្ធិន្ទ្រិយ ។ បេ ។ មានបញ្ញា មានបញ្ញិន្ទ្រិយដែរឬ ។ អើ ។ បុគ្គលទី ៨ មានបញ្ញា មានបញ្ញិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៤៧) បុគ្គលទី ៨ មានតែសទ្ធា មិនមានសទ្ធិន្ទ្រិយទេឬ ។ អើ ។ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល មានតែសទ្ធា មិនមានសទ្ធិន្ទ្រិយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

អដ្ឋមកស្ស បុគ្គលស្ស អត្ថិ បញ្ញា នត្ថិ បញ្ញិន្ទ្រិ-
យន្តិ ។ អាមន្តា ។ សកទាគាមិផលសច្ឆិកិរិយាយ
បដិបន្នស្ស បុគ្គលស្ស អត្ថិ បញ្ញា នត្ថិ បញ្ញិន្ទ្រិ
យន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣៤៨) អដ្ឋមកស្ស បុគ្គលស្ស អត្ថិ សទ្ធា
នត្ថិ សទ្ធិន្ទ្រិយំ ។បេ។ អត្ថិ បញ្ញា នត្ថិ បញ្ញិន្ទ្រិ-
យន្តិ ។ អាមន្តា ។ អនាគាមិផលសច្ឆិកិរិយាយ
បដិបន្នស្ស បុគ្គលស្ស ។បេ។ អរហត្តសច្ឆិកិរិ-
យាយ បដិបន្នស្ស បុគ្គលស្ស អត្ថិ បញ្ញា នត្ថិ
បញ្ញិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣៤៩) អដ្ឋមកស្ស បុគ្គលស្ស នត្ថិ បញ្ចិន្ទ្រិ-
យានីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា បញ្ចិ-
មានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កតមានិ បញ្ច ។ សទ្ធិ-
ន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិ-
យំ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានិ ឥមេសំ
ខោ ភិក្ខវេ បញ្ចន្នំ ឥន្ទ្រិយានំ សមត្តា បរិបូរត្តា

បុគ្គលទី ៨ មានតែបញ្ញា មិនមានបញ្ញិន្ទ្រិយទេឬ ។ អើ ។ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល មានតែបញ្ញា មិនមានបញ្ញិន្ទ្រិយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៤៨] បុគ្គលទី ៨ មានតែសទ្ធា មិនមានសទ្ធិន្ទ្រិយទេ ។ បេ ។ មានតែបញ្ញា មិនមានបញ្ញិន្ទ្រិយទេឬ ។ អើ ។ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ។ បេ ។ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត មានតែបញ្ញា មិនមានបញ្ញិន្ទ្រិយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៤៩] បុគ្គលទី ៨ មិនមានឥន្ទ្រិយ ៥ ទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ យ៉ាង ។ ឥន្ទ្រិយ ៥ យ៉ាង តើដូចម្តេច ។ គឺសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ មាន ៥ យ៉ាង នេះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបានឈ្មោះថាអរហន្ត ព្រោះមានឥន្ទ្រិយទាំង ៥ នេះឯងសម្រេចបរិបូណ៌

អដ្ឋមកស្ស ឥន្ទ្រិយកថា

អរហា ហោតិ តតោ មុទុតរេហិ អរហត្តសច្ឆិកិរិយាយ បដិបន្នោ ហោតិ តតោ មុទុតរេហិ អនាគាមី ហោតិ តតោ មុទុតរេហិ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ ហោតិ តតោ មុទុតរេហិ សកទាគាមី ហោតិ តតោ មុទុតរេហិ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ ហោតិ តតោ មុទុតរេហិ សោតាបន្នោ ហោតិ តតោ មុទុតរេហិ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ ហោតិ យស្ស ខោ ភិក្ខវេ ឥមានិ បញ្ចិន្ទ្រិយានិ សព្វេន សព្វំ សព្វថា សព្វំ នត្ថិ តមហំ ពាហិរោ បុថុជ្ជនបក្ខេ ឋិតោតិ វទាមីតិ អត្ថេវ សុត្តន្តោតិ ។

អដ្ឋមកឥន្ទ្រិយកថា

បុគ្គល ដែលបានឈ្មោះថាអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ព្រោះមានឥន្ទ្រិយទាំងឡាយទន់ ជាឥន្ទ្រិយរបស់បុគ្គលជាអរហន្តនោះ បុគ្គល ដែលបានឈ្មោះថាអនាគាមី ព្រោះមានឥន្ទ្រិយទាំងឡាយទន់ ជាឥន្ទ្រិយរបស់បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តនោះ បុគ្គល ដែលបានឈ្មោះថាអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ព្រោះមានឥន្ទ្រិយទាំងឡាយទន់ ជាឥន្ទ្រិយរបស់បុគ្គលជាអនាគាមីនោះ បុគ្គល ដែលបានឈ្មោះថាសកទាគាមី ព្រោះមានឥន្ទ្រិយទាំងឡាយទន់ ជាឥន្ទ្រិយរបស់បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលនោះ បុគ្គល ដែលបានឈ្មោះថា អ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ព្រោះមានឥន្ទ្រិយទាំងឡាយទន់ ជាឥន្ទ្រិយរបស់បុគ្គលជាសកទាគាមីនោះ បុគ្គល ដែលបានឈ្មោះថាសោតាបន្នៈ ព្រោះមានឥន្ទ្រិយទាំងឡាយទន់ ជាឥន្ទ្រិយរបស់អ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផលនោះ បុគ្គល ដែលបានឈ្មោះថាអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ព្រោះមានឥន្ទ្រិយទាំងឡាយទន់ ជាឥន្ទ្រិយរបស់បុគ្គលជាសោតាបន្នៈនោះ ម្នាលភិក្ខុទាំងឡាយ បុគ្គលណា មិនមានឥន្ទ្រិយទាំង ៥ នេះ សព្វគ្រប់ឥតខ្ចោះ ដោយប្រការទាំងពួងទេ តថាគត ហៅបុគ្គលនោះថាជាអ្នកតាំងនៅ ក្នុងពួកបុថុជ្ជន ជាខាងក្រៅ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។

អាមន្តា ។ អដ្ឋមកោ បុគ្គលោ ពាហិរេ បុថុជ្ជន-
បក្ខេ ឋិតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ
អដ្ឋមកស្ស បុគ្គលស្ស អត្ថិ បញ្ចិន្ទ្រិយានីតិ ។

អដ្ឋមកស្ស ឥន្ទ្រិយកថា ។

## ទិព្វចក្ខុកថា

(៣៨០) មំសចក្ខុំ ធម្មូបត្ថទ្ធំ ទិព្វចក្ខុំ ហោតីតិ ។ អាមន្តា ។ មំសចក្ខុំ ទិព្វចក្ខុំ ទិព្វចក្ខុំ មំសចក្ខុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨១) មំសចក្ខុំ ធម្មូបត្ថទ្ធំ ទិព្វចក្ខុំ ហោតីតិ ។ អាមន្តា ។ យាទិសំ មំសចក្ខុំ តាទិសំ ទិព្វចក្ខុំ យាទិសំ ទិព្វចក្ខុំ តាទិសំ មំសចក្ខុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨២) មំសចក្ខុំ ធម្មូបត្ថទ្ធំ ទិព្វចក្ខុំ ហោតីតិ ។ អាមន្តា ។ តញ្ញេវ មំសចក្ខុំ តំ ទិព្វចក្ខុំ តំ ទិព្វចក្ខុំ តំ មំសចក្ខុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨៣) មំសចក្ខុំ ធម្មូបត្ថទ្ធំ ទិព្វចក្ខុំ ហោតីតិ ។ អាមន្តា ។ យាទិសោ មំសចក្ខុស្ស វិសយោ អានុភាវោ គោចរោ តាទិសោ ទិព្វស្ស ចក្ខុស្ស វិសយោ អានុភាវោ គោចរោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អើ ។ បុគ្គលទី ៨ ឈ្មោះថាតាំងនៅ ក្នុងពួកបុថុជ្ជន ជាខាងក្រៅឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ បុគ្គលទី ៨ ក៏មានឥន្ទ្រិយ ៥ ដែរ ។

ចប់ អដ្ឋមកឥន្ទ្រិយកថា ។

# ទិព្វចក្ខុកថា

( ៣៩០ ) មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។ អើ ។ មំសចក្ខុ គឺទិព្វចក្ខុ ឯទិព្វចក្ខុ គឺមំសចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៩១ ) មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។ អើ ។ មំសចក្ខុ ដូចម្តេច ទិព្វចក្ខុ ក៏ដូច្នោះ ទិព្វចក្ខុ ដូចម្តេច មំសចក្ខុ ក៏ដូច្នោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៩២ ) មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។ អើ ។ មំសចក្ខុនោះឯង គឺទិព្វចក្ខុនោះ ទិព្វចក្ខុនោះ គឺមំសចក្ខុនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៩៣ ) មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។ អើ ។ មំសចក្ខុ មានវិស័យ មានអានុភាព មានគោចរ ដូចម្តេច ទិព្វចក្ខុ ក៏មានវិស័យ មានអានុភាព មានគោចរ ដូច្នោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

## ទិព្វចក្ខុកថា

(៣៨៤) មំសចក្ខុំ ធម្មុបត្ថទ្ធំ ទិព្វចក្ខុំ ហោតីតិ ។ អាមន្តា ។ ឧបាទិន្នំ ហុត្វា អនុបាទិន្នំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨៥) ឧបាទិន្នំ ហុត្វា អនុបាទិន្នំ ហោតីតិ ។ អាមន្តា ។ កាមាវចរំ ហុត្វា រូបាវចរំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨៦) កាមាវចរំ ហុត្វា រូបាវចរំ ហោតីតិ ។ អាមន្តា ។ រូបាវចរំ ហុត្វា អរូបាវចរំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨៧) រូបាវចរំ ហុត្វា អរូបាវចរំ ហោតីតិ ។ អាមន្តា ។ បរិយាបន្នំ ហុត្វា អបរិយាបន្នំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨៨) មំសចក្ខុំ ធម្មុបត្ថទ្ធំ ទិព្វចក្ខុំ ហោតីតិ ។ អាមន្តា ។ ទិព្វចក្ខុំ ធម្មុបត្ថទ្ធំ មំសចក្ខុំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨៩) មំសចក្ខុំ ធម្មុបត្ថទ្ធំ ទិព្វចក្ខុំ ហោតីតិ ។ អាមន្តា ។ ទិព្វចក្ខុំ ធម្មុបត្ថទ្ធំ បញ្ញាចក្ខុំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ទុព្ពបក្ខកថា

( ៣៩៤ ) មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។ អើ ។ (មំសចក្ខុ) ជាឧបាទិន្នៈ ទៅជា ( ទិព្វចក្ខុ ) អនុបាទិន្នៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៩៥ ) ឧបាទិន្នៈ ទៅជាអនុបាទិន្នៈឬ ។ អើ ។ កាមាវចរៈ ទៅជារូបាវចរៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៩៦ ) កាមាវចរៈ ទៅជារូបាវចរៈឬ ។ អើ ។ រូបាវចរៈ ទៅជាអរូបាវចរៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៩៧ ) រូបាវចរៈ ទៅជាអរូបាវចរៈឬ ។ អើ ។ បរិយាបន្នៈ ទៅជាអបរិយាបន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៩៨ ) មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។ អើ ។ ទិព្វចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាមំសចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៣៩៩ ) មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។ អើ ។ ទិព្វចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាបញ្ញាចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៦០) មំសចក្ខុំ ធម្មុបត្ថទ្ធំ ទិព្វចក្ខុំ ហោតីតិ ។ អាមន្តា ។ ទិព្វចក្ខុំ ធម្មុបត្ថទ្ធំ មំសចក្ខុំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៦១) មំសចក្ខុំ ធម្មុបត្ថទ្ធំ ទិព្វចក្ខុំ ហោតីតិ ។ អាមន្តា ។ ទ្វេ ចក្ខូនីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៦២) ទ្វេ ចក្ខូនីតិ ។ អាមន្តា ។ ននុ តីណិ ចក្ខូនិ វុត្តានិ ភគវតា មំសចក្ខុំ ទិព្វចក្ខុំ បញ្ញាចក្ខុន្តិ ។ អាមន្តា ។ ហញ្ចិ តីណិ ចក្ខូនិ វុត្តានិ ភគវតា មំសចក្ខុំ ទិព្វចក្ខុំ បញ្ញាចក្ខុំ តេន វត រេ វត្តព្វេ ទ្វេ ចក្ខូនីតិ ។

(៣៦៣) ទ្វេ ចក្ខូនីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា តីណិមានិ ភិក្ខវេ ចក្ខូនិ ។ កតមានិ តីណិ ។ មំសចក្ខុំ ទិព្វចក្ខុំ បញ្ញាចក្ខុំ ឥមានិ ខោ ភិក្ខវេ តីណិ ចក្ខូនីតិ

[៣៦០] មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។ អើ ។ ទិព្វចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាមំសចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៦១] មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។ អើ ។ ចក្ខុទាំងឡាយ មានតែពីរប៉ុណ្ណោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៦២] ចក្ខុទាំងឡាយ មានតែពីរប៉ុណ្ណោះឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ចក្ខុទាំងឡាយ មាន ៣ គឺមំសចក្ខុ ១ ទិព្វចក្ខុ ១ បញ្ញាចក្ខុ ១ ដូច្នេះមែនឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ចក្ខុទាំងឡាយ មាន ៣ គឺមំសចក្ខុ ១ ទិព្វចក្ខុ ១ បញ្ញាចក្ខុ ១ ដូច្នេះមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុទាំង-ឡាយ មានតែពីរប៉ុណ្ណោះទេ ។

[៣៦៣] ចក្ខុទាំងឡាយ មានតែពីរប៉ុណ្ណោះឬ ។ អើ ។ ក្រែង ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចក្ខុទាំងឡាយ មាន ៣ ។ ចក្ខុទាំង ៣ តើដូចម្តេច ។ គឺ មំសចក្ខុ ១ ទិព្វចក្ខុ ១ បញ្ញាចក្ខុ ១ ម្នាលភិក្ខុទាំងឡាយ ចក្ខុទាំងឡាយ មាន ៣ យ៉ាងនេះឯង

មំសចក្ខុំ ទិព្វចក្ខុំ    បញ្ញាចក្ខុំ អនុត្តរំ
ឯតានិ តីណិ ចក្ខូនិ    អក្ខាសិ បុរិសុត្តមោ
មំសចក្ខុស្ស ឧប្បាទោ    មគ្គោ ទិព្វស្ស ចក្ខុនោ
យទា ច ញាណំ ឧទបាទិ    បញ្ញាចក្ខុំ អនុត្តរំ
តស្ស ចក្ខុស្ស បដិលាភា សព្វទុក្ខា បមុច្ចតីតិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ ទ្វេ ចក្ខូនីតិ ។

ទិព្វចក្ខុកថា ។

# ទិព្វសោតកថា

(៣៦៨) មំសសោតំ ធម្មុបត្ថទ្ធំ ទិព្វសោតំ ហោតីតិ ។ អាមន្តា ។ មំសសោតំ ទិព្វសោតំ ទិព្វសោតំ មំសសោតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៦៩) មំសសោតំ ធម្មុបត្ថទ្ធំ ទិព្វសោតំ ហោតីតិ ។ អាមន្តា ។ យាទិសំ មំសសោតំ តាទិសំ ទិព្វសោតំ យាទិសំ ទិព្វសោតំ តាទិសំ មំសសោតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

បុរសឧត្តម បានពោលថា ចក្ខុទាំងឡាយ មាន ៣ ប៉ុណ្ណោះ គឺមំសចក្ខុ ១ ទិព្វចក្ខុ ១ បញ្ញាចក្ខុជាធម្មជាតដ៏ប្រសើរ ១ ការកើតឡើងនៃមំសចក្ខុ ជាផ្លូវនាំឲ្យកើតឡើងនៃទិព្វចក្ខុ កាលណាបើញាណ កើតឡើងហើយ បញ្ញាចក្ខុដ៏ប្រសើរ (ក៏កើតឡើង កាលណោះដែរ) បុគ្គលរួចស្រឡះចាកទុក្ខទាំងអស់ ព្រោះតែបានបញ្ញាចក្ខុនោះ

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ចក្ខុទាំងឡាយ មានតែ ២ ប៉ុណ្ណោះទេ ។

ចប់ ទិព្វចក្ខុកថា ។

## ទិព្វសោតកថា

(៣៦៤) មំសសោត ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វសោតឬ ។ អើ ។ មំសសោត គឺទិព្វសោត ទិព្វសោត គឺមំសសោតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៦៥) មំសសោត ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វសោតឬ ។ អើ ។ មំសសោត ដូចម្តេច ទិព្វសោត ក៏ដូច្នោះដែរ ទិព្វសោត ដូចម្តេច មំសសោត ក៏ដូច្នោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣៦៦ ] មំសសោតំ ធម្មុបត្ថទ្ធំ ទិព្វសោតំ ហោតីតិ ។ អាមន្តា ។ តញ្ញេវ មំសសោតំ តំ ទិព្វសោតំ តំ ទិព្វសោតំ តំ មំសសោតន្តិ ។ ន ហេវំ វត្តព្វេ ។បេ ។

[ ៣៦៧ ] មំសសោតំ ធម្មុបត្ថទ្ធំ ទិព្វសោតំ ហោតីតិ ។ អាមន្តា ។ យាទិសោ មំសសោតស្ស វិសយោ អានុភាវោ គោចរោ តាទិសោ ទិព្វសោតស្ស វិសយោ អានុភាវោ គោចរោតិ ។ ន ហេវំ វត្តព្វេ ។បេ ។

[ ៣៦៨ ] មំសសោតំ ធម្មុបត្ថទ្ធំ ទិព្វសោតំ ហោតីតិ ។ អាមន្តា ។ ឧបាទិន្នំ ហុត្វា អនុបាទិន្នំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។បេ ។

[ ៣៦៩ ] ឧបាទិន្នំ ហុត្វា អនុបាទិន្នំ ហោតីតិ ។ អាមន្តា ។ កាមាវចរំ ហុត្វា រូបាវចរំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។បេ ។

[ ៣៧០ ] កាមាវចរំ ហុត្វា រូបាវចរំ ហោតីតិ ។ អាមន្តា ។ រូបាវចរំ ហុត្វា អរូបាវចរំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។បេ ។

[ ៣៦៦ ] មំសសោត ដែលធម៌ទ្រទ្រង់ហើយ ជាទិព្វសោត ឬ ។ អើ ។ មំសសោតនោះឯង គឺទិព្វសោតនោះ ទិព្វសោតនោះ គឺមំសសោតនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣៦៧ ] មំសសោត ដែលធម៌ទ្រទ្រង់ហើយ ជាទិព្វសោត ឬ ។ អើ ។ មំសសោត មានវិស័យ អានុភាព គោចរ ដូចម្តេច ទិព្វសោត ក៏មានវិស័យ អានុភាព គោចរ ដូច្នោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣៦៨ ] មំសសោត ដែលធម៌ទ្រទ្រង់ហើយ ជាទិព្វសោត ឬ ។ អើ ។ មំសសោត ជាឧបាទិន្នៈ ទៅជា (ទិព្វសោត) អនុបាទិន្នៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣៦៩ ] (មំសសោត) ជាឧបាទិន្នៈ ទៅជា (ទិព្វសោត) អនុបាទិន្នៈឬ ។ អើ ។ កាមាវចរៈ ទៅជារូបាវចរៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣៧០ ] កាមាវចរៈ ទៅជារូបាវចរៈឬ ។ អើ ។ រូបាវចរៈ ទៅជាអរូបាវចរៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ទិព្វសោតកថា

[៣៧១] រូបាវចរំ ហុត្វា អរូបាវចរំ ហោតីតិ ។ អាមន្តា ។ បរិយាបន្នំ ហុត្វា អបរិយាបន្នំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៧២] មំសសោតំ ធម្មុបត្ថទ្ធំ ទិព្វសោតំ ហោតីតិ ។ អាមន្តា ។ ទិព្វសោតំ ធម្មុបត្ថទ្ធំ មំសសោតំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៧៣] មំសសោតំ ធម្មុបត្ថទ្ធំ ទិព្វសោតំ ហោតីតិ ។ អាមន្តា ។ ឯកញ្ញេវ សោតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៧៤] ឯកញ្ញេវ សោតន្តិ ។ អាមន្តា ។ ននុ ទ្វេ សោតានិ វុត្តានិ ភគវតា មំសសោតំ ទិព្វសោតន្តិ ។ អាមន្តា ។ ហញ្ចិ ទ្វេ សោតានិ វុត្តានិ ភគវតា មំសសោតំ ទិព្វសោតំ នោ ច វត រេ វត្តព្វេ ឯកញ្ញេវ សោតន្តិ ។

ទិព្វសោតកថា ។

ទិព្វសោតកថា

[ ៣៧១ ] រូបាវចរៈ ទៅជាអរូបាវចរៈឬ ។ អើ ។ បរិយាបន្នៈ ទៅជាអបរិយាបន្នៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣៧២ ] មំសសោត ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វសោតឬ ។ អើ ។ ទិព្វសោត ដែលធម៌ទំនុកបម្រុងហើយ ជាមំសសោតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣៧៣ ] មំសសោត ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វសោតឬ ។ អើ ។ សោតៈ មានតែមួយប៉ុណ្ណោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣៧៤ ] សោតៈ មានតែមួយប៉ុណ្ណោះឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា សោតៈទាំងឡាយ មាន ២ គឺមំសសោត១ ទិព្វសោត ១ មែនឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា សោតៈទាំងឡាយ មាន ២ គឺមំសសោត ១ ទិព្វសោត ១ មែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សោតៈ មានតែមួយប៉ុណ្ណោះទេ ។

ចប់ ទិព្វសោតកថា ។

# យថាកម្មូបគតញ្ញាណកថា

(៣៧៥) យថាកម្មូបគតញ្ញាណំ ទិព្វចក្ខុន្តិ ។ អាមន្តា ។ យថាកម្មូបគតេ មនសិករោតិ ទិព្វេន ចក្ខុនា រូបំ បស្សតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣៧៦) យថាកម្មូបគតេ មនសិករោតិ ទិព្វេន ចក្ខុនា រូបំ បស្សតីតិ ។ អាមន្តា ។ ទ្វិន្នំ ផស្សានំ ទ្វិន្នំ ចិត្តានំ សមោធានំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣៧៧) យថាកម្មូបគតញ្ញាណំ ទិព្វចក្ខុន្តិ ។ អាមន្តា ។ ឥមេ វត ភោន្តោ សត្តាតិ ច មនសិករោតិ កាយទុច្ចរិតេន សមន្នាគតាតិ ច មនសិករោតិ វចីទុច្ចរិតេន សមន្នាគតាតិ ច មនសិករោតិ មនោទុច្ចរិតេន សមន្នាគតាតិ ច មនសិករោតិ អរិយានំ ឧបវាទកាតិ ច មនសិករោតិ មិច្ឆាទិដ្ឋិកាតិ ច មនសិករោតិ មិច្ឆាទិដ្ឋិកម្មសមាទានាតិ ច មនសិករោតិ តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នាតិ ច មនសិករោតិ ឥមេ វា បន ភោន្តោ សត្តាតិ ច មនសិករោតិ

# យថាកម្មូបគតញ្ញាណកថា

(៣៧៥) យថាកម្មូបគតញ្ញាណ (ការដឹងពួកសត្វ ដែលអន្ទោលទៅតាមកម្ម) គឺទិព្វចក្ខុ ។ អើ ។ បុគ្គល ធ្វើទុកក្នុងចិត្ត ចំពោះយថាកម្មូបគតៈ (សត្វដែលអន្ទោលទៅតាមកម្ម) ឈ្មោះថាឃើញរូប ដោយទិព្វចក្ខុ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៧៦) បុគ្គល ធ្វើទុកក្នុងចិត្ត ចំពោះយថាកម្មូបគតៈ ឈ្មោះថាឃើញរូប ដោយទិព្វចក្ខុ ។ អើ ។ ការប្រជុំ នៃផស្សៈទាំង ២ នៃចិត្តទាំង ២ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៧៧) យថាកម្មូបគតញ្ញាណ គឺទិព្វចក្ខុ ។ អើ ។ បុគ្គល ធ្វើទុកក្នុងចិត្តថា អើហ្ន៎ ពួកសត្វដ៏ចម្រើនទាំងអម្បាលនេះ ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វប្រកបដោយកាយទុច្ចរិត ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វប្រកបដោយវចីទុច្ចរិត ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វប្រកបដោយមនោទុច្ចរិត ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វអ្នកតិះដៀលព្រះអរិយៈទាំងឡាយ ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វជាមិច្ឆាទិដ្ឋិ ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វប្រកាន់នូវអំពើជាមិច្ឆាទិដ្ឋិ ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វទាំងនោះ បែកធ្លាយរាងកាយស្លាប់ហើយ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត និងនរក ដូច្នេះខ្លះ មួយទៀត បុគ្គល ធ្វើទុកក្នុងចិត្តថា អើហ្ន៎ ពួកសត្វដ៏ចម្រើនទាំងអម្បាលនេះ ដូច្នេះខ្លះ

កាយសុចរិតេន សមន្នាគតាតិ ច មនសិករោតិ វចីសុចរិតេន សមន្នាគតាតិ ច មនសិករោតិ មនោសុចរិតេន សមន្នាគតាតិ ច មនសិករោតិ អរិយានំ អនុបវាទកាតិ ច មនសិករោតិ សម្មាទិដ្ឋិកាតិ ច មនសិករោតិ សម្មាទិដ្ឋិកម្មសមាទានាតិ ច មនសិករោតិ តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ច មនសិករោតិ ទិព្វេន ចក្ខុនា រូបំ បស្សតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៣៧៨ ) យថាកម្មូបគតញាណំ ទិព្វចក្ខុន្តិ ។ អាមន្តា ។ ឥមេ វត ភោន្តោ សត្តាតិ ច មនសិករោតិ ។ បេ ។ តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ច មនសិករោតិ ទិព្វេន ចក្ខុនា រូបំ បស្សតីតិ ។ អាមន្តា ។ ទ្វិន្នំ ផស្សានំ ទ្វិន្នំ ចិត្តានំ សមោធានំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៣៧៩ ) យថាកម្មូបគតញាណំ ទិព្វចក្ខុន្តិ ។ អាមន្តា ។ អត្ថិ កោចិ អទិព្វចក្ខុកោ ទិព្វចក្ខុំ អប្បដិលទ្ធោ អនធិគតោ អសច្ឆិកតោ យថាកម្មូបគតំ ជានាតីតិ ។

យថាកម្មូបគតញ្ញាណកថា

ធ្វើទុកក្នុងចិត្តថា ពួកសត្វប្រកបដោយកាយសុចរិត ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វប្រកបដោយវចីសុចរិត ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វប្រកបដោយមនោសុចរិត ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វជាអ្នកមិនតិះដៀលព្រះអរិយៈទាំងឡាយ ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វជាសម្មាទិដ្ឋិ ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វជាអ្នកប្រកាន់នូវអំពើជាសម្មាទិដ្ឋិ ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ហើយ ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ដូច្នេះខ្លះ ឈ្មោះថាឃើញរូប ដោយទិព្វចក្ខុ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៧៨) យថាកម្មូបគតញ្ញាណ គឺទិព្វចក្ខុ ។ អើ ។ បុគ្គលធ្វើទុកក្នុងចិត្តថា អើហ្ន៎ ពួកសត្វដ៏ចម្រើនទាំងអម្បាលនេះ ដូច្នេះខ្លះ ។ បេ ។ ធ្វើទុកក្នុងចិត្តថា ពួកសត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ហើយ ទៅកើតក្នុងសុគតិសួគ៌ ទេវលោក ដូច្នេះខ្លះ ឈ្មោះថាឃើញរូប ដោយទិព្វចក្ខុ ។ អើ ។ ការប្រជុំ នៃផស្សៈទាំង ២ នៃចិត្តទាំង ២ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៧៩) យថាកម្មូបគតញ្ញាណ គឺទិព្វចក្ខុ ។ អើ ។ បុគ្គលណាមួយ មិនមានទិព្វចក្ខុ មិនបានបំពោះ មិនបានត្រាស់ដឹង មិនធ្វើឲ្យជាក់ច្បាស់ នូវទិព្វចក្ខុ តែងដឹង នូវយថាកម្មូបគៈ មានដែរឬ ។

អាមន្តា ។ ហញ្ចិ អត្ថិ កោចិ អទិព្វចក្ខុកោ ទិព្វចក្ខុំ អប្បដិលទ្ធោ អនធិគតោ អសច្ឆិកតោ យថាកម្មូបគតំ ជានាតិ នោ វត រេ វត្តព្វេ យថាកម្មូបគតញាណំ ទិព្វចក្ខុន្តិ ។

(៣៨០) យថាកម្មូបគតញាណំ ទិព្វចក្ខុន្តិ ។ អាមន្តា ។ អាយស្មា សារីបុត្តោ យថាកម្មូបគតំ(១) ជានាតីតិ ។ អាមន្តា ។ ហញ្ចិ អាយស្មា សារីបុត្តោ យថាកម្មូបគតំ ជានាតិ នោ វត រេ វត្តព្វេ យថាកម្មូបគតញាណំ ទិព្វចក្ខុន្តិ ។

(៣៨១) អាយស្មា សារីបុត្តោ យថាកម្មូបគតំ ជានាតីតិ ។ អាមន្តា ។ អត្ថាយស្មតោ សារីបុត្តស្ស ទិព្វចក្ខុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨២) អត្ថាយស្មតោ សារីបុត្តស្ស ទិព្វចក្ខុន្តិ ។ អាមន្តា ។ ននុ អាយស្មា សារីបុត្តោ ឯតទវោច

នេវ បុព្វេ និវាសាយ  នបិ ទិព្វស្ស ចក្ខុនោ
ចេតោបរិយាយ ឥទ្ធិយា  សោតធាតុវិសុទ្ធិយា
ចុតិយា ឧបបត្តិយា  បណិធិ មេ ន វិជ្ជតីតិ

១ ម. ឯត្ថន្តរេ ញាណន្តិ ទិស្សតិ ។ ឯវំ សព្វត្ថ ។

អើ ។ ប្រសិនបើ បុគ្គលណាមួយ មិនមានទិព្វចក្ខុ មិនបានចំពោះ មិនបានត្រាស់ដឹង មិនបានធ្វើឲ្យជាក់ច្បាស់ នូវទិព្វចក្ខុទេ តែដឹង នូវយថាកម្មូបគតៈដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា យថាកម្មូបគតញ្ញាណ គឺទិព្វចក្ខុទេ ។

(៣៨០) យថាកម្មូបគតញ្ញាណ គឺទិព្វចក្ខុឬ ។ អើ ។ ព្រះសារីបុត្រមានអាយុ បានជ្រាប នូវយថាកម្មូបគតៈឬ ។ អើ ។ ប្រសិនបើ ព្រះសារីបុត្រមានអាយុ បានជ្រាប នូវយថាកម្មូបគតៈដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា យថាកម្មូបគតញ្ញាណ គឺទិព្វចក្ខុទេ ។

(៣៨១) ព្រះសារីបុត្រមានអាយុ បានជ្រាប នូវយថាកម្មូបគតៈឬ ។ អើ ។ ព្រះសារីបុត្រមានអាយុ មានទិព្វចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៨២) ព្រះសារីបុត្រមានអាយុ មានទិព្វចក្ខុឬ ។ អើ ។ ក្រែងព្រះសារីបុត្រមានអាយុ បានពោលគាថានេះថា

ការតាំងចិត្ត របស់ខ្ញុំ មិនមាន ដើម្បីបុព្វេនិវាសានុស្ស-
តិញ្ញាណ មិនមាន ដើម្បីទិព្វចក្ខុ មិនមាន ដើម្បីចេតោបរិ-
យញ្ញាណ មិនមាន ដើម្បីឥទ្ធិវិធញ្ញាណ មិនមាន ដើម្បី
សោតធាតុដ៏បរិសុទ្ធ មិនមាន ដើម្បីចុតូបបាតញ្ញាណទេ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ យថាកម្មូបគតញ្ញាណំ និព្វត្តន្តិ ។

យថាកម្មូបគតញ្ញាណកថា ។

## សំវរកថា

[ ៣៨៣ ] អត្ថិ ទេវេសុ សំវរោតិ ។ អាមន្តា ។ អត្ថិ ទេវេសុ អសំវរោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[ ៣៨៤ ] នត្ថិ ទេវេសុ អសំវរោតិ ។ អាមន្តា ។ នត្ថិ ទេវេសុ សំវរោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[ ៣៨៥ ] ននុ អសំវរា សំវរោ សីលំ អត្ថិ ទេវេសុ សំវរោតិ ។ អាមន្តា ។ អត្ថិ ទេវេសុ អសំវរោ យម្ហា អសំវរា សំវរោ សីលន្តិ ។ ន ហេវំ វត្តព្វេ ។ អាជានាហិ និគ្គហំ ហញ្ចិ អសំវរា សំវរោ សីលំ អត្ថិ ទេវេសុ សំវរោ តេន វត វេ វត្តព្វេ អត្ថិ ទេវេសុ អសំវរោ យម្ហា អសំវរា សំវរោ សីលន្តិ យំ តត្ថ វទេសិ វត្តព្វេ ខោ អសំវរា សំវរោ សីលំ អត្ថិ ទេវេសុ សំវរោ នោ ច វត្តព្វេ

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា យថាកម្មុបគតញ្ញាណ គឺទិព្វចក្ខុទេ ។

ចប់ យថាកម្មុបគតញ្ញាណកថា ។

## សំវរកថា

[ ៣៨៣ ] ការសង្រួម មានក្នុងពួកទេវតាឬ ។ អើ ។ ការមិនសង្រួម មានក្នុងពួកទេវតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣៨៤ ] ការមិនសង្រួម មិនមានក្នុងពួកទេវតាទេឬ ។ អើ ។ ការសង្រួម មិនមានក្នុងពួកទេវតាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៣៨៥ ] ក្រែង ការសង្រួម ជាសីល ព្រោះការមិនសង្រួម ចុះការសង្រួម មានក្នុងពួកទេវតាឬ ។ អើ ។ ការសង្រួម ជាសីល ព្រោះការមិនសង្រួមណា ការមិនសង្រួមនោះ មានក្នុងពួកទេវតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរជ្រាបនូវកំហុស ( របស់អ្នក ) ចុះ ប្រសិនបើ ការសង្រួម ជាសីល ព្រោះការមិនសង្រួម ការសង្រួម មានក្នុងពួកទេវតាមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ការសង្រួម ជាសីល ព្រោះការមិនសង្រួមណា ការមិនសង្រួមនោះ មានក្នុងពួកទេវតា ដូច្នេះ បណ្តាពាក្យទាំង ២ ប្រការនោះ អ្នកពោលពាក្យណាថា គេគួរពោលថា ការសង្រួម ជាសីល ព្រោះការមិនសង្រួម ការសង្រួម មានក្នុងពួកទេវតា មិនគួរពោលថា

អត្ថិ ទេវេសុ អសំវរោ យម្ហា អសំវរា សំវរោ សីលន្តិ មិច្ឆា នោ ចេ បន វត្តព្វេ អត្ថិ ទេវេសុ អសំវរោ យម្ហា អសំវរា សំវរោ សីលន្តិ នោ វត រេ វត្តព្វេ អសំវរា សំវរោ សីលំ អត្ថិ ទេវេសុ សំវរោតិ យំ តត្ថ វទេសិ វត្តព្វេ ខោ អសំវរា សំវរោ សីលំ អត្ថិ ទេវេសុ សំវរោ នោ ច វត្តព្វេ អត្ថិ ទេវេសុ អសំវរោ យម្ហា អសំវរា សំវរោ សីលន្តិ មិច្ឆា ។

(៣៨៦) អត្ថិ មនុស្សេសុ សំវរោ អត្ថិ តត្ថ អសំវរោតិ ។ អាមន្តា ។ អត្ថិ ទេវេសុ សំវរោ អត្ថិ តត្ថ អសំវរោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨៧) អត្ថិ ទេវេសុ សំវរោ នត្ថិ តត្ថ អសំវរោតិ ។ អាមន្តា ។ អត្ថិ មនុស្សេសុ សំវរោ នត្ថិ តត្ថ អសំវរោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ការសង្រួម ជាសីល ព្រោះការមិនសង្រួមណា ការមិនសង្រួមនោះ មានក្នុងពួកទេវតា ដូច្នេះ ពាក្យនោះ ជាពាក្យខុសទេ ប្រសិនបើ គេមិនគួរពោលថា ការសង្រួម ជាសីល ព្រោះការមិនសង្រួមណា ការមិនសង្រួមនោះ មានក្នុងពួកទេវតា ដូច្នេះ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការសង្រួម ជាសីល ព្រោះការមិនសង្រួម ការសង្រួម មានក្នុងពួកទេវតា ដូច្នេះ បណ្តាពាក្យទាំង ២ ប្រការនោះ អ្នកពោលពាក្យណាថា គេគួរពោលថា ការសង្រួម ជាសីល ព្រោះការមិនសង្រួម ការសង្រួម មានក្នុងពួកទេវតា មិនគួរពោលថា ការសង្រួមជាសីល ព្រោះការមិនសង្រួមណា ការមិនសង្រួមនោះ មានក្នុងពួកទេវតា ដូច្នេះ ពាក្យនោះ ជាពាក្យខុសទេ ។

[៣៨៦] ការសង្រួម មានក្នុងពួកមនុស្ស ចុះការមិនសង្រួម មាន ក្នុងពួកមនុស្សនោះដែរឬ ។ អើ ។ ការសង្រួម មានក្នុងពួកទេវតា ចុះការមិនសង្រួម មានក្នុងពួកទេវតានោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៨៧] ការសង្រួម មានក្នុងពួកទេវតា ចុះការមិនសង្រួម មិនមានក្នុងពួកទេវតានោះទេឬ ។ អើ ។ ការសង្រួម មានក្នុងពួកមនុស្ស ចុះការមិនសង្រួម មិនមានក្នុងពួកមនុស្សនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

## សំវរកថា

[៣៨៨] អត្ថិ ទេវេសុ បាណាតិបាតា វេរមណីតិ ។ អាមន្តា ។ អត្ថិ ទេវេសុ បាណាតិបាតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ ទេវេសុ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីតិ ។ អាមន្តា ។ អត្ថិ ទេវេសុ សុរាមេរយមជ្ជប្បមាទដ្ឋានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៨៩] នត្ថិ ទេវេសុ បាណាតិបាតោតិ ។ អាមន្តា ។ នត្ថិ ទេវេសុ បាណាតិបាតា វេរមណីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ នត្ថិ ទេវេសុ សុរាមេរយមជ្ជប្បមាទដ្ឋានន្តិ ។ អាមន្តា ។ នត្ថិ ទេវេសុ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៩០] អត្ថិ មនុស្សេសុ បាណាតិបាតា វេរមណី អត្ថិ តត្ថ បាណាតិបាតោតិ ។ អាមន្តា ។ អត្ថិ ទេវេសុ បាណាតិបាតា វេរមណី អត្ថិ តត្ថ បាណាតិបាតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ មនុស្សេសុ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី អត្ថិ តត្ថ សុរាមេរយមជ្ជប្បមាទដ្ឋានន្តិ ។ អាមន្តា ។

## សំវរកថា

(៣៨៨) ការវៀរចាកបាណាតិបាត មាន ក្នុងពួកទេវតាឬ ។ អើ ។ ចុះបាណាតិបាត (ការសម្លាប់សត្វ) មាន ក្នុងពួកទេវតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន: (ហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកទឹកស្រវឹងគឺសុរា និងមេរ័យ) មាន ក្នុងពួកទេវតាឬ ។ អើ ។ សុរាមេរយមជ្ជប្បមាទដ្ឋាន: (ហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកទឹកស្រវឹងគឺសុរានិងមេរ័យ) មាន ក្នុងពួកទេវតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៣៨៩) បាណាតិបាត មិនមាន ក្នុងពួកទេវតាទេឬ ។ អើ ។ ការវៀរចាកបាណាតិបាត មិនមាន ក្នុងពួកទេវតាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សុរាមេរយមជ្ជប្បមាទដ្ឋាន: មិនមាន ក្នុងពួកទេវតាទេឬ ។ អើ ។ ការវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន: មិនមាន ក្នុងពួកទេវតាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៣៩០) ការវៀរចាកបាណាតិបាត មាន ក្នុងពួកមនុស្ស ចុះបាណាតិបាត មាន ក្នុងពួកមនុស្សនោះឬ ។ អើ ។ ការវៀរចាកបាណាតិបាត មាន ក្នុងពួកទេវតា ចុះបាណាតិបាត មាន ក្នុងពួកទេវតានោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន: មាន ក្នុងពួកមនុស្ស ចុះសុរាមេរយមជ្ជប្បមាទដ្ឋាន: មាន ក្នុងពួកមនុស្សនោះឬ ។ អើ ។

អត្ថិ ទេវេសុ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី អត្ថិ តត្ថ សុរាមេរយមជ្ជប្បមាទដ្ឋានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៩១) អត្ថិ ទេវេសុ បាណាតិបាតា វេរមណី នត្ថិ តត្ថ បាណាតិបាតោតិ ។ អាមន្តា ។ អត្ថិ មនុស្សេសុ បាណាតិបាតា វេរមណី នត្ថិ តត្ថ បាណាតិបាតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ ទេវេសុ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី នត្ថិ តត្ថ សុរាមេរយមជ្ជប្បមាទដ្ឋានន្តិ ។ អាមន្តា ។ អត្ថិ មនុស្សេសុ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី នត្ថិ តត្ថ សុរាមេរយមជ្ជប្បមាទដ្ឋានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៩២) នត្ថិ ទេវេសុ សំវរោតិ ។ អាមន្តា ។ សព្វេ ទេវា បាណាតិបាតិនោ អទិន្នាទាយិនោ

ការវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋានៈ មាន ក្នុងពួកទេវតា ចុះសុរាមេរយមជ្ជប្បមាទដ្ឋានៈ មាន ក្នុងពួកទេវតានោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៩១] ការវៀរចាកបាណាតិបាត មាន ក្នុងពួកទេវតា ចុះបាណាតិបាត មិនមាន ក្នុងពួកទេវតានោះទេឬ ។ អើ ។ ការវៀរចាកបាណាតិបាត មាន ក្នុងពួកមនុស្ស ចុះបាណាតិបាត មិនមាន ក្នុងពួកមនុស្សនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋានៈ មាន ក្នុងពួកទេវតា ចុះសុរាមេរយមជ្ជប្បមាទដ្ឋានៈ មិនមាន ក្នុងពួកទេវតានោះទេឬ ។ អើ ។ ការវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋានៈ មាន ក្នុងពួកមនុស្ស ចុះសុរាមេរយមជ្ជប្បមាទដ្ឋានៈ មិនមាន ក្នុងពួកមនុស្សនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៩២] ការសង្រួម មិនមាន ក្នុងពួកទេវតាទេឬ ។ អើ ។ ពួកទេវតាទាំងអស់ ជាអ្នកសម្លាប់សត្វ ជាអ្នកកាន់យកទ្រព្យដែលម្ចាស់គេមិនឲ្យ

កាមេសុមិច្ឆាចារោ មុសាវាទោ សុរាមេរយមជ្ជប្ប-
មាទដ្ឋាយិនោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន
ហិ អត្ថិ ទេវេសុ សំវរោតិ ។

សំវរកថា ។

# អសញ្ញកថា

(៣៩៣) អសញ្ញសត្តេសុ សញ្ញា អត្ថីតិ ។ អាមន្តា ។ សញ្ញាភវោ សញ្ញាគតិ សញ្ញាសត្តាវាសោ សញ្ញាសំសារោ សញ្ញាយោនិ សញ្ញត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៩៤) ននុ អសញ្ញភវោ អសញ្ញគតិ អសញ្ញសត្តាវាសោ អសញ្ញសំសារោ អសញ្ញយោនិ អសញ្ញត្តភាវប្បដិលាភោតិ ។ អាមន្តា ។ ហញ្ចិ អសញ្ញភវោ អសញ្ញគតិ អសញ្ញសត្តាវាសោ អសញ្ញសំសារោ អសញ្ញយោនិ អសញ្ញត្តភាវប្បដិលាភោ នោ វត រេ វត្តព្វេ អសញ្ញសត្តេសុ សញ្ញា អត្ថីតិ ។

ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាអ្នកពោលពាក្យកុហក ជាអ្នកប្រព្រឹត្តនូវហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកទឹកស្រវឹងគឺសុរានិងមេរ័យដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ ការសង្រួម មាន ក្នុងពួកទេវតាដែរ ។

ចប់ សំវរកថា ។

# អសញ្ញកថា

(៣៩៣) សញ្ញា ក្នុងពួកអសញ្ញសត្វ (សត្វមិនមានសញ្ញា) មានដែរឬ ។ អើ ។ ភពរបស់សញ្ញសត្វ (សត្វមានសញ្ញា) គតិរបស់សញ្ញសត្វ លំនៅរបស់សញ្ញសត្វ សំសាររបស់សញ្ញសត្វ កំណើតរបស់សញ្ញសត្វ ការបានចំពោះនូវអត្តភាពរបស់សញ្ញសត្វ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៩៤) ក្រែង ភពរបស់អសញ្ញសត្វ គតិរបស់អសញ្ញសត្វ លំនៅរបស់អសញ្ញសត្វ សំសាររបស់អសញ្ញសត្វ កំណើតរបស់អសញ្ញសត្វ ការបានចំពោះនូវអត្តភាពរបស់អសញ្ញសត្វ មានដែរឬ ។ អើ ។ ប្រសិនបើ ភពរបស់អសញ្ញសត្វ គតិរបស់អសញ្ញសត្វ លំនៅរបស់អសញ្ញសត្វ សំសាររបស់អសញ្ញសត្វ កំណើតរបស់អសញ្ញសត្វ ការបានចំពោះនូវអត្តភាពរបស់អសញ្ញសត្វ មានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សញ្ញា ក្នុងពួកអសញ្ញសត្វ មានទេ ។

( ៣៩៥ ) អសញ្ញសត្តេសុ សញ្ញា អត្ថីតិ ។ អាមន្តា ។ បញ្ចវោការភវោ គតិ សត្តាវាសោ សំសារោ យោនិ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៣៩៦ ) ននុ ឯកវោការភវោ គតិ សត្តាវាសោ សំសារោ យោនិ អត្តភាវប្បដិលាភោតិ ។ អាមន្តា ។ ហញ្ចិ ឯកវោការភវោ គតិ សត្តាវាសោ សំសារោ យោនិ អត្តភាវប្បដិលាភោ នោ វត រេ វត្តព្វេ អសញ្ញសត្តេសុ សញ្ញា អត្ថីតិ ។

( ៣៩៧ ) អសញ្ញសត្តេសុ សញ្ញា អត្ថីតិ ។ អាមន្តា ។ តាយ សញ្ញាយ សញ្ញាករណីយំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៣៩៨ ) មនុស្សេសុ សញ្ញា អត្ថិ សោ ច សញ្ញាភវោ សញ្ញាគតិ សញ្ញាសត្តាវាសោ សញ្ញាសំសារោ សញ្ញាយោនិ សញ្ញត្តភាវប្បដិលាភោតិ ។ អាមន្តា ។ អសញ្ញសត្តេសុ សញ្ញា អត្ថិ សោ ច សញ្ញាភវោ សញ្ញាគតិ សញ្ញាសត្តាវាសោ សញ្ញាសំសារោ សញ្ញាយោនិ សញ្ញត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៩៥) សញ្ញា ក្នុងពួកអសញ្ញសត្វ មានដែរឬ ។ អើ ។ បញ្ចវោការភព គតិ សត្តាវាសៈ សំសារ កំណើត ការបានអត្តភាព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៩៦) ក្រែង ឯកវោការភព គតិ សត្តាវាសៈ សំសារ កំណើត ការបានអត្តភាព មានដែរឬ ។ អើ ។ ប្រសិនបើ ឯកវោការភព គតិ សត្តាវាសៈ សំសារ កំណើត ការបានអត្តភាព មានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សញ្ញា ក្នុងពួកអសញ្ញសត្វ មានទេ ។

(៣៩៧) សញ្ញា ក្នុងពួកអសញ្ញសត្វ មានដែរឬ ។ អើ ។ បុគ្គលធ្វើកិច្ចគួរធ្វើដោយសញ្ញា ដោយសញ្ញានោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៩៨) សញ្ញា ក្នុងពួកមនុស្ស មាន ទាំងសញ្ញភពនោះ សញ្ញគតិ (គតិរបស់សត្វមានសញ្ញា) សញ្ញសត្តាវាសៈ សញ្ញសំសារ សញ្ញយោនិ សញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អើ ។ សញ្ញា ក្នុងពួកអសញ្ញសត្វ មាន ទាំងសញ្ញភពនោះ សញ្ញគតិ សញ្ញសត្តាវាសៈ សញ្ញសំសារ សញ្ញយោនិ សញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

## អសញ្ញកថា

[៣៩៩] មនុស្សេសុ សញ្ញា អត្ថិ សោ ច បញ្ចវោការភវោ គតិ សត្តាវាសោ សំសារោ យោនិ អត្តភាវប្បដិលាភោតិ ។ អាមន្តា ។ អសញ្ញសត្តេសុ សញ្ញា អត្ថិ សោ ច បញ្ចវោការភវោ គតិ សត្តាវាសោ សំសារោ យោនិ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤០០] មនុស្សេសុ សញ្ញា អត្ថិ តាយ សញ្ញាយ សញ្ញាករណីយំ ករោតីតិ ។ អាមន្តា ។ អសញ្ញសត្តេសុ សញ្ញា អត្ថិ តាយ សញ្ញាយ សញ្ញាករណីយំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤០១] អសញ្ញសត្តេសុ សញ្ញា អត្ថិ សោ ច អសញ្ញភវោ អសញ្ញគតិ អសញ្ញសត្តាវាសោ អសញ្ញសំសារោ អសញ្ញយោនិ អសញ្ញត្តភាវប្បដិលាភោតិ ។ អាមន្តា ។ មនុស្សេសុ សញ្ញា អត្ថិ សោ ច អសញ្ញភវោ ។ បេ ។ អសញ្ញត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

## អសញ្ញកថា

[ ៥០២ ] បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន កំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគត កំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៥០៣ ] បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីត តែមិនធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះទេឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោបេពោធិញ្ញាណជាបច្ចុប្បន្ន តែមិនធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៥០៤ ] បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីត តែមិនកំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ មិនចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះទេឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន តែមិនកំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ មិនចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៥០៥) អនាគតាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ អាមន្តា ។ បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៥០៦) អនាគតាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ទុក្ខំ បរិជានាតិ ។បេ។ មគ្គំ ភាវេតីតិ ។ អាមន្តា ។ បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ទុក្ខំ បរិជានាតិ ។បេ។ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៥០៧) អតីតាយ ពោធិយា ពុទ្ធោ អនាគតាយ ពោធិយា ពុទ្ធោ បច្ចុប្បន្នាយ ពោធិយា ពុទ្ធោតិ ។ អាមន្តា ។ តីហិ ពោធីហិ ពុទ្ធោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៥០៨) តីហិ ពោធីហិ ពុទ្ធោតិ ។ អាមន្តា ។ សតតំ សមិតំ អព្វោកិណ្ណំ តីហិ ពោធីហិ សមន្នាគតោ សមាហិតោ តិស្សោ ពោធិយោ បច្ចុបដ្ឋិតាតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៩០៥] បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគត តែមិនធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះទេឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន តែមិនធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩០៦] បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគត តែមិនកំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ មិនចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះទេឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន តែមិនកំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ មិនចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩០៧] បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីត ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគត ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្នឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណ ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩០៨] បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណ ៣ ឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ប្រកបដោយពោធិញ្ញាណទាំង ៣ មានចិត្តខ្ជាប់ខ្ជួនទៀងទាត់ មិនរាយមាយ ចុះពោធិញ្ញាណទាំង ៣ តាំងនៅប្រាកដ ។ អ្នកមិនគួរពោលយ៉ាងនេះទេឬ ។ បេ ។

(៨០៩) ន វត្តព្វំ ពោធិយា ពុទ្ធោតិ ។ អាមន្តា ។ ននុ ពោធិប្បដិលាភា ពុទ្ធោតិ ។ អាមន្តា ។ ហញ្ចិ ពោធិប្បដិលាភា ពុទ្ធោ តេន វត រេ វត្តព្វេ ពោធិយា ពុទ្ធោតិ ។

(៨១០) ពោធិប្បដិលាភា ពុទ្ធោតិ ។ ពោធិយា ពុទ្ធោតិ ។ អាមន្តា ។ ពោធិប្បដិលាភា ពោធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ពោធិយា ពុទ្ធោតិកថា ។

## លក្ខណកថា

(៨១១) លក្ខណសមន្នាគតោ ពោធិសត្តោតិ ។ អាមន្តា ។ បទេសលក្ខណេហិ សមន្នាគតោ បទេសពោធិសត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨១២) លក្ខណសមន្នាគតោ ពោធិសត្តោតិ ។ អាមន្តា ។ តិភាគលក្ខណេហិ សមន្នាគតោ តិភាគពោធិសត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨១៣) លក្ខណសមន្នាគតោ ពោធិសត្តោតិ ។ អាមន្តា ។ ឧបឌ្ឍលក្ខណេហិ សមន្នាគតោ ឧបឌ្ឍពោធិសត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[ ៥០៩ ] បុគ្គលមិនគួរនិយាយថា បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណទេឬ ។ អើ ។ ក្រែងបុគ្គល ជាព្រះពុទ្ធ ព្រោះបានចំពោះនូវពោធិញ្ញាណឬ ។ អើ ។ បើបុគ្គល ជាព្រះពុទ្ធ ព្រោះបានចំពោះនូវពោធិញ្ញាណមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណទេ ។

[ ៥១០ ] បុគ្គល ជាព្រះពុទ្ធ ព្រោះបានចំពោះនូវពោធិញ្ញាណឬ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណឬ ។ អើ ។ ការត្រាស់ដឹង ព្រោះការបានចំពោះនូវពោធិញ្ញាណឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ ពោធិយា ពុទ្ធោតិកថា ។

## លក្ខណកថា

[ ៥១១ ] ពោធិសត្វ ប្រកបដោយលក្ខណៈឬ ។ អើ ។ បទេសពោធិសត្វ ប្រកបដោយបទេសលក្ខណៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៥១២ ] ពោធិសត្វ ប្រកបដោយលក្ខណៈឬ ។ អើ ។ តិភាគពោធិសត្វ ប្រកបដោយតិភាគលក្ខណៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៥១៣ ] ពោធិសត្វ ប្រកបដោយលក្ខណៈឬ ។ អើ ។ ឧបឌ្ឍពោធិសត្វប្រកបដោយឧបឌ្ឍលក្ខណៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៥១៤ ) លក្ខណសមន្នាគតោ ពោធិសត្តោតិ ។ អាមន្តា ។ ចក្កវត្តិសត្តោ លក្ខណសមន្នាគតោ ចក្កវត្តិសត្តោ ពោធិសត្តោតិ ។ ន ហេវំ វត្តព្វេ ។បេ ។

( ៥១៥ ) ចក្កវត្តិសត្តោ លក្ខណសមន្នាគតោ ចក្កវត្តិសត្តោ ពោធិសត្តោតិ ។ អាមន្តា ។ យាទិសោ ពោធិសត្តស្ស បុញ្ញយោគោ បុញ្ញចរិយា ធម្មក្ខានំ ធម្មទេសនា តាទិសោ ចក្កវត្តិសត្តស្ស បុញ្ញយោគោ បុញ្ញចរិយា ធម្មក្ខានំ ធម្មទេសនាតិ ។ ន ហេវំ វត្តព្វេ ។បេ ។

( ៥១៦ ) យថា ពោធិសត្តស្ស ជាយមានស្ស ទេវា បឋមំ បដិគ្គណ្ហន្តិ បច្ឆា មនុស្សា ឯវមេវ ចក្កវត្តិសត្តស្ស ជាយមានស្ស ទេវា បឋមំ បដិគ្គណ្ហន្តិ បច្ឆា មនុស្សាតិ ។ ន ហេវំ វត្តព្វេ ។បេ ។

( ៥១៧ ) យថា ពោធិសត្តស្ស ជាយមានស្ស ចត្តារោ ទេវបុត្តា បដិគ្គហេត្វា មាតុ បុរតោ ឋបេន្តិ អត្តមនា ទេវិ ហោហិ មហេសក្ខោ តេ បុត្តោ ឧប្បន្នោតិ ឯវមេវ ចក្កវត្តិសត្តស្ស ជាយមានស្ស ចត្តារោ ទេវបុត្តា បដិគ្គហេត្វា មាតុ បុរតោ ឋបេន្តិ

(៩១៤) ពោធិសត្វ ប្រកបដោយលក្ខណៈឬ ។ អើ ។ ចក្កវត្តិសត្វ ប្រកបដោយលក្ខណៈ ចុះចក្កវត្តិសត្វ ហៅថាពោធិសត្វឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៩១៥) ចក្កវត្តិសត្វ ប្រកបដោយលក្ខណៈ ចុះចក្កវត្តិសត្វ ហៅថាពោធិសត្វឬ ។ អើ ។ បុព្វយោគៈ បុព្វចរិយា ការពោលធម៌ ការសំដែងធម៌ របស់ពោធិសត្វ យ៉ាងណា បុព្វយោគៈ បុព្វចរិយា ការពោលធម៌ ការសំដែងធម៌ របស់ចក្កវត្តិសត្វ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៩១៦) កាលពោធិសត្វប្រសូត ពួកទេវតាទទួលមុន ពួកមនុស្សទទួលក្រោយ យ៉ាងណា កាលចក្កវត្តិសត្វប្រសូត ពួកទេវតាទទួលមុន ពួកមនុស្សទទួលក្រោយ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៩១៧) កាលពោធិសត្វប្រសូត ទេវបុត្រទាំង ៤ ទទួលហើយតម្កល់ទុក ក្នុងទីចំពោះមុខនៃព្រះមាតាថា បពិត្រនាងទេវី ព្រះនាងចូរត្រេកអរចុះ បុត្ររបស់នាង មានស័ក្តិធំ កើតហើយ យ៉ាងណា កាលចក្កវត្តិសត្វប្រសូត ទេវបុត្រទាំង ៤ ទទួលហើយតម្កល់ទុក ក្នុងទីចំពោះមុខនៃព្រះមាតាថា

អត្តមនា ទេវា ហោន្តិ មហាសត្តា តវ បុត្តោ ឧប្បន្នោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៥១៨) យថា ពោធិសត្តស្ស ជាយមានស្ស ទ្វេ ឧទកស្ស ធារា អន្តលិក្ខា បាតុភវន្តិ ឯកា សីតស្ស ឯកា ឧណ្ហស្ស យេន ពោធិសត្តស្ស ឧទកកិច្ចំ ករោន្តិ មាតុ ច ឯវមេវ ចក្កវត្តិសត្តស្ស ជាយមានស្ស ទ្វេ ឧទកស្ស ធារា អន្តលិក្ខា បាតុភវន្តិ ឯកា សីតស្ស ឯកា ឧណ្ហស្ស យេន ចក្កវត្តិសត្តស្ស ឧទកកិច្ចំ ករោន្តិ មាតុ ចាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៥១៩) យថា សម្បតិជាតោ ពោធិសត្តោ សមេហិ បាទេហិ បតិដ្ឋហិត្វា ឧត្តរេន អភិមុខោ សត្តបទវីតិហារេ គច្ឆតិ សេតម្ហិ ឆត្តេ អនុធារិយមានេ សព្វា ច ទិសា វិលោកេតិ អាសភិញ្ច វាចំ ភាសតិ អគ្គោហមស្មិ លោកស្ស ជេដ្ឋោហមស្មិ លោកស្ស សេដ្ឋោហមស្មិ លោកស្ស អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ឯវមេវ សម្បតិជាតោ ចក្កវត្តិសត្តោ

បតិគ្គនាងទេវី ព្រះនាងប្រគេកអរថា បុត្ររបស់នាង មានស័ក្តិធំ កើតហើយ ក៏យ៉ាងនោះដែរឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ៗ បេ ៗ

( ៤១៨ ) ពោធិសត្វប្រសូត ទនៃទឹក ២ គឺទនៃទឹកត្រជាក់ ១ ទនៃទឹកក្តៅ ១ ធ្លាក់មកប្រាកដអំពីអាកាស ធ្វើកិច្ចជម្រះដោយទឹក ចំពោះព្រះពោធិសត្វផង ចំពោះព្រះមាតាផង យ៉ាងណា កាលចក្កវត្តិសត្វប្រសូត ទនៃទឹក ២ គឺទនៃទឹកត្រជាក់ ១ ទនៃទឹកក្តៅ ១ ធ្លាក់មកប្រាកដអំពីអាកាស ធ្វើកិច្ចជម្រះដោយទឹក ចំពោះចក្កវត្តិសត្វផង ចំពោះព្រះមាតាផង ក៏យ៉ាងនោះដែរឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ៗ បេ ៗ

( ៤១៩ ) ព្រះពោធិសត្វប្រសូតមកភ្លាម ជាន់ដោយព្រះបាទដ៏ស្មើ មានមុខបែរទៅរកទិសខាងជើង ឈានទៅ ៧ ជំហាន កាលពួកទេវតាបាំងស្វេតច្ឆត្រ ក៏រមិលមើលសព្វទិស បន្លឺឡើងនូវអាសភិវាចាថា អញជាបុគ្គលធ្លើមរបស់លោក អញជាបុគ្គលច្បងរបស់លោក អញជាបុគ្គលប្រសើររបស់លោក នេះ ជាជាតិទីបំផុត ( របស់អញ ) ឥឡូវនេះ ភពថ្មីទៀត មិនមានឡើយ យ៉ាងណា ចក្កវត្តិសត្វប្រសូតមកភ្លាម

សមេហិ បាទេហិ បតិដ្ឋហិត្វា ឧត្តរេន អភិមុខោ សត្តបទវីតិហារេន គច្ឆតិ សេតម្ហិ ឆត្តេ អនុធារិយមានេ សព្វា ច ទិសា វិលោកេតិ អាសភិញ្ច វាចំ ភាសតិ អគ្គោហមស្មិ លោកស្ស ជេដ្ឋោហមស្មិ លោកស្ស សេដ្ឋោហមស្មិ លោកស្ស អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤២០) យថា ពោធិសត្តស្ស ជាយមានស្ស មហតោ អាលោកស្ស មហតោ ឱភាសស្ស មហតោ ភូមិចាលស្ស បាតុភាវោ ហោតិ ឯវមេវ ចក្កវត្តិសត្តស្ស ជាយមានស្ស មហតោ អាលោកស្ស មហតោ ឱភាសស្ស មហតោ ភូមិចាលស្ស បាតុភាវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤២១) យថា ពោធិសត្តស្ស បកតិកាយោ សមន្តា ព្យាមំ ឱភាសតិ ឯវមេវ ចក្កវត្តិសត្តស្ស បកតិកាយោ សមន្តា ព្យាមំ ឱភាសតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ដាន់ដោយព្រះបាទដ៏ស្មើ មានមុខបែរទៅរកទិសខាងជើង ឈានទៅ ៧ ជំហាន កាលពួកទេវតាបាំងស្វេតច្ឆត្រ ក៏រមិលមើលសព្វទិស បន្លឺឡើងនូវអាសភិវាចាថា អញជាបុគ្គលឆ្នើមរបស់លោក អញជាបុគ្គលច្បងរបស់លោក អញជាបុគ្គលប្រសើររបស់លោក នេះ ជាជាតិទីបំផុត (របស់អញ) ឥឡូវនេះ ភពថ្មីទៀត មិនមានឡើយ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៩២០) កាលព្រះពោធិសត្វប្រសូត ការកើតឡើងប្រាកដ នៃពន្លឺដ៏ធំ នៃរស្មីដ៏ធំ នៃការកម្រើកញាប់ញ័រផែនដីដ៏ខ្លាំង យ៉ាងណា កាលចក្រវត្តិសត្វប្រសូត ការកើតឡើងប្រាកដ នៃពន្លឺដ៏ធំ នៃរស្មីដ៏ធំ នៃការកម្រើកញាប់ញ័រផែនដីដ៏ខ្លាំង ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៩២១) កាយប្រក្រតី របស់ពោធិសត្វ រមែងភ្លឺទៅមួយព្យាម ដោយជុំវិញ យ៉ាងណា កាយប្រក្រតី របស់ចក្រវត្តិសត្វ រមែងភ្លឺទៅមួយព្យាមដោយជុំវិញ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៤២២ ) យថា ពោធិសត្តោ មហាសុបិនំ បស្សិ ឯវមេវ ចក្កវត្តិសត្តោ មហាសុបិនំ បស្សតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៤២៣ ) ន វត្តព្វំ លក្ខណសមន្នាគតោ ពោធិ-សត្តោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ទ្វត្តឹសិមានិ ភិក្ខវេ មហាបុរិសស្ស មហាបុរិសលក្ខណានិ យេហិ សមន្នាគតស្ស មហាបុរិសស្ស ទ្វេវ គតិយោ ភវន្តិ អនញ្ញា សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្ក-វត្តិ ធម្មិកោ ធម្មរាជា ចាតុរន្តោ វិជិតាវី ជនបទត្ថា-វរិយប្បត្តោ សត្តរតនសមន្នាគតោ តស្សិមានិ សត្ត-រតនានិ ភវន្តិ សេយ្យថីទំ ចក្ករតនំ ហត្ថិរតនំ អស្ស-រតនំ មណិរតនំ ឥត្ថិរតនំ គហបតិរតនំ បរិណាយក-រតនមេវ សត្តមំ បរោសហស្សំ ខោ បនស្ស បុត្តា ភវន្តិ សូរា វីរង្គរូបា បរសេនប្បមទ្ទនា សោ ឥមំ បឋវឹ សាគរបរិយន្តំ អទណ្ឌេន អសត្ថេន ធម្មេន អភិវិជិយ អជ្ឈាវសតិ សចេ បន ខោ អគារស្មា អនគារិយំ បព្វជតិ អរហំ ហោតិ សម្មាសម្ពុទ្ធោ

លក្ខណកថា

[ ៥២២ ] ព្រះពោធិសត្វ ឃើញមហាសុបិន យ៉ាងណា ចក្កវត្តិសត្វ ឃើញមហាសុបិន ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

[ ៥២៣ ] បុគ្គលមិនគួរនិយាយថា ព្រះពោធិសត្វ ប្រកបដោយលក្ខណៈទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មហាបុរស ប្រកបដោយមហាបុរិសលក្ខណៈទាំង ៣២ នេះ រមែងមានតែគតិ ២ យ៉ាងប៉ុណ្ណោះ មិនមែនខុសអំពីគតិ ២ យ៉ាងនោះទេ គឺថាបើនៅគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រពត្តិ ជាធម្មរាជ ប្រកបដោយធម៌ ជាឥស្សរៈលើផែនដីដែលមានសមុទ្រទាំង ៤ ជាទីបំផុត ឈ្នះអស់សត្រូវទាំងខាងក្នុងខាងក្រៅ ដល់នូវភាពមាំមួនក្នុងជនបទ ប្រកបដោយកែវទាំង ៧ ប្រការ ឯកែវទាំង ៧ ប្រការ នេះ របស់ស្តេចចក្រពត្តិនោះ គឺចក្រកែវ ១ ដំរីកែវ ១ សេះកែវ ១ មណីកែវ ១ ស្ត្រីកែវ ១ គហបតីកែវ ១ បរិនាយកកែវ ១ ទៀតជាគម្រប់ ៧ ព្រះរាជានោះ មានព្រះរាជបុត្រ ច្រើនជាងពាន់ ដែលជាអ្នកក្លៀវក្លា មានសភាពអង់អាច អាចញាំញីនូវសេនានៃស្តេចដទៃបាន ព្រះរាជានោះ មានជ័យជំនះ នៅគ្រប់គ្រងផែនដីនេះដែលមានសាគរជាទីបំផុត ដោយធម៌ ដោយមិនមានគ្រឿងភ័យដំ ដោយមិនមានគ្រឿងកាប់ចាក់ បើចេញចាកផ្ទះចូលទៅកាន់ផ្នួស វិញ នឹងបានជាអរហន្តសម្មាសម្ពុទ្ធ មាន

លោកេ វិវដច្ឆទោតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ លក្ខណាសមន្នាគតោ ពោធិសត្តោតិ ។

លក្ខណកថា ។

# និយាមោក្កន្តិកថា

(៥២៤) ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោតិ ។ អាមន្តា ។ ពោធិសត្តោ កស្សបស្ស ភគវតោ សាវកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៥២៥) ពោធិសត្តោ កស្សបស្ស ភគវតោ សាវកោតិ ។ អាមន្តា ។ សាវកោ ហុត្វា ពុទ្ធោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៥២៦) សាវកោ ហុត្វា ពុទ្ធោ ហោតីតិ ។ អាមន្តា ។ អនុស្សវិយោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ដំបូលគឺកិលេសបើកហើយ ក្នុងលោក ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ឬ ។ អើ ។ ព្រោះហេតុនោះ ព្រះពោធិសត្វ ប្រកបដោយលក្ខណៈ (ដោយពិត) ។

ចប់ លក្ខណកថា ។

# និយាមោក្កន្តិកថា

[ ៤២៤ ] ព្រះពោធិសត្វ(១) មាននិយាមៈ(២) យាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបឬ ។ អើ ។ ព្រះពោធិសត្វ ជាសាវ័ក នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៤២៥ ] ព្រះពោធិសត្វ ជាសាវ័ក នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបឬ ។ អើ ។ (ព្រះពោធិសត្វ) បានជាសាវ័កហើយ ទើបបានត្រាស់ជាព្រះពុទ្ធឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៤២៦ ] (ព្រះពោធិសត្វ) បានជាសាវ័កហើយ ទើបបានត្រាស់ជាព្រះពុទ្ធឬ ។ អើ ។ (បុគ្គលជាព្រះពុទ្ធ) ប្រកបដោយការស្តាប់តាមគេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

១ សំដៅយកពោធិសត្វ កាលកើតជាជោតិបាល បានបួសក្នុងសំណាក់ព្រះកស្សបមានព្រះភាគ ។ ២ ជាឈ្មោះនៃអរិយមគ្គ ។

## និយាមោក្កន្តិកថា

[៥២៧] អនុស្សវិយោតិ(១) ។ អាមន្តា ។ ននុ ភគវា សយម្ភូតិ ។ អាមន្តា ។ ហញ្ចិ ភគវា សយម្ភូ តេន វត រេ វត្តព្វេ អនុស្សវិយោតិ ។

[៥២៨] ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោតិ ។ អាមន្តា ។ ភគវា ពោធិយា មូលេ តីណិ សាមញ្ញផលានិ អភិសម្ពុជ្ឈីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៥២៩] ននុ ភគវា ពោធិយា មូលេ ចត្តារិ សាមញ្ញផលានិ អភិសម្ពុជ្ឈីតិ ។ អាមន្តា ។ ហញ្ចិ ភគវា ពោធិយា មូលេ ចត្តារិ សាមញ្ញផលានិ អភិសម្ពុជ្ឈិ តេន វត រេ វត្តព្វេ ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោតិ ។

[៥៣០] ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោតិ ។ អាមន្តា ។ ពោធិសត្តោ ទុក្ករការិកំ អកាសីតិ ។

---

១ អដ្ឋកថាយំ អនុស្សវិកោតិ ទិស្សតិ ។

( ៩២៧ ) ( បុគ្គលជាព្រះពុទ្ធ ) ប្រកបដោយការស្តាប់តាមគេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ជាអ្នកត្រាស់ដឹងដោយព្រះអង្គឯងឬ ។ អើ ។ បើព្រះមានព្រះភាគ ជាអ្នកត្រាស់ដឹងដោយព្រះអង្គឯង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ( បុគ្គលជាព្រះពុទ្ធ ) ប្រកបដោយការស្តាប់តាមគេទេ ។

( ៩២៨ ) ព្រះពោធិសត្វ មាននិយាមៈយានចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបដែរឬ ។ អើ ។ សាមញ្ញផល ៣ គឺព្រះមានព្រះភាគបានត្រាស់ដឹង ទៀបគល់នៃពោធិព្រឹក្សឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៩២៩ ) ក្រែងសាមញ្ញផល ៤ គឺព្រះមានព្រះភាគបានត្រាស់ដឹង ទៀបគល់នៃពោធិព្រឹក្សឬ ។ អើ ។ បើសាមញ្ញផល ៤ គឺព្រះមានព្រះភាគបានត្រាស់ដឹង ទៀបគល់នៃពោធិព្រឹក្សមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះពោធិសត្វ មាននិយាមៈយានចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបទេ ។

( ៩៣០ ) ព្រះពោធិសត្វ មាននិយាមៈយានចុះហើយ មានព្រហ្មចរិយ ប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបឬ ។ អើ ។ ព្រះពោធិសត្វ បានធ្វើទុក្ករកិរិយាដែរឬ ។

អាមន្តា ។ ឧបសម្បន្នោ បុគ្គលោ ឧត្តរំ ការិយំ ការេយ្យាតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៨៣១) ពោធិសត្តោ អបរទ្ធំ អកាសិ អញ្ញំ សត្ថារំ ឧទ្ទិសីតិ ។ អាមន្តា ។ ឧបសម្បន្នោ បុគ្គលោ អញ្ញំ សត្ថារំ ឧទ្ទិសេយ្យាតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៨៣២) អាយស្មា អានន្ទោ ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោ អាយស្មា អានន្ទោ ភគវតោ សាវកោតិ ។ អាមន្តា ។ ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោ ពោធិសត្តោ កស្សបស្ស ភគវតោ សាវកោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៨៣៣) ចិត្តោ គហបតិ ហត្ថកោ អាឡវកោ ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោ ចិត្តោ គហបតិ ហត្ថកោ អាឡវកោ ភគវតោ

អើ ។ បុគ្គល បរិបូណ៌ដោយទស្សនៈ គប្បីធ្វើទុកក្រិយាដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៤៣១ ] ព្រះពោធិសត្វ បានធ្វើអំពើដែលមិនញុំាងបុគ្គលដទៃឲ្យក្តៅក្រហាយ ហើយឧទ្ទិស ចំពោះសាស្តាដទៃដែរឬ ។ អើ ។ បុគ្គល បរិបូណ៌ដោយទស្សនៈ គប្បីឧទ្ទិស ចំពោះសាស្តាដទៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៤៣២ ] ព្រះអានន្ទមានអាយុ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ព្រះអានន្ទមានអាយុ ជាសាវ័ក នៃព្រះមានព្រះភាគដែរឬ ។ អើ ។ ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សប ព្រះពោធិសត្វ ជាសាវ័ក នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៤៣៣ ] ឧបាសកឈ្មោះចិត្តគហបតី និងហត្ថកាឡវកៈ មាននិយាមៈចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ឧបាសកឈ្មោះចិត្តគហបតី និងហត្ថកាឡវកៈ ជាសាវ័ក

សាវកោតិ ។ អាមន្តា ។ ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោ ពោធិសត្តោ កស្សបស្ស ភគវតោ សាវកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៥៣៤) ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោ ន ច កស្សបស្ស ភគវតោ សាវកោតិ ។ អាមន្តា ។ អា-យស្មា អានន្ទោ ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោ ន ច ភគវតោ សាវកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៥៣៥) ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោ ន ច កស្សបស្ស ភគវតោ សាវកោតិ ។ អាមន្តា ។ ចិត្តោ គហបតិ ហត្ថកោ អាឡវកោ ភគវតោ បា-វចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោ ន ច ភគវតោ សាវកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

នៃព្រះមានព្រះភាគដែរឬ ។ អើ ។ ព្រះពោធិសត្វ មាននិយាមៈយាន៍ចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគទ្រង់ព្រះនាមកស្សប ព្រះពោធិសត្វ ជាសាវ័ក នៃព្រះមានព្រះភាគទ្រង់ព្រះនាមកស្សបដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

( ៩៣៨ ) ព្រះពោធិសត្វ មាននិយាមៈយាន៍ចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សប តែមិនមែនជាសាវ័ក នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបទេឬ ។ អើ ។ ព្រះអានន្ទមានអាយុ មាននិយាមៈយាន៍ចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ តែមិនមែនជាសាវ័ក នៃព្រះមានព្រះភាគទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

( ៩៣៩ ) ព្រះពោធិសត្វ មាននិយាមៈយាន៍ចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សប តែមិនមែនជាសាវ័ក នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបទេឬ ។ អើ ។ ឧបាសកឈ្មោះចិត្តគហបតី និងហត្ថកាឡវកៈ មាននិយាមៈចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ តែមិនមែនជាសាវ័ក នៃព្រះមានព្រះភាគទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[៨៣៦] ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោ ន ច កស្សបស្ស ភគវតោ សាវកោតិ ។ អាមន្តា ។ សាវកោ ជាតឹ វីតិវត្តោ អសាវកោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៨៣៧] ន វត្តព្វំ ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា កស្សបេ អហំ អានន្ទ ភគវតិ ព្រហ្មចរិយំ អចរឹ អាយតឹ សម្ពោធាយាតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោតិ ។

[៨៣៨] ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

[ ៩៣៦ ] ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សប តែមិនមែនជាសាវ័ក នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបទេឬ ។ អើ ។ សាវ័ក ដែលប្រព្រឹត្តកន្លងនូវជាតិហើយ មិនមែនជាសាវ័កទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៣៧ ] បុគ្គលមិនគួរនិយាយថា ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអានន្ទ តថាគត បានប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សប ដើម្បីត្រាស់ដឹងតទៅ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបដែរ ។

[ ៩៣៨ ] ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

និយាមោក្ខត្ថិកថា

សព្វាភិភូ សព្វវិទូហមស្មិ

សព្វេសុ ធម្មេសុ អនូបលិត្តោ

សព្វញ្ជហោ តណ្ហក្ខយេ វិមុត្តោ

សយំ អភិញ្ញាយ កមុទ្ទិសេយ្យំ

ន មេ អាចរិយោ អត្ថិ សទិសោ មេ ន វិជ្ជតិ

សទេវកស្មឹ លោកស្មឹ នត្ថិ មេ បដិបុគ្គលោ

អហំ ហិ អរហា លោកេ អហំ សត្ថា អនុត្តរោ

ឯកោម្ហិ សម្មាសម្ពុទ្ធោ សីតិភូតោស្មិ និព្វុតោ

ធម្មចក្កំ បវត្តេតុំ គច្ឆាមិ កាសិនំ បុរំ

អន្ធភូតស្មឹ លោកស្មឹ អាហញ្ឆឹ អមតទុន្ទុភិន្តិ

យថា ខោ ត្វំ អាវុសោ បដិជានាសិ អរហាសិ

អនន្តជិនោតិ

## និយាមោក្កត្តិកថា

តថាគត ជាអ្នកគ្របសង្កត់នូវតេភូមិកធម៌ទាំងអស់ ត្រាស់ដឹងនូវចតុភូមិកធម៌ទាំងអស់ មិនប្រឡាក់ដោយកិលេសក្នុងតេភូមិកធម៌ទាំងអស់ទេ លះចោលនូវតេភូមិកធម៌ទាំងអស់ហើយ មានចិត្តរួចស្រឡះហើយ ព្រោះការអស់ទៅនៃតណ្ហា ដឹងច្បាស់នូវចតុភូមិកធម៌ ដោយខ្លួនឯង (ចាំបាច់) ឧទ្ទិសបុគ្គលណា តថាគត មិនមានអាចារ្យទេ បុគ្គលដទៃស្មើនឹងតថាគតមិនមានឡើយ ក្នុងលោក ព្រមទាំងទេវ-លោក មិនមានបុគ្គលប្រៀបផ្ទឹមនឹងតថាគតបានឡើយ ព្រោះថា តថាគត ជាអរហន្តក្នុងលោក តថាគត ជាសាស្តាខ្ពស់បំផុត តថាគត ជាសម្មាសម្ពុទ្ធឯក មានសេចក្តីត្រជាក់ មានភ្លើងកិលេសរលត់ហើយ ឥឡូវនេះ តថាគត ទៅកាន់បុរីនៃពួកជនអ្នកកាសី ដើម្បីសំដែងធម្មចក្រ (ដោយបំណងថា) តថាគត នឹងទួងស្គរគឺអមតនិព្វាន ចំពោះសត្វលោកដែលងងឹតគឺអវិជ្ជាកំពុងគ្របសង្កត់

(ឧបកាជីវកតបថា) ម្នាលអាវុសោ អ្នកប្តេជ្ញាខ្លួនអ្នក ថាយ៉ាងណាអ្នក (គួរដើម្បីបាននូវឈ្មោះ) ថាអនន្តជិនៈ យ៉ាងនោះឯង (ព្រះសម្មា-សម្ពុទ្ធ ទ្រង់ត្រាស់ទៀតថា)

មាទិសា វេ ជិនា ហោន្តិ យេ បត្តា អាសវក្ខយំ

ជិតា មេ បាបកា ធម្មា តស្មាហំ ឧបក ជិនោតិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោតិ ។

(៨៣៩) ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ឥទំ ទុក្ខំ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ តំ ខោ បនិទំ ទុក្ខំ អរិយសច្ចំ បរិញ្ញេយ្យន្តិ មេ ភិក្ខវេ ។បេ។

ជនទាំងឡាយណា បានដល់នូវការអស់ទៅនៃអាសវៈ ជនទាំងឡាយនោះ ឈ្មោះថាជិនៈ (អ្នកឈ្នះកិលេស) ប្រាកដដូចជាតថាគតដែរ តថាគត បានឈ្នះបាបធម៌ទាំងឡាយហើយ ម្នាលឧបកៈ ព្រោះហេតុនោះ ទើបតថាគត បាននូវឈ្មោះថាជិនៈ (អ្នកឈ្នះបាបធម៌)

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបទេ ។

(៤៣៩) ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនធ្លាប់បានឮក្នុងកាលពីមុនមកថា នេះ ជាទុក្ខអរិយសច្ច ដូច្នេះឡើយ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគតថា នោះឯង ជាទុក្ខអរិយសច្ច ដែលបុគ្គលគួរកំណត់ដឹង

## និយាមោក្កន្តិកថា

បរិញ្ញាតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ ឥទំ ទុក្ខសមុទយោ អរិយសច្ចន្តិ មេ ភិក្ខវេ ។ បេ ។ តំ ខោ បនិទំ ទុក្ខសមុទយោ អរិយសច្ចំ បហាតព្វន្តិ មេ ភិក្ខវេ ។ បេ ។ បហីនន្តិ មេ ភិក្ខវេ ។ បេ ។ ឥទំ ទុក្ខនិរោធោ អរិយសច្ចន្តិ មេ ភិក្ខវេ ។ បេ ។ តំ ខោ បនិទំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកាតព្វន្តិ មេ ភិក្ខវេ ។ បេ ។ សច្ឆិកតន្តិ មេ ភិក្ខវេ ។ បេ ។ ឥទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចន្តិ មេ ភិក្ខវេ ។ បេ ។ តំ ខោ បនិទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ភាវេតព្វន្តិ មេ ភិក្ខវេ ។ បេ ។

និយាមោក្កន្តិកថា

ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ។បេ។ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនធ្លាប់បានឮក្នុងកាលពីមុនមកថា ទុក្ខនោះឯង ដែលតថាគតបានកំណត់ដឹងហើយ ម្នាលភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា នេះ ជាទុក្ខសមុទយ-អរិយសច្ច ដូច្នេះឡើយ ម្នាលភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា នោះឯង ជាទុក្ខសមុទយអរិយសច្ច ដែលបុគ្គលគួរលះចោល ម្នាលភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា នោះឯង ជាទុក្ខ-សមុទយអរិសច្ច ដែលតថាគតបានលះចោលហើយ ម្នាលភិក្ខុទាំង-ឡាយ ។បេ។ ដល់តថាគតថា នេះ ជាទុក្ខនិរោធអរិយសច្ច ដូច្នេះឡើយ ម្នាលភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា នោះឯង ជាទុក្ខនិរោធអរិយសច្ច ដែលបុគ្គលគួរធ្វើឲ្យជាក់ច្បាស់ ម្នាលភិក្ខុទាំង-ឡាយ ។បេ។ ដល់តថាគតថា នោះឯង ជាទុក្ខនិរោធអរិយសច្ច ដែលតថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា នេះ ជាទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ដូច្នេះឡើយ ម្នាលភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា នោះឯង ជាទុក្ខនិរោធ-គាមិនីបដិបទាអរិយសច្ច ដែលបុគ្គលគួរចម្រើន ម្នាលភិក្ខុទាំងឡាយ

ភាវិតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទីតិ អត្ថេវ សុត្ត-ន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ ពោធិសត្តោ-កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិ-តព្រហ្មចរិយោតិ ។

និយាមោក្កន្តិកថា ។

## អបរាបិ សមន្នាគតកថា

(៥៤០) អហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ តីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ចតូហិ ផស្សេហិ ចតូហិ វេទនាហិ ចតូហិ សញ្ញាហិ ចតូហិ ចេតនាហិ ចតូហិ ចិត្តេហិ ចតូហិ សទ្ធាហិ ចតូហិ វីរិយេហិ ចតូហិ សតីហិ ចតូហិ សមាធីហិ ចតូហិ បញ្ញាហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនធ្លាប់បានឮក្នុងកាលពីមុនមកថា នេះឯង ជាទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ដែលតថាគតបានចម្រើនហើយ ពាក្យដូច្នេះមានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបទេ ។

ចប់ និយាមោក្កន្តិកថា ។

## អបរាបិ សមន្នាគតកថា

(៨៤០) បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយផល ៣ ឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយផស្សៈ ៤ ដោយវេទនា ៤ ដោយសញ្ញា ៤ ដោយចេតនា ៤ ដោយចិត្ត ៤ ដោយសទ្ធា ៤ ដោយវីរិយៈ ៤ ដោយសតិ ៤ ដោយសមាធិ ៤ ដោយបញ្ញា ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

អបរាបិ សមន្នាគតកថា

( ៥៦១ ) អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ទ្វីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ តីហិ ផស្សេហិ តីហិ វេទនាហិ ។ បេ ។ តីហិ បញ្ញាហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៥៦២ ) សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ទ្វីហិ ផស្សេហិ ទ្វីហិ វេទនាហិ ។ បេ ។ ទ្វីហិ បញ្ញាហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៥៦៣ ) អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបន្នោ សត្តក្ខត្តុំបរមោ កោលំកោលោ ឯកពីជីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៩៤១) បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយផល ២ ឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយផស្សៈ ៣ ដោយវេទនា ៣ ។ បេ ។ ដោយបញ្ញា ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៩៤២) បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកបដោយផស្សៈ ២ ដោយវេទនា ២ ។ បេ ។ ដោយបញ្ញា ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៩៤៣) បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គល ជាសោតាបន្នៈ គឺសត្តក្ខត្តុំបរមៈ កោលំកោលៈ ឯកពីជី ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៥៤៤ ) អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៥៤៥ ) អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ អនាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ អនាគាមី អន្តរាបរិនិព្វាយី ឧបហច្ចបរិនិព្វាយី អសង្ខារបរិនិព្វាយី សសង្ខារបរិនិព្វាយី ឧទ្ធំសោតោ អកនិដ្ឋគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៥៤៦ ) អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបន្នោ សត្តក្ខត្តុំបរមោ កោលំកោលោ ឯកពីជីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៥៤៧ ) អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។

( ៥៤៤ ) បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសកទាគាមិផលឬ ។ អើ ។ សកទាគាមិបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៥៤៥ ) បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយអនាគាមិផលឬ ។ អើ ។ បុគ្គល ជាអនាគាមី គឺអន្តរាបរិនិព្វាយី ឧបហច្ចបរិនិព្វាយី អសង្ខារបរិនិព្វាយី សសង្ខារបរិនិព្វាយី ឧទ្ធំសោតៈ អកនិដ្ឋគាមី ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៥៤៦ ) បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គល ជាសោតាបន្នៈ គឺសត្តក្ខត្តុបរមៈ កោលំកោលៈ ឯកពីជី ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៥៤៧ ) បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយសកទាគាមិផលឬ ។ អើ ។

អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៤៨) សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបន្នោ សត្តក្ខត្តុំបរមោ កោលំកោលោ ឯកពីជីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៤៩) សោតាបត្តិផលេន សមន្នាគតោ សោតាបន្នោតិ វត្តព្វោតិ ។ អាមន្តា ។ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេវ អរហត្តសច្ឆិកិរិយាយ បដិបន្នោ សោ សោតាបន្នោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៥០) សកទាគាមិផលេន សមន្នាគតោ សកទាគាមីតិ វត្តព្វោតិ ។ អាមន្តា ។ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេវ អរហត្តសច្ឆិកិរិយាយ បដិបន្នោ សោ សកទាគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

សកទាគាមិបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤២៨) បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គលជាសោតាបន្នៈ គឺសត្តក្ខត្តុំបរមៈ កោលំកោលៈ ឯកពីជី ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤២៩) គួរនិយាយថា សោតាបន្នបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តនោះឯង គឺសោតាបន្នបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(២៥០) គួរនិយាយថា សកទាគាមិបុគ្គល ប្រកបដោយសកទាគាមិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសកទាគាមិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តនោះឯង គឺសកទាគាមិបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៥៥១) អនាគាមិផលេន សមន្នាគតោ អនាគាមីតិ វត្តព្វោតិ ។ អាមន្តា ។ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ អនាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេវ អរហត្តសច្ឆិកិរិយាយ បដិបន្នោ សោ អនាគាមីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៥៥២) សោតាបត្តិផលេន សមន្នាគតោ សោតាបន្នោតិ វត្តព្វោតិ ។ អាមន្តា ។ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេវ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ សោ សោតាបន្នោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៥៥៣) សកទាគាមិផលេន សមន្នាគតោ សកទាគាមីតិ វត្តព្វោតិ ។ អាមន្តា ។ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេវ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ សោ សកទាគាមីតិ ។ ន ហេវំ វត្តព្វេ ។បេ។

( ៥៥១ ) គួរនិយាយថា អនាគាមិបុគ្គល ប្រកបដោយអនាគាមិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយអនាគាមិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តនោះឯង គឺអនាគាមិបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៥៥២ ) គួរនិយាយថា សោតាបន្នបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលនោះឯង គឺសោតាបន្នបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៥៥៣ ) គួរនិយាយថា សកទាគាមិបុគ្គល ប្រកបដោយសកទាគាមិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយសកទាគាមិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលនោះឯង គឺសកទាគាមិបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៥៥៤) សោតាបត្តិផលេន សមន្នាគតោ សោតាបន្នោតិ វត្តព្វោតិ ។ អាមន្តា ។ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេវ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ សោ សោតាបន្នោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៥៥៥) អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ននុ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលំ វីតិវត្តោ នោ វត រេ វត្តព្វេ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។

(៥៥៦) អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិមគ្គំ វីតិវត្តោ សក្កាយទិដ្ឋឹ វិចិកិច្ឆំ

អបរាបិ សមន្នាគតកថា

( ៥៥៤ ) គួរនិយាយថា សោតាបន្នបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផលនោះឯង គឺសោតាបន្នបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៥៥៥ ) បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ក្រែងបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយឬ ។ អើ ។ បើ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសោតាបត្តិផលទេ ។

( ៥៥៦ ) បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ប្រកបដោយសោតាបត្តិផលនោះឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិមគ្គ ប្រព្រឹត្តកន្លង នូវសក្កាយទិដ្ឋិ នូវវិចិកិច្ឆា

សីលព្វតុបាទានំ អបាយគមនិយំ រាគំ អបាយគមនិយំ ទោសំ អបាយគមនិយំ មោហំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៥៥៧) អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ ននុ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិផលំ វីតិវត្តោ នោ ច វត រេ វត្តព្វេ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិផលេន សមន្នាគតោតិ ។

(៥៥៨) អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិមគ្គំ វីតិវត្តោ ឱឡារិកំ កាមរាគំ ឱឡារិកំ ព្យាបាទំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។បេ។

នូវសីលព្វតបរាមាសៈ នូវរាគៈ ជាដំណើរទៅកាន់អបាយ នូវទោសៈជាដំណើរទៅកាន់អបាយ នូវមោហៈជាដំណើរទៅកាន់អបាយ ហើយប្រកបដោយសោតាបត្តិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៥៥៧ ] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសកទាគាមិផលឬ ។ អើ ។ ក្រែងបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយឬ ។ អើ ។ បើបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសកទា-គាមិផលទេ ។

[ ៥៥៨ ] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយ ប្រកបដោយសកទាគាមិផលនោះឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសកទាគាមិមគ្គ ប្រព្រឹត្តកន្លងនូវកាមរាគៈដ៏គ្រោតគ្រាត នូវព្យា-បាទដ៏គ្រោតគ្រាត ហើយប្រកបដោយសកទាគាមិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៥៩) អរហត្តសច្ចិកិរិយាយ បដិបន្នោ បុគ្គលោ អនាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ ននុ អរហត្តសច្ចិកិរិយាយ បដិបន្នោ បុគ្គលោ អនាគាមិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អរហត្តសច្ចិកិរិយាយ បដិបន្នោ បុគ្គលោ អនាគាមិផលំ វីតិវត្តោ នោ វត រេ វត្តព្វេ អរហត្តសច្ចិកិរិយាយ បដិបន្នោ បុគ្គលោ អនាគាមិផលេន សមន្នាគតោតិ ។

(៤៦០) អរហត្តសច្ចិកិរិយាយ បដិបន្នោ បុគ្គលោ អនាគាមិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ អរហត្តសច្ចិកិរិយាយ បដិបន្នោ បុគ្គលោ អនាគាមិមគ្គំ វីតិវត្តោ អណុសហគតំ កាមរាគំ អណុសហគតំ ព្យាបាទំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៦១) អនាគាមិផលសច្ចិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ននុ អនាគាមិផលសច្ចិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អនាគាមិផលសច្ចិកិរិយាយ បដិបន្នោ បុគ្គលោ

( ៩៥៩ ) បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយអនាគាមិផលឬ ។ អើ ។ ក្រែងបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវអនាគាមិផលហើយឬ ។ អើ ។ បើបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវអនាគាមិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយអនាគាមិផលទេ ។

( ៩៦០ ) បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវអនាគាមិផល ហើយប្រកបដោយអនាគាមិផលនោះឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវអនាគាមិមគ្គ ប្រព្រឹត្តកន្លងនូវកាមរាគៈដ៏ស្រាលស្តើង នូវព្យាបាទដ៏ស្រាលស្តើង ហើយប្រកបដោយអនាគាមិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៩៦១ ) បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ក្រែងបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយឬ ។ អើ ។ បើបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល

សោតាបត្តិផលំ វីតិវត្តោ តេ វត រេ វត្តព្វេ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។

(៥៦២) អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិមគ្គំ វីតិវត្តោ សក្កាយទិដ្ឋឹ ។ បេ ។ អបាយគមនិយំ មោហំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៥៦៣) អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ ននុ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិផលំ វីតិវត្តោ តេ វត រេ វត្តព្វេ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិផលេន សមន្នាគតោតិ ។

ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោល ថា បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកប ដោយសោតាបត្តិផលទេ ។

( ៩៦៤ ) បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិ-ផល ប្រព្រឹត្តកន្លងនូវសោតាបត្តិផល ហើយប្រកបដោយសោតាបត្តិ-ផលនោះឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអ-នាគាមិផល ប្រព្រឹត្តកន្លងនូវសោតាបត្តិមគ្គ ប្រព្រឹត្តកន្លងនូវសក្កាយទិដ្ឋិ ។ បេ ។ នូវមោហៈជាដំណើរទៅកាន់អបាយ ហើយប្រកបដោយសោតា-បត្តិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៩៦៣ ) បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិ-ផល ប្រកបដោយសកទាគាមិផលឬ ។ អើ ។ ក្រែងបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រព្រឹត្តកន្លងនូវសកទាគាមិផល ហើយឬ ។ អើ ។ បើបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវ អនាគាមិផល ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិ-ផល ប្រកបដោយសកទាគាមិផលទេ ។

អបរាបិ សមន្នាគតកថា

[៥៦៤] អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិមគ្គំ វីតិវត្តោ ឱឡារិកំ កាមរាគំ ឱឡារិកំ ព្យាបាទំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៥៦៥] សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ននុ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលំ វីតិវត្តោ នោ វត រេ វត្តព្វេ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។

[៥៦៦] សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិមគ្គំ វីតិវត្តោ សក្កាយទិដ្ឋឹ

(៤៦៤) បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រព្រឹត្តកន្លងនូវសកទាគាមិផល ហើយប្រកបដោយសកទាគាមិផលនោះឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រព្រឹត្តកន្លងនូវសកទាគាមិមគ្គ ប្រព្រឹត្តកន្លងនូវកាមរាគៈដ៏គ្រោតគ្រាត នូវព្យាបាទដ៏គ្រោតគ្រាត ហើយប្រកបដោយសកទាគាមិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៦៥) បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ក្រែងបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រព្រឹត្តកន្លងនូវសោតាបត្តិផល ហើយឬ ។ អើ ។ បើបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកបដោយសោតាបត្តិផលទេ ។

(៤៦៦) បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រព្រឹត្តកន្លងនូវសោតាបត្តិផល ហើយប្រកបដោយសោតាបត្តិផលនោះឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រព្រឹត្តកន្លងនូវសោតាបត្តិមគ្គ ប្រព្រឹត្តកន្លងនូវសក្កាយទិដ្ឋិ

។ បេ ។ អបាយគមនិយំ មោហំ វីតិវេត្វា តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៥៦៧] ន វត្តព្វំ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ តីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ ននុ អរហត្តសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន តីណិ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អាមន្តា ។ ហញ្ចិ អរហត្តសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន តីណិ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោ តេន វត រេ វត្តព្វេ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ តីហិ ផលេហិ សមន្នាគតោតិ ។

[៥៦៨] ន វត្តព្វំ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ទ្វីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ ននុ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន ទ្វេ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អាមន្តា ។ ហញ្ចិ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន ទ្វេ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោ តេន វត រេ វត្តព្វេ

ៗ បេ ៗ នូវមោហៈជាដំណើរទៅកាន់អបាយ ហើយប្រកបដោយសោតាបត្តិមគ្គនោះឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ៗ បេ ៗ

( ៩៦៧ ) បុគ្គលមិនគួរនិយាយថា បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយផល ៣ ទេឬ ៗ អើ ៗ ក្រែងបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត បានបំពោះ នូវផលទាំង ៣ ហើយ មិនសាបសូន្យ ចាកផលទាំង ៣ នោះទេឬ ៗ អើ ៗ បើបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត បានបំពោះ នូវផលទាំង ៣ ហើយ មិនសាបសូន្យ ចាកផលទាំង ៣ នោះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយផល ៣ មែន ៗ

( ៩៦៨ ) បុគ្គលមិនគួរនិយាយថា បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយផល ២ ទេឬ ៗ អើ ៗ ក្រែងបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល បានបំពោះ នូវផលទាំង ២ ហើយ មិនសាបសូន្យ ចាកផលទាំង ២ នោះទេឬ ៗ អើ ៗ បើបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល បានបំពោះ នូវផលទាំង ២ ហើយ មិនសាបសូន្យ ចាកផលទាំង ២ នោះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា

អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ទ្វីហិ ផលេហិ សមន្នាគតោតិ ។

[៨៦៩] ន វត្តព្វំ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ននុ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន សោតាបត្តិផលំ បដិលទ្ធំ តេន ច អបរិហីនោតិ ។ អាមន្តា ។ ហញ្ចិ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន សោតាបត្តិផលំ បដិលទ្ធំ តេន ច អបរិហីនោ តេន វត រេ វត្តព្វេ សកទាគាមិផលសច្ឆិកិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។

[៨៧០] អរហត្តសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន តីណិ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ តីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ អរហត្តសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន ចត្តារោ មគ្គា បដិលទ្ធា តេហិ ច អបរិហីនោតិ ។

បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយផល ២ មែន ។

(៥៦៩) បុគ្គលមិនគួរនិយាយថា បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកបដោយសោតាបត្តិផលទេឬ ។ អើ ។ ក្រែងបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល បានចំពោះ នូវសោតាបត្តិផលហើយ មិនសាបសូន្យ ចាកសោតាបត្តិផលនោះទេឬ ។ អើ ។ បើបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល បានចំពោះ នូវសោតាបត្តិផលហើយ មិនសាបសូន្យចាកសោតាបត្តិផលនោះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកបដោយសោតាបត្តិផលដែរ ។

(៥៧០) បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត បានចំពោះ នូវផល ៣ ហើយ មិនសាបសូន្យ ចាកផលទាំង ៣ នោះទេឬ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយផលទាំង ៣ ឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត បានចំពោះ នូវមគ្គ ៤ ហើយ មិនសាបសូន្យ ចាកមគ្គទាំង ៤ នោះទេឬ ។

អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ចតូហិ មគ្គេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៧១) អនាគាមិផលសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន ទ្វេ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ទ្វីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន តយោ មគ្គា បដិលទ្ធា តេហិ ច អបរិហីនោតិ ។ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ តីហិ មគ្គេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៧២) សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន សោតាបត្តិផលំ បដិលទ្ធំ តេន ច អបរិហីនោតិ ។ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន ទ្វេ មគ្គា បដិលទ្ធា តេហិ ច អបរិហីនោតិ ។

បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយមគ្គទាំង ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៧១] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល បានបំពោះ នូវផល ២ ហើយ មិនសាបសូន្យ ចាកផលទាំង ២ នោះទេឬ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយផលទាំង ២ ឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល បានបំពោះ នូវមគ្គ ៣ ហើយ មិនសាបសូន្យ ចាកមគ្គទាំង ៣ នោះទេឬ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយមគ្គទាំង ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៧២] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល បានបំពោះ នូវសោតាបត្តិផលហើយ មិនសាបសូន្យ ចាកសោតាបត្តិផលនោះទេឬ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល បានបំពោះ នូវមគ្គ ២ ហើយ មិនសាបសូន្យ ចាកមគ្គទាំង ២ នោះទេឬ ។

សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ទ្វីហិ មគ្គេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អបរាបិ សមន្នាគតកថា ។

## សព្វសញ្ញោជនប្បហានកថា

( ៥៧៣ ) សព្វសញ្ញោជនានំ បហានំ អរហត្តន្តិ ។ អាមន្តា ។ អរហត្តមគ្គេន សព្វេ សញ្ញោជនា បហីយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៥៧៤ ) អរហត្តមគ្គេន សព្វេ សញ្ញោជនា បហីយន្តិ ។ អាមន្តា ។ អរហត្តមគ្គេន សក្កាយទិដ្ឋឹ វិចិកិច្ឆំ សីលព្វតបរាមាសំ បជហាតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៥៧៥ ) អរហត្តមគ្គេន សក្កាយទិដ្ឋឹ វិចិកិច្ឆំ សីលព្វតបរាមាសំ បជហាតីតិ ។ អាមន្តា ។ ននុ តិណ្ណំ សញ្ញោជនានំ បហានំ សោតាបត្តិផលំ វុត្តំ ភគវតាតិ ។ អាមន្តា ។ ហញ្ចិ តិណ្ណំ សញ្ញោជនានំ បហានំ សោតាបត្តិផលំ វុត្តំ ភគវតា នោ វត រេ វត្តព្វេ អរហត្តមគ្គេន សព្វេ សញ្ញោជនា បហីយន្តីតិ ។

បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកប ដោយមគ្គទាំង ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ អបរាបិ សមន្នាគតកថា ។

# សព្វសញ្ញោជនប្បហានកថា

(៩៧៣) ការលះបង់ នូវសញ្ញោជនៈទាំងអស់ ឈ្មោះថាអរហត្តឬ ។ អើ ។ សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៩៧៤) សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ ដោយអរហត្តមគ្គឬ ។ អើ ។ (ព្រះអរហន្ត) លះបង់ នូវសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៩៧៥) ព្រះអរហន្ត លះបង់ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ដោយអរហត្តមគ្គឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ការលះបង់ នូវសញ្ញោជនៈទាំង ៣ ឈ្មោះថាសោតាបត្តិផលឬ ។ អើ ។ បើព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ការលះបង់ នូវសញ្ញោជនៈទាំង ៣ ឈ្មោះថាសោតាបត្តិផល ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សញ្ញោជនៈទាំងអស់ ព្រះអរហន្តលះបង់ ដោយអរហត្តមគ្គទេ ។

អរហត្តមគ្គេន សព្វេ សញ្ញោជនា បហីយន្តីតិ ។ អាមន្តា ។ អរហត្តមគ្គេន ឱឡារិកំ កាមរាគំ ឱឡារិកំ ព្យាបាទំ បជហាតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៧៦) អរហត្តមគ្គេន ឱឡារិកំ កាមរាគំ ឱឡារិកំ ព្យាបាទំ បជហាតីតិ ។ អាមន្តា ។ ននុ កាមរាគព្យាបាទានំ តនុភាវំ សកទាគាមិផលំ វុត្តំ ភគវតាតិ ។ អាមន្តា ។ ហញ្ចិ កាមរាគព្យាបាទានំ តនុភាវំ សកទាគាមិផលំ វុត្តំ ភគវតា នោ វត រេ វត្តព្វេ អរហត្តមគ្គេន សព្វេ សញ្ញោជនា បហីយន្តីតិ ។

(៤៧៧) អរហត្តមគ្គេន សព្វេ សញ្ញោជនា បហីយន្តីតិ ។ អាមន្តា ។ អរហត្តមគ្គេន អណុសហគតំ កាមរាគំ អណុសហគតំ ព្យាបាទំ បជហាតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៧៨) អរហត្តមគ្គេន អណុសហគតំ កាមរាគំ អណុសហគតំ ព្យាបាទំ បជហាតីតិ ។ អាមន្តា ។ ននុ កាមរាគព្យាបាទានំ អនវសេសប្បហានំ អនាគាមិផលំ វុត្តំ ភគវតាតិ ។ អាមន្តា ។

សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ ដោយអរហត្តមគ្គឬ ។ អើ ។ ព្រះអរហន្ត លះបង់ នូវកាមរាគៈដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោតគ្រាត ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៩៧៦ ) ព្រះអរហន្ត លះបង់ នូវកាមរាគៈដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោតគ្រាត ដោយអរហត្តមគ្គឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ភាវៈស្រាលស្តើង នៃកាមរាគៈនិងព្យា-បាទ ឈ្មោះថាសកទាគាមិផលឬ ។ អើ ។ បើព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ភាវៈស្រាលស្តើង នៃកាមរាគៈនិងព្យាបាទ ឈ្មោះថា សកទាគាមិផល ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ ដោយអរហត្តមគ្គទេ ។

( ៩៧៧ ) សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ ដោយអរហត្តមគ្គឬ ។ អើ ។ ( ព្រះអរហន្ត ) លះបង់ នូវកាមរាគៈដ៏ស្រាលស្តើង ព្យាបាទដ៏ស្រាលស្តើង ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៩៧៨ ) ( ព្រះអរហន្ត ) លះបង់ នូវកាមរាគៈដ៏ស្រាលស្តើង ព្យាបាទដ៏ស្រាលស្តើង ដោយអរហត្តមគ្គឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ការលះបង់ នូវកាមរាគៈនិងព្យាបាទ មិនឲ្យមានសេសសល់ ឈ្មោះថាអនាគាមិផលឬ ។ អើ ។

ហញ្ចិ កាមរាគព្យាបាទានំ អនវសេសប្បហានំ អនាគាមិផលំ វុត្តំ ភគវតា តេន វត រេ វត្តព្វេ អរហត្តមគ្គេន សព្វេ សញ្ញោជនា បហីយន្តីតិ ។

(៨៧៩) អរហត្តមគ្គេន សព្វេ សញ្ញោជនា បហីយន្តីតិ ។ អាមន្តា ។ ននុ រូបរាគអរូបរាគមានឧទ្ធច្ចអវិជ្ជាយ អនវសេសប្បហានំ អរហត្តំ វុត្តំ ភគវតាតិ ។ អាមន្តា ។ ហញ្ចិ រូបរាគអរូបរាគមានឧទ្ធច្ចអវិជ្ជាយ អនវសេសប្បហានំ អរហត្តំ វុត្តំ ភគវតា តេន វត រេ វត្តព្វេ អរហត្តមគ្គេន សព្វេ សញ្ញោជនា បហីយន្តីតិ ។

(៨៨០) ន វត្តព្វំ សព្វសញ្ញោជនានំ បហានំ អរហត្តន្តិ ។ អាមន្តា ។ ននុ អរហតោ សព្វេ សញ្ញោជនា បហីនាតិ ។ អាមន្តា ។ ហញ្ចិ អរហតោ សព្វេ សញ្ញោជនា បហីនា តេន វត រេ វត្តព្វេ សព្វសញ្ញោជនានំ បហានំ អរហត្តន្តិ ។

សព្វសញ្ញោជនប្បហានកថា ។

ចតុត្ថោ វគ្គោ ។

បើព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ការលះបង់ នូវកាមរាគៈនិងព្យាបាទ មិនឲ្យមានសេសសល់ ឈ្មោះថាអនាគាមិផល ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ ដោយអរហត្តមគ្គទេ ។

(៤៧៩) សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ ដោយអរហត្តមគ្គឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ការលះបង់រូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ និងអវិជ្ជា មិនឲ្យមានសេសសល់ ឈ្មោះថាអរហត្តឬ ។ អើ ។ បើព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ការលះបង់រូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ និងអវិជ្ជា មិនឲ្យមានសេសសល់ ឈ្មោះថាអរហត្ត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ ដោយអរហត្តមគ្គទេ ។

(៤៨០) បុគ្គលមិនគួរនិយាយថា ការលះបង់ នូវសញ្ញោជនៈទាំងអស់ ឈ្មោះថាអរហត្តទេឬ ។ អើ ។ ក្រែងសញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ហើយឬ ។ អើ ។ បើសញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ហើយ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ការលះបង់ នូវសញ្ញោជនៈទាំងអស់ ឈ្មោះថាអរហត្ត ។

ចប់ សព្វសញ្ញោជនប្បហានកថា ។

ចប់ ចតុត្ថវគ្គ ។

## តស្ស ឧទ្ទានំ

គិហិស្ស អរហា សហ ឧបបត្តិយា អរហា
អរហតោ សព្វេ ធម្មា អនាសវា អរហា ចតូហិ
ផលេហិ សមន្នាគតោ ឆវមេវ ឆហិ ឧបេក្ខា-
ហិ ពោធិយា ពុទ្ធោ សហ លក្ខណសមន្នាគ-
តោ ពោធិសត្តោ ឱក្កន្តនិយាមោ ចរិតព្រហ្ម-
ចរិយោ បដិបន្នកោ ផលេន សមន្នាគតោ
សព្វសញ្ញោជនានំ បហានំ អរហត្តន្តិ ។

---

## វិមុត្តកថា

(៥៨១) វិមុត្តិញាណំ វិមុត្តន្តិ ។ អាមន្តា ។
យំ កិញ្ចិ វិមុត្តិញាណំ សព្វន្តំ វិមុត្តន្តិ ។ ន ហេវំ
វត្តព្វេ ។ បេ ។ វិមុត្តិញាណំ វិមុត្តន្តិ ។ អាមន្តា ។
បច្ចវេក្ខណញាណំ វិមុត្តន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។
វិមុត្តិញាណំ វិមុត្តន្តិ ។ អាមន្តា ។ គោត្រភុនោ បុគ្គ-
លស្ស វិមុត្តិញាណំ វិមុត្តន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ឧទ្ទាននៃបញ្ចវគ្គនោះ គឺ

និយាយអំពី គ្រហស្ថ បានជាព្រះអរហន្ត ១ បានជាព្រះអរហន្តជាមួយគ្នានឹងការកើតឡើង ១ ពួកធម៌ទាំងអស់ មិនមានអាសវៈ របស់ព្រះអរហន្ត ១ ព្រះអរហន្ត ប្រកបដោយផលទាំងបួន ១ ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ យ៉ាង ១ បានជាព្រះពុទ្ធ ដោយពោធិញ្ញាណ ១ ពោធិសត្វ ប្រកបព្រមដោយលក្ខណៈ ១ ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ១ បុគ្គលអ្នកប្រតិបត្តិប្រកបដោយផល ១ ការលះបង់សញ្ញោជនៈទាំងអស់ ឈ្មោះថាអរហត្ត ១ ។

---

# វិមុត្តកថា

( ៤៨១ ) វិមុត្តិញាណ ឈ្មោះថាវិមុត្តឬ ។ អើ ។ វិមុត្តិញាណណាមួយ វិមុត្តិញាណទាំងអស់នោះ ឈ្មោះថាវិមុត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិមុត្តិញាណ ឈ្មោះថាវិមុត្តឬ ។ អើ ។ បច្ចវេក្ខណញាណ ឈ្មោះថាវិមុត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិមុត្តិញាណ ឈ្មោះថាវិមុត្តឬ ។ អើ ។ វិមុត្តិញាណ របស់បុគ្គលជាគោត្រភូ ឈ្មោះថាវិមុត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៥៨២) សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តន្តិ ។ អាមន្តា ។ សោតាបន្នស្ស ញាណំ សោតាបត្តិផលំ បត្តស្ស បដិលទ្ធស្ស អធិគតស្ស សច្ឆិកតស្ស ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តន្តិ ។ អាមន្តា ។ សកទាគាមិស្ស ញាណំ សកទាគាមិផលំ បត្តស្ស បដិលទ្ធស្ស អធិគតស្ស សច្ឆិកតស្ស ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តន្តិ ។ អាមន្តា ។ អនាគាមិស្ស ញាណំ អនាគាមិផលំ បត្តស្ស បដិលទ្ធស្ស អធិគតស្ស សច្ឆិកតស្ស ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហត្តសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តន្តិ ។ អាមន្តា ។ អរហតោ ញាណំ អរហត្តំ បត្តស្ស បដិលទ្ធស្ស អធិគតស្ស សច្ឆិកតស្ស ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

វិមុត្តកថា

( ៥៨៤ ) វិមុត្តិញាណ របស់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឈ្មោះថាវិមុត្តឬ ។ អើ ។ ញាណរបស់សោតាបន្នបុគ្គល ជាញាណរបស់បុគ្គល ដែលបានដល់ បានបំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិមុត្តិញាណ របស់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ឈ្មោះថាវិមុត្តឬ ។ អើ ។ ញាណ របស់សកទាគាមិបុគ្គល ជាញាណរបស់បុគ្គលដែលបានដល់ បានបំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ នូវសកទាគា-មិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិមុត្តិញាណ របស់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ឈ្មោះថាវិមុត្តឬ ។ អើ ។ ញាណ របស់អនាគាមិបុគ្គល ជាញាណរបស់បុគ្គល ដែលបានដល់ បានបំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិមុត្តិញាណ របស់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្ត ឈ្មោះថាវិមុត្តឬ ។ អើ ។ ញាណ របស់ព្រះអរហន្ត ជាញាណរបស់បុគ្គលដែលបានដល់ បានបំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ នូវព្រះអរហត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៨៣) សោតាបត្តិផលសមង្គិស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តន្តិ ។ អាមន្តា ។ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ សកទាគាមិផលសមង្គិស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តន្តិ ។ អាមន្តា ។ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ អនាគាមិផលសមង្គិស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តន្តិ ។ អាមន្តា ។ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ អរហត្តផលសមង្គិស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តន្តិ ។ អាមន្តា ។ អរហត្តសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

(៤៨៤) សោតាបត្តិផលសមង្គិស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តំ តញ្ច ផលំ បត្តស្ស ញាណន្តិ ។ អាមន្តា ។ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តំ តញ្ច

ទុក្ខសច្ចំ សង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សមុទយោ សង្ខតោតិ ។ អាមន្តា ។ សមុទយសច្ចំ សង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា សង្ខតាតិ ។ អាមន្តា ។ សមុទយសច្ចំ សង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មគ្គោ សង្ខតោតិ ។ អាមន្តា ។ មគ្គសច្ចំ សង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ សង្ខតោតិ ។ អាមន្តា ។ មគ្គសច្ចំ សង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៤៨) និរោធសច្ចំ អសង្ខតំ និរោធោ អសង្ខតោតិ ។ អាមន្តា ។ ទុក្ខសច្ចំ អសង្ខតំ ទុក្ខំ អសង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ និរោធសច្ចំ អសង្ខតំ និរោធោ អសង្ខតោតិ ។ អាមន្តា ។ សមុទយសច្ចំ អសង្ខតំ សមុទយោ អសង្ខតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ និរោធសច្ចំ អសង្ខតំ និរោធោ អសង្ខតោតិ ។ អាមន្តា ។ មគ្គសច្ចំ អសង្ខតំ មគ្គោ អសង្ខតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ទុក្ខសច្ចំ ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សមុទយៈ ជាសង្ខតៈឬ ។ អើ ។ សមុទយសច្ចំ ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ជាសង្ខតៈឬ ។ អើ ។ សមុទយសច្ចំ ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មគ្គ ជាសង្ខតៈឬ ។ អើ ។ មគ្គសច្ចំ ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ជាសង្ខតៈឬ ។ អើ ។ មគ្គសច្ចំ ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៤៨) និរោធសច្ចំ ជាអសង្ខតៈ និរោធ ជាអសង្ខតៈដែរឬ ។ អើ ។ ទុក្ខសច្ចំ ជាអសង្ខតៈ ទុក្ខ ជាអសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ និរោធសច្ចំ ជាអសង្ខតៈ និរោធ ជាអសង្ខតៈដែរឬ ។ អើ ។ សមុទយសច្ចំ ជាអសង្ខតៈ សមុទយៈ ជាអសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ និរោធសច្ចំ ជាអសង្ខតៈ និរោធ ជាអសង្ខតៈដែរឬ ។ អើ ។ មគ្គសច្ចំ ជាអសង្ខតៈ មគ្គ ជាអសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៦៤៩ ] ទុក្ខសច្ចំ អសង្ខតំ ទុក្ខំ សង្ខតន្តិ ។ អាមន្តា ។ និរោធសច្ចំ អសង្ខតំ និរោធោ សង្ខតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សមុទយសច្ចំ អសង្ខតំ សមុទយោ សង្ខតោតិ ។ អាមន្តា ។ និរោធសច្ចំ អសង្ខតំ និរោធោ សង្ខតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មគ្គសច្ចំ អសង្ខតំ មគ្គោ សង្ខតោតិ ។ អាមន្តា ។ និរោធសច្ចំ អសង្ខតំ និរោធោ សង្ខតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[ ៦៥០ ] ន វត្តព្វំ ចត្តារិ សច្ចានិ អសង្ខតានីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ចត្តារិមានិ ភិក្ខវេ តថានិ អវិតថានិ អនញ្ញថានិ ។ កតមានិ ចត្តារិ ។ ឥទំ ទុក្ខន្តិ ភិក្ខវេ តថមេតំ អវិតថមេតំ អនញ្ញថមេតំ ។ បេ ។ អយំ ទុក្ខសមុទយោតិ ។ បេ ។ អយំ ទុក្ខនិរោធោតិ ។ បេ ។ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ តថមេតំ អវិតថមេតំ អនញ្ញថមេតំ ឥមានិ ខោ ភិក្ខវេ ចត្តារិ តថានិ អវិតថានិ អនញ្ញថានីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ចត្តារិ សច្ចានិ អសង្ខតានីតិ ។

សច្ចកថា ។

[ ៦៤៩ ] ទុក្ខសច្ច ជាអសង្ខតៈ ទុក្ខ ជាសង្ខតៈដែរឬ ។ អើ ។ និរោធសច្ច ជាអសង្ខតៈ និរោធ ជាសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សមុទយសច្ច ជាអសង្ខតៈ សមុទយៈ ជាសង្ខតៈដែរឬ ។ អើ ។ និរោធសច្ច ជាអសង្ខតៈ និរោធ ជាសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មគ្គសច្ច ជាអសង្ខតៈ មគ្គ ជាសង្ខតៈដែរឬ ។ អើ ។ និរោធសច្ច ជាអសង្ខតៈ និរោធ ជាសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៦៥០ ] បុគ្គលមិនគួរនិយាយថា សច្ចៈទាំង ៤ ជាអសង្ខតៈ ទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេចក្ដីពិត សេចក្ដីមិនឃ្លៀងឃ្លាត សេចក្ដីមិនប្រែប្រួលនោះ មាន ៤ យ៉ាង ។ ៤ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីពិត សេចក្ដីមិនឃ្លៀងឃ្លាត សេចក្ដីមិនប្រែប្រួលថា នេះ ជាទុក្ខ ១ ។ បេ ។ ថា នេះ ជាទុក្ខសមុទយៈ ១ ។ បេ ។ ថា នេះ ជាទុក្ខនិរោធ ១ ។ បេ ។ សេចក្ដីពិត សេចក្ដីមិនឃ្លៀងឃ្លាត សេចក្ដីមិនប្រែប្រួលថា នេះ ជាទុក្ខនិរោធគាមិនីបដិបទា ១ ម្នាលភិក្ខុទាំងឡាយ សេចក្ដីពិត សេចក្ដីមិនឃ្លៀងឃ្លាត សេចក្ដីមិនប្រែប្រួល មាន ៤ យ៉ាង នេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សច្ចៈទាំង ៤ ជាអសង្ខតៈ ។

ចប់ សច្ចកថា ។

# អារុប្បកថា

( ៦៥១ ) អាកាសានញ្ចាយតនំ អសង្ខតន្តិ ។ អាមន្តា ។ និព្វានំ តាណំ លេណំ សរណំ បរាយនំ អច្ចុតំ អមតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អាកាសានញ្ចាយតនំ អសង្ខតំ និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ ទ្វេ អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វេ អសង្ខតានីតិ ។ អាមន្តា ។ ទ្វេ តាណានិ ។ បេ ។ អន្តរិកា ភតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អាកាសានញ្ចាយតនំ អសង្ខតន្តិ ។ អាមន្តា ។ អាកាសានញ្ចាយតនំ ភវោ គតិ សត្តាវាសោ សំសារោ យោនិ វិញ្ញាណដ្ឋិតិ អត្តភាវប្បដិលាភោតិ ។ អាមន្តា ។ អសង្ខតំ ភវោ គតិ សត្តាវាសោ សំសារោ យោនិ វិញ្ញាណដ្ឋិតិ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អាកាសានញ្ចាយតនូបគំ កម្មន្តិ ។ អាមន្តា ។ អត្ថិ អសង្ខតូបគំ កម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អាកាសានញ្ចាយតនូបគា សត្តាតិ ។ អាមន្តា ។ អត្ថិ អសង្ខតូបគា សត្តាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

# អារុប្បកថា

[ ៦៥១ ] អាកាសានញ្ចាយតនៈ ជាអសង្ខតឬ ។ អើ ។ និព្វាន ជាទីពឹង ជាទីជ្រកកោន ជាទីការពារ ជាទីប្រព្រឹត្តទៅខាងមុខ ជាទីមិនច្យុត ជាទីមិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អាកាសានញ្ចាយតនៈ ជាអសង្ខតៈ ចុះនិព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អសង្ខតៈ មាន ២ ឬ ។ អើ ។ ទីពឹង មាន ២ ។ បេ ។ ការវិនាសទៅក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អាកាសានញ្ចាយតនៈ ជាអសង្ខតៈឬ ។ អើ ។ អាកាសានញ្ចាយតនៈ គឺជាភព ជាគតិ ជាសត្តាវាសៈ ជាសំសារ ជាកំណើត ជាវិញ្ញាណដ្ឋិតិ ជាការបានចំពោះនូវអត្តភាពឬ ។ អើ ។ អសង្ខតៈ គឺជាភព ជាគតិ ជាសត្តាវាសៈ ជាសំសារ ជាកំណើត ជាវិញ្ញាណដ្ឋិតិ ជាការបានចំពោះនូវអត្តភាពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កម្ម ដែលចូលទៅកាន់អាកាសានញ្ចាយតនៈ មានឬ ។ អើ ។ កម្ម ដែលចូលទៅកាន់អសង្ខតៈ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វដែលចូលទៅកាន់អាកាសានញ្ចាយតនៈ មានឬ ។ អើ ។ ពួកសត្វដែលចូលទៅកាន់អសង្ខតៈ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៦៥២ ] អាកាសានញ្ចាយតនេ សត្តា ជាយន្តិ ជិយ្យន្តិ មិយ្យន្តិ ចវន្តិ ឧបបជ្ជន្តីតិ ។ អាមន្តា ។ អសង្ខតេ សត្តា ជាយន្តិ ជិយ្យន្តិ មិយ្យន្តិ ចវន្តិ ឧបបជ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[ ៦៥៣ ] អាកាសានញ្ចាយតនេ អត្ថិ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ អាមន្តា ។ អសង្ខតេ អត្ថិ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អាកាសានញ្ចាយតនំ ចតុវោការភវោតិ ។ អាមន្តា ។ អសង្ខតំ ចតុវោការភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[ ៦៥៤ ] ន វត្តព្វំ ចត្តារោ អារុប្បា អសង្ខតាតិ ។ អាមន្តា ។ ននុ ចត្តារោ អារុប្បា អនេជា វុត្តា ភគវតាតិ ។ អាមន្តា ។ ហញ្ចិ ចត្តារោ អារុប្បា អនេជា វុត្តា ភគវតា តេន វត រេ វត្តព្វេ ចត្តារោ អារុប្បា អសង្ខតាតិ ។

អារុប្បកថា ។

(៦៥២) ពួកសត្វ រមែងកើត ចាស់ ស្លាប់ ច្យុត កើតឡើង ក្នុងអាកាសានញ្ចាយតនៈឬ ។ អើ ។ ពួកសត្វ រមែងកើត ចាស់ ស្លាប់ ច្យុត កើតឡើង ក្នុងអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៥៣) វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងអាកាសានញ្ចាយតនៈឬ ។ អើ ។ វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អាកាសានញ្ចាយតនៈ គឺចតុវោការភពឬ ។ អើ ។ អសង្ខតៈ គឺចតុវោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៥៤) បុគ្គលមិនគួរនិយាយថា អារុប្បៈ ៤ ជាអសង្ខតៈឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អារុប្បៈ ៤ ជាធម៌មិនញាប់ញ័រឬ ។ អើ ។ បើព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អារុប្បៈ ៤ ជាធម៌មិនញាប់ញ័រ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អារុប្បៈ ៤ ជាអសង្ខតៈ ។

ចប់ អារុប្បកថា ។

# និរោធសមាបត្តិកថា

[៦៥៥] និរោធសមាបត្តិ អសង្ខតាតិ ។ អាមន្តា ។ និព្វានំ តាណំ លេណំ សរណំ បរាយនំ អច្ចុតំ អមតន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ និរោធសមាបត្តិ អសង្ខតា និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ ទ្វេ អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ទ្វេ អសង្ខតានីតិ ។ អាមន្តា ។ ទ្វេ តាណានិ ។បេ។ អន្តរិកា វាតិ ។ ន ហេវំ វត្តព្វេ ។បេ។ និរោធសមាបត្តិ អសង្ខតាតិ ។ អាមន្តា ។ អត្ថិ កេចិ និរោធំ សមាបជ្ជន្តិ បដិលភន្តិ ឧប្បាទេន្តិ សមុប្បាទេន្តិ ឧដ្ឋាបេន្តិ សមុដ្ឋាបេន្តិ និព្វត្តេន្តិ អភិនិព្វត្តេន្តិ ជនេន្តិ សញ្ជនេន្តីតិ ។ អាមន្តា ។ អត្ថិ កេចិ អសង្ខតំ សមាបជ្ជន្តិ បដិលភន្តិ ឧប្បាទេន្តិ សមុប្បាទេន្តិ ឧដ្ឋាបេន្តិ សមុដ្ឋាបេន្តិ និព្វត្តេន្តិ អភិនិព្វត្តេន្តិ ជនេន្តិ សញ្ជនេន្តីតិ ។ ន ហេវំ វត្តព្វេ ។បេ។ និរោធា វោទានំ វុដ្ឋានំ បញ្ញាយតីតិ ។ អាមន្តា ។ អសង្ខតា វោទានំ វុដ្ឋានំ បញ្ញាយតីតិ ។ ន ហេវំ វត្តព្វេ

# និរោធសមាបត្តិកថា

[ ៦៥៥ ] និរោធសមាបត្តិ ជាអសង្ខតៈឬ ។ អើ ។ និព្វាន ជាទីពឹង ជាទីជ្រកកោន ជាទីការពារ ជាទីប្រព្រឹត្តទៅខាងមុខ ជាទីមិនច្យុត ជាទីមិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ និរោធសមាបត្តិ ជាអសង្ខតៈ ចុះនិព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អសង្ខតៈ មាន ២ ឬ ។ អើ ។ ទីពឹង មាន ២ ។ បេ ។ ការវិនាស ទៅក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ និរោធសមាបត្តិ ជាអសង្ខតៈឬ ។ អើ ។ មានបុគ្គលពួកខ្លះ ចូលកាន់និរោធ បានចំពោះនូវនិរោធ ញ៉ាំងនិរោធ ឲ្យកើតឡើង ឲ្យកើតឡើងព្រម ឲ្យតាំងឡើង ឲ្យតាំងឡើងព្រម ឲ្យលូតឡើង ឲ្យលាស់ឡើង ឲ្យដុះឡើង ឲ្យដុះដាលឡើងឬ ។ អើ ។ មានបុគ្គលពួកខ្លះ ចូលកាន់អសង្ខតៈ បានចំពោះនូវអសង្ខតធម៌ ញ៉ាំងអសង្ខតធម៌ ឲ្យកើតឡើង ឲ្យកើតឡើងព្រម ឲ្យតាំងឡើង ឲ្យតាំងឡើងព្រម ឲ្យលូតឡើង ឲ្យលាស់ឡើង ឲ្យដុះឡើង ឲ្យដុះដាលឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការផ្ទៀងផ្ទាត់ ការចេញ ព្រោះនិរោធ រមែងប្រាកដឬ ។ អើ ។ ការផ្ទៀងផ្ទាត់ ការចេញ ព្រោះអសង្ខតៈ រមែងប្រាកដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ

។ បេ ។ និរោធំ សមាបជ្ជន្តស្ស បឋមំ និរុជ្ឈតិ វចីសង្ខារោ តតោ កាយសង្ខារោ តតោ ចិត្តសង្ខារោតិ ។ អាមន្តា ។ អសង្ខតំ សមាបជ្ជន្តស្ស បឋមំ និរុជ្ឈតិ វចីសង្ខារោ តតោ កាយសង្ខារោ តតោ ចិត្តសង្ខារោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ និរោធា វុដ្ឋហន្តស្ស បឋមំ ឧប្បជ្ជតិ ចិត្តសង្ខារោ តតោ កាយសង្ខារោ តតោ វចីសង្ខារោតិ ។ អាមន្តា ។ អសង្ខតា វុដ្ឋហន្តស្ស បឋមំ ឧប្បជ្ជតិ ចិត្តសង្ខារោ តតោ កាយសង្ខារោ តតោ វចីសង្ខារោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៥៦) និរោធា វុដ្ឋិតំ តយោ ផស្សា ផុសន្តិ សុញ្ញតោ ផស្សោ អនិមិត្តោ ផស្សោ អប្បណិហិតោ ផស្សោតិ ។ អាមន្តា ។ អសង្ខតា វុដ្ឋិតំ តយោ ផស្សា ផុសន្តិ សុញ្ញតោ ផស្សោ អនិមិត្តោ ផស្សោ អប្បណិហិតោ ផស្សោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ៗ បេ ៗ កាលបុគ្គលចូលកាន់និរោធ វចីសង្ខាររលត់មុន តទៅ ទើបកាយសង្ខាររលត់ តទៅ ទើបចិត្តសង្ខាររលត់ឬ ៗ អើ ៗ កាលបុគ្គលចូលកាន់អសញ្ញសត្ត វចីសង្ខាររលត់មុន តទៅ ទើបកាយសង្ខាររលត់ តទៅ ទើបចិត្តសង្ខាររលត់ឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ៗ បេ ៗ កាលបុគ្គលចេញចាកនិរោធ ចិត្តសង្ខារកើតឡើងមុន តទៅ ទើបកាយសង្ខារកើត តទៅ ទើបវចីសង្ខារកើតឬ ៗ អើ ៗ កាលបុគ្គលចេញចាកអសញ្ញសត្ត ចិត្តសង្ខារកើតឡើងមុន តទៅ ទើបកាយសង្ខារកើត តទៅ ទើបវចីសង្ខារកើតឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ៗ បេ ៗ

(៦៥៦) ផស្សៈ ៣ គឺ សុញ្ញតផស្សៈ ១ អនិមិត្តផស្សៈ ១ អប្បណិហិតផស្សៈ ១ រមែងពាល់ត្រូវនូវបុគ្គលដែលចេញអំពីនិរោធឬ ៗ អើ ៗ ផស្សៈ ៣ គឺ សុញ្ញតផស្សៈ ១ អនិមិត្តផស្សៈ ១ អប្បណិហិតផស្សៈ ១ រមែងពាល់ត្រូវនូវបុគ្គលដែលចេញអំពីអសញ្ញសត្តឬ ៗ អ្នកមិនគួរពោលយ៉ាងនេះទេ ៗ បេ ៗ

[៦៥៧] និរោធា វុដ្ឋិតស្ស វិវេកនិន្នំ ចិត្តំ ហោតិ វិវេកពោណំ វិវេកបព្ភារន្តិ ។ អាមន្តា ។ អសង្ខតា វុដ្ឋិតស្ស វិវេកនិន្នំ ចិត្តំ ហោតិ វិវេកពោណំ វិវេកបព្ភារន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

[៦៥៨] ន វត្តព្វំ និរោធសមាបត្តិ អសង្ខតាតិ ។ អាមន្តា ។ អសង្ខតាតិ ។ ន ហេវំ វត្តព្វេ ។បេ។ តេន ហិ និរោធសមាបត្តិ អសង្ខតាតិ ។

**និរោធសមាបត្តិកថា ។**

## អាកាសកថា

[៦៥៩] អាកាសោ អសង្ខតោតិ ។ អាមន្តា ។ និព្វានំ តាណំ លេណំ សរណំ បរាយនំ អច្ចុតំ អមតន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

[៦៦០] អាកាសោ អសង្ខតោ និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ ទ្វេ អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ទ្វេ អសង្ខតានីតិ ។ អាមន្តា ។ ទ្វេ តាណានិ ។បេ។ អន្តរិកា ភតិ ។ ន ហេវំ វត្តព្វេ ។បេ។

( ៦៥៧ ) ចិត្ត របស់បុគ្គលដែលចេញអំពីនិរោធ ឱនទៅកាន់វិវេក ឈមទៅកាន់វិវេក ផ្ទាកទៅកាន់វិវេកដែរឬ ។ អើ ។ ចិត្ត របស់បុគ្គលដែលចេញអំពីអសង្ខត: ឱនទៅកាន់វិវេក ឈមទៅកាន់វិវេក ផ្ទាកទៅកាន់វិវេកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៦៥៨ ) បុគ្គលមិនគួរនិយាយថា និរោធសមាបត្តិ ជាអសង្ខត:ទេឬ ។ អើ ។ និរោធសមាបត្តិ ជាអសង្ខត:ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ និរោធសមាបត្តិ ជាអសង្ខត: ។

ចប់ និរោធសមាបត្តិកថា ។

# អាកាសកថា

( ៦៥៩ ) អាកាស ជាអសង្ខត:ឬ ។ អើ ។ និព្វាន ជាទីពឹង ជាទីជ្រកកោន ជាទីការពារ ជាទីប្រព្រឹត្តទៅខាងមុខ ជាទីមិនច្យុត ជាទីមិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៦៦០ ) អាកាស ជាអសង្ខត: ចុះនិព្វាន ជាអសង្ខត:ដែរឬ ។ អើ ។ អសង្ខត: មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អសង្ខត: មាន ២ ឬ ។ អើ ។ ទីពឹង មាន ២ ។ បេ ។ ការវិនាស ទៅក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៦៦១ ] អាកាសោ អសង្ខតោតិ ។ អាមន្តា ។ អត្ថិ កោចិ អនាកាសំ អាកាសំ ករោន្តីតិ ។ អា-មន្តា ។ អត្ថិ កោចិ សង្ខតំ អសង្ខតំ ករោន្តីតិ ។ ន ហេវំ វត្តព្វេ ។បេ ។

[ ៦៦២ ] អត្ថិ កោចិ អាកាសំ អនាកាសំ ករោន្តីតិ ។ អាមន្តា ។ អត្ថិ កោចិ អសង្ខតំ សង្ខតំ ករោន្តីតិ ។ ន ហេវំ វត្តព្វេ ។បេ ។

[ ៦៦៣ ] អាកាសេ បក្ខិនោ គច្ឆន្តិ ចន្ទិមសុរិយា គច្ឆន្តិ តារករូបានិ គច្ឆន្តិ ឥទ្ធឹ វិកុព្វន្តិ ពាហុំ ចាលេន្តិ បាណឹ ចាលេន្តិ លេឌ្ឌុំ ខិបន្តិ លគុឡំ ខិបន្តិ ឥទ្ធឹ ខិបន្តិ ឧសុំ ខិបន្តីតិ ។ អាមន្តា ។ អសង្ខតេ បក្ខិនោ គច្ឆន្តិ ចន្ទិមសុរិយា គច្ឆន្តិ តារករូបានិ គច្ឆន្តិ ឥទ្ធឹ វិកុព្វន្តិ ពាហុំ ចាលេន្តិ បាណឹ ចាលេន្តិ លេឌ្ឌុំ ខិបន្តិ លគុឡំ ខិបន្តិ ឥទ្ធឹ ខិបន្តិ ឧសុំ ខិបន្តីតិ ។ ន ហេវំ វត្តព្វេ ។បេ ។

(៦៦១) អាកាស ជាអសង្ខតៈឬ ។ អើ ។ មាន បុគ្គលពួកខ្លះ ធ្វើនូវទីមិនមែនជាអាកាស ឲ្យជាអាកាសឬ ។ អើ ។ មាន បុគ្គលពួកខ្លះ ធ្វើនូវសង្ខតៈ ឲ្យជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៦២) មាន បុគ្គលពួកខ្លះ ធ្វើនូវអាកាស ឲ្យទៅជាមិនមែនអាកាសឬ ។ អើ ។ មាន បុគ្គលពួកខ្លះ ធ្វើនូវអសង្ខតៈ ឲ្យជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៤៣) ពួកសត្វស្លាប តែងហើរទៅ ព្រះចន្ទ្រនិងព្រះអាទិត្យ តែងចរទៅ ពួកផ្កាយ តែងចរទៅ ពួកជន តែងសម្ដែងរិទ្ធិ តែងញ៉ាំងដើមដៃឲ្យកម្រើក ញ៉ាំងបាតដៃឲ្យកម្រើក បោះដុំដី បោះដំបង បោះរិទ្ធិ បោះកូនសរ ទៅក្នុងអាកាសបានឬ ។ អើ ។ ពួកសត្វស្លាប តែងហើរទៅ ព្រះចន្ទ្រនិងព្រះអាទិត្យ តែងចរទៅ ពួកផ្កាយ តែងចរទៅ ពួកជន តែងសម្ដែងរិទ្ធិ តែងញ៉ាំងដើមដៃឲ្យកម្រើក ញ៉ាំងបាតដៃឲ្យកម្រើក បោះដុំដី បោះដំបង បោះរិទ្ធិ បោះកូនសរ ទៅក្នុងអសង្ខតៈបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

អាកាសកថា

(៦៦៤) អាកាសំ បរិវារេត្វា ឃរានិ ករោន្តិ កោដ្ឋានិ ករោន្តីតិ ។ អាមន្តា ។ អសង្ខតំ បរិវារេត្វា ឃរានិ ករោន្តិ កោដ្ឋានិ ករោន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៦៥) ឧទបានេ ខញ្ញមានេ អនាកាសោ អាកាសោ ហោតីតិ ។ អាមន្តា ។ សង្ខតំ អសង្ខតំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៦៦) តុច្ឆឧទបានេ បូរិយមានេ តុច្ឆកោដ្ឋេ បូរិយមានេ តុច្ឆកុម្ភិយា បូរិយមានាយ អាកាសោ អន្តរធាយតីតិ ។ អាមន្តា ។ អសង្ខតំ អន្តរធាយតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៦៧) ន វត្តព្វំ អាកាសោ អសង្ខតោតិ ។ អាមន្តា ។ អាកាសោ សង្ខតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ អាកាសោ អសង្ខតោតិ ។

អាកាសកថា ។

អាកាសកថា

( ៦៦៤ ) ពួកជន បិទបាំងនូវអាកាស ហើយធ្វើផ្ទះទាំងឡាយ ធ្វើជង្រុកទាំងឡាយបានឬ ។ អើ ។ ពួកជន បិទបាំង នូវអសង្ខតៈ ហើយធ្វើផ្ទះទាំងឡាយ ធ្វើជង្រុកទាំងឡាយបានឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

( ៦៦៥ ) កាលអណ្តូង ដែលគេជីក អាកាស ទៅជាមិនមែន អាកាសឬ ។ អើ ។ សង្ខតៈ ទៅជាអសង្ខតៈឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

( ៦៦៦ ) កាលអណ្តូងទទេ ដែលគេដាក់ទឹកពេញ កាលជង្រុក ទទេ ដែលគេដាក់ស្រូវពេញ កាលក្អមទទេ ដែលគេដាក់ទឹកពេញ អា-កាស រមែងបាត់ឬ ។ អើ ។ អសង្ខតៈ រមែងបាត់ឬ ។ អ្នកមិន គួរពោលយ៉ាងនេះទេ ។ បេ ។

( ៦៦៧ ) បុគ្គលមិនគួរនិយាយថា អាកាស ជាអសង្ខតៈឬ ។ អើ ។ អាកាស ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ អាកាស ជាអសង្ខតៈ ។

ចប់ អាកាសកថា ។

# អាកាសោ សនិទស្សនោតិកថា

(៦៦៨) អាកាសោ សនិទស្សនោតិ ។ អាមន្តា ។ រូបំ រូបាយតនំ រូបធាតុ នីលំ បីតកំ លោហិតកំ ឱទាតំ ចក្ខុវិញ្ញេយ្យំ ចក្ខុស្មឹ បដិហញ្ញតិ ចក្ខុស្ស អាបាថំ អាគច្ឆតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៦៦៩) អាកាសោ សនិទស្សនោតិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច អាកាសញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

(៦៧០) ចក្ខុញ្ច បដិច្ច អាកាសញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច អាកាសញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ នត្ថិ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ ហញ្ចិ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោ តេន វត រេ វត្តព្វេ ចក្ខុញ្ច បដិច្ច អាកាសញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។

# អាកាសសនិទស្សនោតិកថា

(៦៦៨) អាកាស ជាសនិទស្សនៈ (ប្រកបដោយការមើលឃើញ) ឬ ។ អើ ។ រូប រូបាយតនៈ រូបធាតុ ពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ដែលបុគ្គលគប្បីដឹងបានដោយចក្ខុ រមែងប៉ះពាល់ក្នុងចក្ខុ មកកាន់គន្លងនៃចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៦៩) អាកាស ជាសនិទស្សនៈឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវអាកាសផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៧០) ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវអាកាសផងឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវអាកាសផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវអាកាសផងទេ ។

(៦៧១) ន វត្តព្វំ អាកាសោ សនិទស្សនោតិ ។ អាមន្តា ។ ននុ បស្សសិ ទ្វិន្នំ រុក្ខានំ អន្តរំ ទ្វិន្នំ ថម្ភានំ អន្តរំ តាឡច្ឆិទ្ទំ វាតបានច្ឆិទ្ទន្តិ ។ អាមន្តា ។ ហញ្ចិ បស្សសិ ទ្វិន្នំ រុក្ខានំ អន្តរំ ទ្វិន្នំ ថម្ភានំ អន្តរំ តាឡច្ឆិទ្ទំ វាតបានច្ឆិទ្ទំ តេន វត រេ វត្តព្វេ អាកាសោ សនិទស្សនោតិ ។

អាកាសោ សនិទស្សនោតិកថា ។

## បឋវីធាតុ សនិទស្សនាត្យាទិកថា

(៦៧២) បឋវីធាតុ សនិទស្សនាតិ ។ អាមន្តា ។ រូបំ រូបាយតនំ រូបធាតុ នីលំ បីតកំ លោហិតកំ ឱទាតំ ចក្ខុវិញ្ញេយ្យំ ចក្ខុស្មឹ បដិហញ្ញតិ ចក្ខុស្ស អាបាថំ អាគច្ឆតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៧៣) បឋវីធាតុ សនិទស្សនាតិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច បឋវីធាតុញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៦៧១ ) បុគ្គលមិនគួរនិយាយថា អាកាស ជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នក ឃើញ នូវចន្លោះនៃដើមឈើពីរ នូវចន្លោះនៃសសរពីរ នូវប្រហោងនៃកូនសោ នូវប្រហោងនៃបង្អួចដែរឬ ។ អើ ។ បើអ្នក ឃើញ នូវចន្លោះនៃដើមឈើពីរ នូវចន្លោះនៃសសរពីរ នូវប្រហោងនៃកូនសោ នូវប្រហោងនៃបង្អួចដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អាកាស ជាសនិទស្សនៈដែរ ។

ចប់ អាកាសសនិទស្សនោតិកថា ។

## បឋវីធាតុសនិទស្សនាត្យាទិកថា

( ៦៧២ ) បឋវីធាតុ ជាសនិទស្សនៈឬ ។ អើ ។ រូប រូបាយតនៈ រូបធាតុ ពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ដែលបុគ្គលគប្បីដឹងបានដោយចក្ខុ រមែងប៉ះពាល់ក្នុងចក្ខុ មកកាន់គន្លងនៃចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៦៧៣ ) បឋវីធាតុ ជាសនិទស្សនៈឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវបឋវីធាតុផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[ ៦៧៨ ] ចក្ខុញ្ច បដិច្ច បឋវីធាតុញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច បឋវីធាតុញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ នត្ថិ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ ហញ្ចិ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោ នោ វត រេ វត្តព្វេ ចក្ខុញ្ច បដិច្ច បឋវីធាតុញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។

[ ៦៧៩ ] ន វត្តព្វំ បឋវីធាតុ សនិទស្សនាតិ ។ អាមន្តា ។ ននុ បស្សសិ ភូមឹ ចាសាណំ បព្វតន្តិ ។ អាមន្តា ។ ហញ្ចិ បស្សសិ ភូមឹ ចាសាណំ បព្វតំ តេន វត រេ វត្តព្វេ បឋវីធាតុ សនិទស្សនាតិ ។បេ។ ន វត្តព្វំ អាបោធាតុ សនិទស្សនាតិ ។ អាមន្តា ។ ននុ បស្សសិ ឧទកន្តិ ។ អាមន្តា ។ ហញ្ចិ បស្សសិ ឧទកំ តេន វត រេ វត្តព្វេ អាបោធាតុ សនិទស្សនាតិ ។បេ។ ន វត្តព្វំ តេជោធាតុ សនិទស្សនាតិ ។ អាមន្តា ។ ននុ បស្សសិ អគ្គឹ ជលន្តន្តិ ។ អាមន្តា ។

( ៦៧៨ ) ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវបឋវីធាតុផងឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវបឋវីធាតុផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវបឋវីធាតុផងទេ ។

( ៦៧៩ ) បុគ្គលមិនគួរនិយាយថា បឋវីធាតុ ជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នក ឃើញផែនដី ថ្ម ភ្នំ ដែរឬ ។ អើ ។ បើអ្នក ឃើញផែនដី ថ្ម ភ្នំដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បឋវីធាតុ ជាសនិទស្សនៈដែរ ។ បេ ។ បុគ្គលមិនគួរនិយាយថា អាបោធាតុ ជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នក ឃើញទឹកដែរឬ ។ អើ ។ បើអ្នក ឃើញទឹកដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អាបោធាតុ ជាសនិទស្សនៈដែរ ។ បេ ។ បុគ្គលមិនគួរនិយាយថា តេជោធាតុ ជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នក ឃើញភ្លើងកំពុងឆេះដែរឬ ។ អើ ។

ហញ្ចិ បស្សសិ អគ្គឹ ជលន្តំ តេន វត រេ វត្តព្វេ តេជោ-ធាតុ សនិទស្សនាតិ ។ប។ ន វត្តព្វំ អាបោធាតុ សនិទស្សនាតិ ។ អាមន្តា ។ ននុ បស្សសិ អាបេន រុក្ខេ សញ្ចាលិយមានេតិ ។ អាមន្តា ។ ហញ្ចិ បស្សសិ អាបេន រុក្ខេ សញ្ចាលិយមានេ តេន វត រេ វត្តព្វេ អាបោធាតុ សនិទស្សនាតិ ។ប។

បឋវីធាតុ សនិទស្សនាត្យាទិកថា ។

## ចក្ខុន្ទ្រិយំ សនិទស្សនន្តិអាទិកថា

(៦៧៦) ចក្ខុន្ទ្រិយំ សនិទស្សនន្តិ ។ អាមន្តា ។ រូបំ រូបាយតនំ រូបធាតុ ។ប។ ចក្ខុស្ស អាបាថំ អាគច្ឆតីតិ ។ ន ហេវំ វត្តព្វេ ។ប។

(៦៧៧) ចក្ខុន្ទ្រិយំ សនិទស្សនន្តិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច ចក្ខុន្ទ្រិយញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ប។

(៦៧៨) ចក្ខុញ្ច បដិច្ច ចក្ខុន្ទ្រិយញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច ចក្ខុន្ទ្រិយញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ នត្ថិ ។

បើអ្នក ឃើញភ្លើងកំពុងឆេះដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា តេជោធាតុ ជាសនិទស្សនៈដែរ ។ បេ ។ បុគ្គលមិនគួរនិយាយថា វាយោធាតុ ជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នកឃើញដើមឈើ ដែលរញ្ជួយដោយខ្យល់ដែរឬ ។ អើ ។ បើអ្នកឃើញដើមឈើ ដែលរញ្ជួយដោយខ្យល់ដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វាយោធាតុ ជាសនិទស្សនៈដែរ ។ បេ ។

ចប់ បឋវីធាតុសនិទស្សនាត្យាទិកថា ។

## ចក្ខុន្ទ្រិយំ សនិទស្សនន្តិអាទិកថា

( ៦៧៦ ) ចក្ខុន្ទ្រិយ ជាសនិទស្សនៈឬ ។ អើ ។ រូប រូបាយតនៈ រូបធាតុ ។ បេ ។ មកកាន់គន្លងនៃចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៦៧៧ ) ចក្ខុន្ទ្រិយ ជាសនិទស្សនៈឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវចក្ខុន្ទ្រិយផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៦៧៨ ) ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវចក្ខុន្ទ្រិយផងឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវចក្ខុន្ទ្រិយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។

ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ ហញ្ចិ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោ តេន វត រេ វត្តព្វេ ចក្ខុញ្ច បដិច្ច ចក្ខុន្ទ្រិយញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។

(៦៧៩) ន វត្តព្វំ បញ្ចិន្ទ្រិយានិ សនិទស្សនានីតិ ។ អាមន្តា ។ ននុ បស្សសិ ចក្ខុំ សោតំ ឃានំ ជិវ្ហំ កាយន្តិ ។ អាមន្តា ។ ហញ្ចិ បស្សសិ ចក្ខុំ សោតំ ឃានំ ជិវ្ហំ កាយំ តេន វត រេ វត្តព្វេ បញ្ចិន្ទ្រិយានិ សនិទស្សនានីតិ ។ ប ។

ចក្ខុន្ទ្រិយំ សនិទស្សនន្តិអាទិកថា ។

# កាយកម្មំ សនិទស្សនន្តិកថា

(៦៨០) កាយកម្មំ សនិទស្សនន្តិ ។ អាមន្តា ។ រូបំ រូបាយតនំ រូបធាតុ នីលំ បីតកំ លោហិតកំ ឱទាតំ ចក្ខុវិញ្ញេយ្យំ ចក្ខុស្មឹ បដិហញ្ញតិ ចក្ខុស្ស អាបាថំ អាគច្ឆតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាយកម្មំ សនិទស្សនន្តិ ។ អាមន្តា ។

ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវចក្ខុន្ទ្រិយផងទេ ។

[ ៦៧៩ ] បុគ្គលមិនគួរនិយាយថា បញ្ចិន្ទ្រិយ ( ឥន្ទ្រិយ ៥ ) ជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នក ឃើញភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយដែរឬ ។ អើ ។ បើអ្នកឃើញភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បញ្ចិន្ទ្រិយ ជាសនិទស្សនៈដែរ ។ បេ ។

ចប់ ចក្ខុន្ទ្រិយំ សនិទស្សនន្តិអាទិកថា ។

## កាយកម្មំ សនិទស្សនន្តិកថា

[ ៦៨០ ] កាយកម្ម ជាសនិទស្សនៈឬ ។ អើ ។ រូប រូបាយតនៈ រូបធាតុ ពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ដែលបុគ្គលគួរដឹងបានដោយចក្ខុ រមែងប៉ះពាល់ក្នុងចក្ខុ មកកាន់គន្លងនៃចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាយកម្ម ជាសនិទស្សនៈឬ ។ អើ ។

## កាយកម្មំ សនិទស្សនត្តិកថា

ចក្ខុញ្ច បដិច្ច កាយកម្មញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ ចក្ខុញ្ច បដិច្ច កាយកម្មញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច កាយកម្មញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ នត្ថិ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ ហញ្ចិ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោ តេន វត រេ វត្តព្វេ ចក្ខុញ្ច បដិច្ច កាយកម្មញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។

(៦៨១) ន វត្តព្វំ កាយកម្មំ សនិទស្សនន្តិ ។ អាមន្តា ។ ននុ បស្សសិ អភិក្កមន្តំ បដិក្កមន្តំ អាលោកេន្តំ វិលោកេន្តំ សម្មិញ្ជេន្តំ បសារេន្តន្តិ ។ អាមន្តា ។ ហញ្ចិ បស្សសិ អភិក្កមន្តំ បដិក្កមន្តំ អាលោកេន្តំ វិលោកេន្តំ សម្មិញ្ជេន្តំ បសារេន្តំ តេន វត រេ វត្តព្វេ កាយកម្មំ សនិទស្សនន្តិ ។

កាយកម្មំ សនិទស្សនត្តិកថា ។

ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវកាយកម្មផង ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវកាយកម្មផងឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវកាយកម្មផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវកាយកម្មផងទេ ។

[ ៦៨១ ] បុគ្គលមិនគួរនិយាយថា កាយកម្ម ជាសនិទស្សនៈទេ ឬ ។ អើ ។ ក្រែងអ្នក ឃើញបុគ្គលដែលកំពុងដើរទៅមុខ ថយក្រោយ ក្រឡេកមើលទៅមុខ ក្រឡេកមើលទៅទិសផ្សេងៗ បត់អវយវៈ លាអវយវៈដែរឬ ។ អើ ។ បើអ្នក ឃើញបុគ្គលដែលកំពុងដើរទៅមុខ ថយក្រោយ ក្រឡេកមើលទៅមុខ ក្រឡេកមើលទៅទិសផ្សេងៗ បត់អវយវៈ លាអវយវៈដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កាយកម្ម ជាសនិទស្សនៈដែរ ។

ចប់ កាយកម្មំ សនិទស្សនត្តិកថា ។

បឋវីធាតុ សនិទស្សនាតិអាទិ កថា

កាយកម្មំ សនិទស្សនន្តិ បរិយោសានកថា ។

ឆដ្ឋោ វគ្គោ ។

## តស្សុទ្ទានំ

និយាមោ អសង្ខតោ បដិច្ចសមុប្បាទោ
អសង្ខតោ ចត្តារិ សច្ចានិ អសង្ខតានិ
ចត្តារោ អារុប្បា អសង្ខតា និរោធ-
សមាបត្តិ អសង្ខតា អាកាសោ អសង្ខតោ
អាកាសោ សនិទស្សនោ ចត្តារោ មហាភូតា
បញ្ចិន្ទ្រិយានិ តថេវ កាយកម្មន្តិ ។

អភិធម្មបិដក កថាវត្ថុ

និយាយពីបឋវីធាតុសនិទស្សនៈជាដើម

និងកាយកម្មសនិទស្សនៈជាទីបំផុត ។

ចប់ ឆដ្ឋវគ្គ ។

## ឧទ្ទាន នៃឆដ្ឋវគ្គនោះ គឺ

និយាយអំពី និយាមៈ ជាអសង្ខតៈ ១ បដិច្ចសមុប្បាទ ជាអសង្ខតៈ ១ សច្ចៈទាំង ៤ ជាអសង្ខតៈ ១ អារុប្បៈ ៤ ជាអសង្ខតៈ ១ និរោធសមាបត្តិ ជាអសង្ខតៈ ១ អាកាស ជាអសង្ខតៈ ១ អាកាស ជាសនិទស្សនៈ ១ មហាភូតរូប ៤ ជាសនិទស្សនៈ ១ បញ្ចិន្ទ្រិយ ជាសនិទស្សនៈ ១ កាយកម្ម ជាសនិទស្សនៈ ១ ។

---

# សង្គហិតកថា

( ៦៨២ ) នត្ថិ កេចិ ធម្មា កេហិចិ ធម្មេហិ សង្គហិតាតិ ។ អាមន្តា ។ ននុ អត្ថិ កេចិ ធម្មា កេហិចិ ធម្មេហិ គណនំ គច្ឆន្តិ ឧទ្ទេសំ គច្ឆន្តិ បរិយាបន្នាតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កេចិ ធម្មា កេហិចិ ធម្មេហិ គណនំ គច្ឆន្តិ ឧទ្ទេសំ គច្ឆន្តិ បរិយាបន្នា នោ វត រេ វត្តព្វេ នត្ថិ កេចិ ធម្មា កេហិចិ ធម្មេហិ សង្គហិតាតិ ។

( ៦៨៣ ) ចក្ខាយតនំ កតមក្ខន្ធគណនំ គច្ឆតីតិ ។ រូបក្ខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ ចក្ខាយតនំ រូបក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ ចក្ខាយតនំ រូបក្ខន្ធេន សង្គហាហិតន្តិ ។ សោតាយតនំ ។ បេ ។ ឃានាយតនំ ។ បេ ។ ជិវ្ហាយតនំ ។ បេ ។ កាយាយតនំ កតមក្ខន្ធគណនំ គច្ឆតីតិ ។ រូបក្ខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ កាយាយតនំ រូបក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ កាយាយតនំ រូបក្ខន្ធេន សង្គហិតន្តិ ។

# សង្គហិតកថា

( ៦៨២ ) ពួកធម៌នីមួយ សង្គ្រោះ ដោយពួកធម៌នីមួយ មិនមានទេ ឬ ។ អើ ។ ក្រែងពួកធម៌នីមួយ ដល់នូវការរាប់ ដល់នូវឧទ្ទេស រាប់បញ្ចូល ដោយពួកធម៌នីមួយ មានឬ ។ អើ ។ បើពួកធម៌នីមួយ ដល់នូវការរាប់ ដល់នូវឧទ្ទេស រាប់បញ្ចូល ដោយពួកធម៌នីមួយ មានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ពួកធម៌នីមួយ សង្គ្រោះ ដោយពួកធម៌នីមួយ មិនមានទេ ។

( ៦៨៣ ) អាយតនៈគឺភ្នែក ដល់នូវការរាប់ដោយខន្ធណា ។ ដល់នូវការរាប់ដោយរូបក្ខន្ធ ។ បើអាយតនៈគឺភ្នែក ដល់នូវការរាប់ ដោយរូបក្ខន្ធយ៉ាងនេះ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរ ពោលថា អាយតនៈគឺភ្នែក សង្គ្រោះ ដោយរូបក្ខន្ធ ។ អាយតនៈគឺ ត្រចៀក ។ បេ ។ អាយតនៈគឺច្រមុះ ។ បេ ។ អាយតនៈគឺ អណ្តាត ។ បេ ។ អាយតនៈគឺកាយ ដល់នូវការរាប់ដោយខន្ធណា ។ ដល់នូវការរាប់ដោយរូបក្ខន្ធ ។ បើអាយតនៈគឺកាយ ដល់នូវការរាប់ដោយ រូបក្ខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោល ថា អាយតនៈគឺកាយ សង្គ្រោះ ដោយរូបក្ខន្ធ ។

[ ៦៨៤ ] រូបាយតនំ ។បេ។ សទ្ទាយតនំ ។បេ។ គន្ធាយតនំ ។បេ។ រសាយតនំ ។បេ។ ផោដ្ឋព្វាយតនំ កតមក្ខន្ធគណនំ គច្ឆតីតិ ។ រូបក្ខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ ផោដ្ឋព្វាយតនំ រូបក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ ផោដ្ឋព្វាយតនំ រូបក្ខន្ធេន សង្គហិតន្តិ ។

[ ៦៨៥ ] សុខា វេទនា កតមក្ខន្ធគណនំ គច្ឆតីតិ ។ វេទនាក្ខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ សុខា វេទនា វេទនាក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ សុខា វេទនា វេទនាក្ខន្ធេន សង្គហិតាតិ ។ ទុក្ខា វេទនា ។បេ។ អទុក្ខមសុខា វេទនា កតមក្ខន្ធគណនំ គច្ឆតីតិ ។ វេទនាក្ខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ អទុក្ខមសុខា វេទនា វេទនាក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ អទុក្ខមសុខា វេទនា វេទនាក្ខន្ធេន សង្គហិតាតិ ។

[ ៦៨៤ ] អាយតនៈគឺរូប ។ បេ ។ អាយតន គឺសំឡេង ។ បេ ។ អាយតនៈគឺក្លិន ។ បេ ។ អាយតនៈគឺរស ។ បេ ។ អាយតនៈគឺសម្ផស្ស ដល់នូវការកប់ដោយខន្ធណា ។ ដល់នូវការកប់ដោយរូបក្ខន្ធ ។ បើអាយតនៈគឺសម្ផស្ស ដល់នូវការកប់ដោយរូបក្ខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អាយតនៈគឺសម្ផស្ស សង្គ្រោះ ដោយរូបក្ខន្ធ ។

[ ៦៨៥ ] សុខវេទនា ដល់នូវការកប់ដោយខន្ធណា ។ ដល់នូវការកប់ដោយវេទនាខន្ធ ។ បើសុខវេទនា ដល់នូវការកប់ដោយវេទនាខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សុខវេទនា សង្គ្រោះ ដោយវេទនាខន្ធ ។ ទុក្ខវេទនា ។ បេ ។ អទុក្ខមសុខវេទនា ដល់នូវការកប់ដោយខន្ធណា ។ ដល់នូវការកប់ដោយវេទនាខន្ធ ។ បើអទុក្ខមសុខវេទនា ដល់នូវការកប់ដោយវេទនាខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អទុក្ខមសុខវេទនា សង្គ្រោះ ដោយវេទនាខន្ធ ។

## សង្គហិតកថា

[ ៦៨៦ ] ចក្ខុសម្ផស្សជា សញ្ញា កតមក្ខន្ធគណនំ គច្ឆតីតិ ។ សញ្ញាក្ខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ ចក្ខុសម្ផស្សជា សញ្ញា សញ្ញាក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ ចក្ខុសម្ផស្សជា សញ្ញា សញ្ញាក្ខន្ធេន សង្គហិតាតិ ។ សោតសម្ផស្សជា សញ្ញា ។បេ។ មនោសម្ផស្សជា សញ្ញា កតមក្ខន្ធគណនំ គច្ឆតីតិ ។ សញ្ញាក្ខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ មនោសម្ផស្សជា សញ្ញា សញ្ញាក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ មនោសម្ផស្សជា សញ្ញា សញ្ញាក្ខន្ធេន សង្គហិតាតិ ។

[ ៦៨៧ ] ចក្ខុសម្ផស្សជា ចេតនា ។បេ។ មនោសម្ផស្សជា ចេតនា កតមក្ខន្ធគណនំ គច្ឆតីតិ ។ សង្ខារក្ខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ មនោសម្ផស្សជា ចេតនា សង្ខារក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ មនោសម្ផស្សជា ចេតនា សង្ខារក្ខន្ធេន សង្គហិតាតិ ។

## សង្គហិតកថា

(៦៨៦) សញ្ញា កើតអំពីចក្ខុសម្ផស្ស ដល់នូវការរាប់ដោយខន្ធណា ។ ដល់នូវការរាប់ដោយសញ្ញាខន្ធ ។ បើសញ្ញា កើតអំពីចក្ខុសម្ផស្ស ដល់នូវការរាប់ដោយសញ្ញាខន្ធ (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សញ្ញា កើតអំពីចក្ខុសម្ផស្ស សង្គ្រោះ ដោយសញ្ញាខន្ធ ។ សញ្ញា កើតអំពីសោតសម្ផស្ស ។ បេ ។ សញ្ញា កើតអំពីមនោសម្ផស្ស ដល់នូវការរាប់ដោយខន្ធណា ។ ដល់នូវការរាប់ដោយសញ្ញាខន្ធ ។ បើសញ្ញា កើតអំពីមនោសម្ផស្ស ដល់នូវការរាប់ដោយសញ្ញាខន្ធ (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សញ្ញា កើតអំពីមនោសម្ផស្ស សង្គ្រោះ ដោយសញ្ញាខន្ធ ។

(៦៨៧) ចេតនា កើតអំពីចក្ខុសម្ផស្ស ។ បេ ។ ចេតនា កើតអំពីមនោសម្ផស្ស ដល់នូវការរាប់ដោយខន្ធណា ។ ដល់នូវការរាប់ដោយសង្ខារក្ខន្ធ ។ បើចេតនា កើតអំពីមនោសម្ផស្ស ដល់នូវការរាប់ដោយសង្ខារក្ខន្ធ (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន អ្នកគួរពោលថា ចេតនា កើតអំពីមនោសម្ផស្ស សង្គ្រោះ ដោយសង្ខារក្ខន្ធ ។

(៦៨៨) ចក្ខុវិញ្ញាណំ ។ បេ ។ មនោវិញ្ញាណំ ឯកក្ខន្ធគណនំ គច្ឆតីតិ ។ វិញ្ញាណក្ខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ មនោវិញ្ញាណំ វិញ្ញាណក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ មនោវិញ្ញាណំ វិញ្ញាណក្ខន្ធេន សង្គហិតន្តិ ។ យថា ទាមេន វា យោត្តេន វា ទ្វេ ពលិពទ្ទា សង្គហិតា សិក្កាយ បិណ្ឌបាតោ សង្គហិតោ សា គទ្ទុលេន សង្គហិតោ ឯវមេវ តេ ធម្មា តេហិ ធម្មេហិ សង្គហិតាតិ ។ ហញ្ចិ ទាមេន វា យោត្តេន វា ទ្វេ ពលិពទ្ទា សង្គហិតា សិក្កាយ បិណ្ឌបាតោ សង្គហិតោ សា គទ្ទុលេន សង្គហិតោ តេន វត រេ វត្តព្វេ អត្ថិ កេចិ ធម្មា កេហិចិ ធម្មេហិ សង្គហិតាតិ ។

សង្គហិតកថា ។

# សម្បយុត្តកថា

(៦៨៩) អត្ថិ កេចិ ធម្មា កេហិចិ ធម្មេហិ សម្បយុត្តាតិ ។ អាមន្តា ។ ននុ អត្ថិ កេចិ ធម្មា កេហិចិ ធម្មេហិ សហគតា សហជាតា សំសដ្ឋា

( ៦៨៨ ) ចក្ខុវិញ្ញាណ ។ បេ ។ មនោវិញ្ញាណ ដល់នូវការរាប់ដោយខន្ធណា ។ ដល់នូវការរាប់ដោយវិញ្ញាណក្ខន្ធ ។ បើមនោវិញ្ញាណ ដល់នូវការរាប់ដោយវិញ្ញាណក្ខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា មនោវិញ្ញាណ សង្គ្រោះ ដោយវិញ្ញា-ណក្ខន្ធ ។ គោបម្រើពីរ សង្គ្រោះ ដោយខ្សែទាម ឬដោយពួរ បិណ្ឌ-បាត សង្គ្រោះ ( ដាក់បញ្ចូល ) ក្នុងសង្រែក ឯសង្រែកនោះ សង្គ្រោះ ដោយឈើពុន យ៉ាងណា ធម៌ទាំងនោះ សង្គ្រោះ ដោយធម៌ទាំងនោះ ក៏យ៉ាងនោះដែរ ។ បើគោបម្រើពីរ សង្គ្រោះ ដោយខ្សែទាម ឬដោយពួរ បិណ្ឌបាត សង្គ្រោះ (ដាក់បញ្ចូល) ក្នុងសង្រែក ឯសង្រែកនោះ សង្គ្រោះ ដោយឈើពុន ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ពួកធម៌ទីមួយ សង្គ្រោះ ដោយពួកធម៌ទីមួយ មានដែរ ។

ចប់ សង្គហិតកថា ។

## សម្បយុត្តកថា

( ៦៨៩ ) ពួកធម៌ទីមួយ ប្រកបដោយពួកធម៌ទីមួយ មានឬ ។ អើ ។ ក្រែងពួកធម៌ទីមួយ ប្រព្រឹត្តទៅមួយអន្លើ កើតមួយអន្លើ ប្រឡំព្រម

ឯកុប្បាទា ឯកនិរោធា ឯកវត្ថុកា ឯការម្មណាតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កេចិ ធម្មា កេហិចិ ធម្មេហិ សហគតា សហជាតា សំសដ្ឋា ឯកុប្បាទា ឯកនិរោធា ឯកវត្ថុកា ឯការម្មណា តេន វត រេ វត្តព្វេ អត្ថិ កេចិ ធម្មា កេហិចិ ធម្មេហិ សម្បយុត្តាតិ ។

[៦៩០] វេទនាក្ខន្ធោ សញ្ញាក្ខន្ធេន សហជាតោតិ ។ អាមន្តា ។ ហញ្ចិ វេទនាក្ខន្ធោ សញ្ញាក្ខន្ធេន សហជាតោ តេន វត រេ វត្តព្វេ វេទនាក្ខន្ធោ សញ្ញាក្ខន្ធេន សម្បយុត្តោតិ ។ វេទនាក្ខន្ធោ សង្ខារក្ខន្ធេន វិញ្ញាណក្ខន្ធេន សហជាតោតិ ។ អាមន្តា ។ ហញ្ចិ វេទនាក្ខន្ធោ វិញ្ញាណក្ខន្ធេន សហជាតោ តេន វត រេ វត្តព្វេ វេទនាក្ខន្ធោ វិញ្ញាណក្ខន្ធេន សម្បយុត្តោតិ ។ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ វេទនាក្ខន្ធេន សញ្ញាក្ខន្ធេន សង្ខារក្ខន្ធេន សហជាតោតិ ។ អាមន្តា ។ ហញ្ចិ វិញ្ញាណក្ខន្ធោ សង្ខារក្ខន្ធេន សហជាតោ តេន វត រេ វត្តព្វេ វិញ្ញាណក្ខន្ធោ សង្ខារក្ខន្ធេន សម្បយុត្តោតិ ។ យថា តិលម្ហិ តេលំ អនុគតំ អនុបវិដ្ឋំ ឧច្ឆុម្ហិ រសោ អនុគតោ អនុបវិដ្ឋោ

សម្បយុត្តកថា

កើតជាមួយគ្នា រលត់ទៅជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយពួកធម៌នីមួយឬ ។ អើ ។ បើពួកធម៌នីមួយ ប្រព្រឹត្តទៅជាមួយ កើតជាមួយ ប្រឡំព្រម កើតជាមួយគ្នា រលត់ជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយពួកធម៌នីមួយ មាន (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ពួកធម៌នីមួយ ប្រកបដោយពួកធម៌នីមួយ មិនមានទេ ។

[៦៩០] វេទនាខន្ធ កើតជាមួយ នឹងសញ្ញាខន្ធឬ ។ អើ ។ បើវេទនាខន្ធ កើតជាមួយ នឹងសញ្ញាខន្ធ (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វេទនាខន្ធ ប្រកបដោយសញ្ញាខន្ធ (មាន) ។ វេទនាខន្ធ កើតជាមួយ នឹងសង្ខារក្ខន្ធ នឹងវិញ្ញាណក្ខន្ធឬ ។ អើ ។ បើវេទនាខន្ធ កើតជាមួយ នឹងវិញ្ញាណក្ខន្ធ (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វេទនាខន្ធ ប្រកបដោយវិញ្ញាណក្ខន្ធ (មាន) ។ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ កើតជាមួយ នឹងវេទនាខន្ធ នឹងសញ្ញាខន្ធ នឹងសង្ខារក្ខន្ធឬ ។ អើ ។ បើវិញ្ញាណក្ខន្ធ កើតជាមួយ នឹងសង្ខារក្ខន្ធ (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វិញ្ញាណក្ខន្ធ ប្រកបដោយសង្ខារក្ខន្ធ (មាន) ។ ប្រេងល្ង ឋិតនៅស៊ប់ ចូលទៅស៊ប់ ក្នុងគ្រាប់ល្ង រសអំពៅ ឋិតនៅស៊ប់ ចូលទៅស៊ប់ ក្នុងដើមអំពៅ យ៉ាងណា

ឯវមេវ តេ ធម្មា តេហិ ធម្មេហិ អនុគតា អនុបវិដ្ឋាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

សម្បយុត្តកថា ។

# ចេតសិកកថា

( ៦៩១ ) នត្ថិ ចេតសិកោ ធម្មោតិ ។ អាមន្តា ។ ននុ អត្ថិ កេចិ ធម្មា ចិត្តេន សហគតា សហជាតា សំសដ្ឋា សម្បយុត្តា ឯកុប្បាទា ឯកនិរោធា ឯកវត្ថុកា ឯការម្មណាតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កេចិ ធម្មា ចិត្តេន សហគតា សហជាតា សំសដ្ឋា សម្បយុត្តា ឯកុប្បាទា ឯកនិរោធា ឯកវត្ថុកា ឯការម្មណា នោ វត រេ វត្តព្វេ នត្ថិ ចេតសិកោ ធម្មោតិ ។

( ៦៩២ ) ផស្សោ ចិត្តេន សហជាតោតិ ។ អាមន្តា ។ ហញ្ចិ ផស្សោ ចិត្តេន សហជាតោ តេន វត រេ វត្តព្វេ ផស្សោ ចេតសិកោតិ ។ វេទនា ។ បេ ។ សញ្ញា ចេតនា ។ បេ ។ សទ្ធា វីរិយំ សតិ សមាធិ បញ្ញា រាគោ ទោសោ មោហោ ។ បេ ។ អនោត្តប្បំ ចិត្តេន សហជាតន្តិ ។ អាមន្តា ។

ធម៌ទាំងនោះ បិតនៅស៊ប់ ចូលទៅស៊ប់ ដោយធម៌ទាំងនោះ ក៏យ៉ាង នោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ សម្បយុត្តកថា ។

# ចេតសិកកថា

( ៦៩១ ) ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត មិនមានឬ ។ អើ ។ ក្រែង ពួកធម៌ទីមួយ ប្រព្រឹត្តទៅជាមួយ កើតជាមួយ ប្រឡំព្រម ប្រកបព្រម កើតជាមួយគ្នា រលត់ជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្ត មានដែរឬ ។ អើ ។ បើពួកធម៌ទីមួយ ប្រព្រឹត្តទៅជាមួយ កើតជាមួយ ប្រឡំព្រម ប្រកបព្រម កើតជាមួយគ្នា រលត់ជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្ត មាន ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម៌ប្រព្រឹត្តទៅក្នុងចិត្ត មិនមានទេ ។

( ៦៩២ ) ផស្សៈ កើតជាមួយនឹងចិត្តឬ ។ អើ ។ បើផស្សៈ កើតជាមួយនឹងចិត្ត ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ផស្សៈ ជាចេតសិក ។ វេទនា ។ បេ ។ សញ្ញា ចេតនា ។ បេ ។ សទ្ធា វិរិយៈ សតិ សមាធិ បញ្ញា រាគៈ ទោសៈ មោហៈ ។ បេ ។ អនោត្តប្បៈ កើតជាមួយនឹងចិត្តឬ ។ អើ ។

## ចេតសិកកថា

ហាញ្ញិ អនោត្តប្បំ ចិត្តេន សហជាតំ តេន វត រេ វត្តព្វេ អនោត្តប្បំ ចេតសិកន្តិ ។ ចិត្តេន សហជាតាតិ កត្វា ចេតសិកាតិ ។ អាមន្តា ។ ផស្សេន សហជាតាតិ កត្វា ផស្សិកាតិ ។ អាមន្តា ។ ចិត្តេន សហជាតាតិ កត្វា ចេតសិកាតិ ។ អាមន្តា ។ វេទនាយ ។ បេ ។ សញ្ញាយ ចេតនាយ សទ្ធាយ វីរិយេន សតិយា សមាធិនា បញ្ញាយ រាគេន ទោសេន មោហេន ។ បេ ។ អនោត្តប្បេន សហជាតាតិ កត្វា អនោត្តប្បិកាតិ ។ អាមន្តា ។ នត្ថិ ចេតសិកោ ធម្មោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

ចិត្តមិទំ ចេតសិកា ច ធម្មា
អនត្តតោ សំវិទិតស្ស ហោន្តិ
ហីនប្បណីតំ តទុភយេ វិទិត្វា
សម្មទ្ទសោ វេទិ បលោកធម្មន្តិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ អត្ថិ ចេតសិកោ ធម្មោតិ ។

ចេតសិកកថា

បើអនោត្តប្បៈ កើតជាមួយនឹងចិត្ត (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អនោត្តប្បៈ ជាចេតសិក ។ ពួកធម៌ជាចេតសិក ព្រោះធ្វើសេចក្តីចូលចិត្តថា កើតជាមួយនឹងចិត្តឬ ។ អើ ។ ពួកធម៌ ប្រព្រឹត្តទៅក្នុងផស្សៈ ព្រោះធ្វើសេចក្តីចូលចិត្តថា កើតជាមួយនឹងផស្សៈឬ ។ អើ ។ ពួកធម៌ ជាចេតសិក ព្រោះធ្វើសេចក្តីចូលចិត្តថា កើតជាមួយនឹងចិត្តឬ ។ អើ ។ ពួកធម៌ នឹងវេទនា ។បេ។ នឹងសញ្ញា នឹងចេតនា នឹងសទ្ធា នឹងវិរិយៈ នឹងសតិ នឹងសមាធិ នឹងបញ្ញា នឹងរាគៈ នឹងទោសៈ នឹងមោហៈ ។បេ។ ពួកធម៌ ប្រព្រឹត្តទៅក្នុងអនោត្តប្បៈ ព្រោះធ្វើសេចក្តីចូលចិត្តថា កើតជាមួយនឹងអនោត្តប្បៈឬ ។ អើ ។ ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត មិនមានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

> ចិត្តនេះក្តី ចេតសិកធម៌ទាំងឡាយក្តី របស់បុគ្គលដែលដឹងច្បាស់ ដោយអនត្តលក្ខណៈ កើតប្រាកដ បុគ្គលឃើញដោយប្រពៃ នូវធម៌ ដ៏ថោកទាបនឹងប្រសើរ ក៏ព្រោះដឹងច្បាស់ នូវធម៌ទាំងពីរនោះ ទើបទទួលលោកធម៌ (ធម៌ដែលបាក់បែកទ្រុឌទ្រោមទៅ)

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ធម៌ប្រព្រឹត្តទៅក្នុងចិត្ត មាន ។

(៦៩៣) នត្ថិ ចេតសិកោ ធម្មោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ឥធ កេវដ្ដ ភិក្ខុ បរសត្តានំ បរ-បុគ្គលានំ ចិត្តម្បិ អាទិសតិ ចេតសិកម្បិ អាទិសតិ វិតក្កិតម្បិ អាទិសតិ វិចារិតម្បិ អាទិសតិ ឯវម្បិ តេ មនោ ឥត្ថម្បិ តេ មនោ ឥតិបិ តេ ចិត្តន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ អត្ថិ ចេត-សិកោ ធម្មោតិ ។

ចេតសិកកថា ។

## ទានកថា

(៦៩៤) ចេតសិកោ ធម្មោ ទានន្តិ ។ អាមន្តា ។ លព្ភា ចេតសិកោ ធម្មោ បរេសំ ទាតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ លព្ភា ចេតសិកោ ធម្មោ បរេសំ ទាតុន្តិ ។ អាមន្តា ។ លព្ភា ផស្សោ បរេសំ ទាតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ លព្ភា វេទនា ។ បេ ។ សញ្ញា ចេតនា សទ្ធា វីរិយំ សតិ សមាធិ ។ បេ ។ បញ្ញា បរេសំ ទាតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ៦៩៣ ) ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត មិនមានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលកេវដ្ដៈ កិច្ចក្នុងធម៌វិន័យនេះ តែងបង្អួលបង្ហាញចិត្តផង បង្អួលបង្ហាញធម៌ដែលប្រព្រឹត្តទៅក្នុងចិត្តផង បង្អួលបង្ហាញធម៌ដែលខ្លួនត្រិះរិះហើយផង បង្អួលបង្ហាញធម៌ដែលខ្លួនពិចារណាហើយផង ដល់ពួកសត្វដទៃ ដល់ពួកបុគ្គលដទៃថា ចិត្តរបស់អ្នកយ៉ាងនេះខ្លះ ចិត្តរបស់អ្នក មានប្រការយ៉ាងនេះខ្លះ ចិត្តរបស់អ្នក ដូច្នេះខ្លះ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ធម៌ប្រព្រឹត្តទៅក្នុងចិត្ត មាន ។

ចប់ ចេតសិកកថា ។

## ទានកថា

( ៦៩៤ ) ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត ជាទានឬ ។ អើ ។ ធម៌ប្រព្រឹត្តទៅក្នុងចិត្ត ដែលបុគ្គលបាន ដើម្បីឲ្យដល់បុគ្គលដទៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត ដែលបុគ្គលបាន ដើម្បីឲ្យដល់បុគ្គលដទៃដែរឬ ។ អើ ។ ផស្សៈ ដែលបុគ្គលបាន ដើម្បីឲ្យដល់បុគ្គលដទៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វេទនា ។ បេ ។ សញ្ញា ចេតនា សទ្ធា វីរិយៈ សតិ សមាធិ ។ បេ ។ បញ្ញា ដែលបុគ្គលបាន ដើម្បីឲ្យដល់បុគ្គលដទៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ទានកថា

(៦៩៨) ន វត្តព្វំ ចេតសិកោ ធម្មោ ទានន្តិ ។ អាមន្តា ។ ទានំ អនិដ្ឋផលំ អកន្តផលំ អមនុញ្ញផលំ សេចនកផលំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ ននុ ទានំ ឥដ្ឋផលំ កន្តផលំ មនុញ្ញផលំ អសេចនកផលំ សុខុទ្រយំ សុខវិបាកន្តិ ។ អាមន្តា ។ ហញ្ចិ ទានំ ឥដ្ឋផលំ កន្តផលំ មនុញ្ញផលំ អសេចនកផលំ សុខុទ្រយំ សុខវិបាកំ តេន វត រេ វត្តព្វេ ចេតសិកោ ធម្មោ ទានន្តិ ។ ទានំ ឥដ្ឋផលំ វុត្តំ ភគវតា ចីវរំ ទានន្តិ ។ អាមន្តា ។ ចីវរំ ឥដ្ឋផលំ កន្តផលំ មនុញ្ញផលំ អសេចនកផលំ សុខុទ្រយំ សុខវិបាកន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ ទានំ ឥដ្ឋផលំ វុត្តំ ភគវតា បិណ្ឌបាតោ សេនាសនំ គិលានប្បច្ចយភេសជ្ជបរិក្ខារោ ទានន្តិ ។ អាមន្តា ។ គិលានប្បច្ចយភេសជ្ជបរិក្ខារោ ឥដ្ឋផលោ កន្តផលោ មនុញ្ញផលោ អសេចនកផលោ សុខុទ្រយោ សុខវិបាកោតិ ។ ន ហេវំ វត្តព្វេ ។បេ។

[ ៦៩៨ ] បុគ្គលមិនគួរនិយាយថា ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត ជាទាន ទេឬ ។ អើ ។ ទាន មានផលមិនជាទីប្រាថ្នា មានផលមិនជាទីត្រេកអរ មានផលមិនជាទីគាប់ចិត្ត មានផលប្រឡូកប្រឡំ ចម្រើនដោយទុក្ខ មានវិបាកជាទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងទាន មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អើ ។ បើទាន មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខ(យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត ចាត់ជាទាន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ទាន មានផលជាទីប្រាថ្នា ចុះចីវរ ជាទានឬ ។ អើ ។ ចីវរ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ទាន មានផលជាទីប្រាថ្នា ចុះបិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ ចាត់ជាទានឬ ។ អើ ។ គិលានប្បច្ច័យភេសជ្ជបរិក្ខារ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

( ៦៩៦ ) ន វត្តព្វំ ចេតសិកោ ធម្មោ ទានន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

សទ្ធា ហិរិយំ កុសលញ្ច ទានំ
ធម្មា ឯតេ សប្បុរិសានុយាតា
ឯតំ ហិ មគ្គំ ទិវិយំ វទន្តិ
ឯតេន ហិ គច្ឆតិ ទេវលោកន្តិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ចេតសិកោ ធម្មោ ទានន្តិ ។

( ៦៩៧ ) ន វត្តព្វំ ចេតសិកោ ធម្មោ ទានន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា បញ្ចិមានិ ភិក្ខវេ ទានានិ មហាទានានិ អគ្គញ្ញានិ រត្តញ្ញានិ វំសញ្ញានិ បោរាណានិ អសង្កិណ្ណានិ អសង្កិណ្ណបុព្វានិ ន សង្កិយន្តិ ន សង្កិយិស្សន្តិ អប្បដិក្កុដ្ឋានិ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ ។ កតមានិ បញ្ច ។ ឥធ ភិក្ខវេ អរិយសាវកោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ បាណាតិបាតា បដិវិរតោ ភិក្ខវេ អរិយសាវកោ អបរិមាណានំ សត្តានំ អភយំ ទេតិ អវេរំ ទេតិ អព្យាបជ្ឈំ ទេតិ

( ៦៩៦ ) បុគ្គលមិនគួរនិយាយថា ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត ជាទានឬ ។ អេ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

សទ្ធា ហិរិ និងកុសល ហៅថាទាន ធម៌ទាំងនុ៎ះ ជាទីប្រព្រឹត្តទៅរឿយៗនៃសប្បុរស ព្រោះថា អ្នកប្រាជ្ញទាំងឡាយ
តែងពោលនូវធម៌នុ៎ះ ថាជាផ្លូវគួរប្រាថ្នា ព្រោះបុគ្គល ទៅកាន់ទេវលោក ដោយផ្លូវនុ៎ះ

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អេ ។ ព្រោះហេតុនោះ ធម៌ប្រព្រឹត្តទៅក្នុងចិត្ត ចាត់ជាទាន ។

( ៦៩៧ ) បុគ្គលមិនគួរនិយាយថា ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត ចាត់ជាទានទេឬ ។ អេ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទាន ៥ យ៉ាងនេះ ជាមហាទាន ដែលបណ្ឌិតដឹងថាជាទានប្រសើរ ដឹងថាមានមកអស់កាលយូរហើយ ដឹងថាជាវង្សរបស់សប្បុរស ជារបស់នៃបុរសក្នុងកាលមុន ដែលបណ្ឌិតមិនដែលលះបង់ មិនធ្លាប់លះបង់ តែងមិនលះបោល នឹងមិនលះបោល ដែលពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ មិនបោះបង់បោលឡើយ ។ ទាន ទាំង ៥ យ៉ាងតើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក ក្នុងសាសនានេះ ជាអ្នកលះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក វៀរស្រឡះចាកបាណាតិបាតហើយ ឈ្មោះថាឲ្យអភ័យ ឲ្យនូវការមិនមានពៀរ ឲ្យនូវសេចក្ដីមិនព្យាបាទ ដល់សត្វទាំងឡាយមានប្រមាណមិនបាន

អបរិមាណានំ សត្តានំ អភយំ ទត្វា អវេរំ ទត្វា អព្យាបជ្ឈំ ទត្វា អបរិមាណស្ស អភយស្ស អវេរស្ស អព្យាបជ្ឈស្ស ភាគី ហោតិ ឥទំ ភិក្ខវេ បឋមំ ទានំ មហាទានំ អគ្គញ្ញំ រត្តញ្ញំ វំសញ្ញំ បោរាណំ អសង្កិណ្ណំ អសង្កិណ្ណបុព្វំ ន សង្កិយតិ ន សង្កិយិស្សតិ អប្បដិក្កុដ្ឋំ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ បុន ចបរំ ភិក្ខវេ អរិយសាវកោ អទិន្នាទានំ បហាយ ។ បេ ។ កាមេសុ មិច្ឆាចារំ បហាយ ។ បេ ។ មុសាវាទំ បហាយ ។ បេ ។ សុរាមេរយមជ្ជប្បមាទដ្ឋានំ បហាយ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ភិក្ខវេ អរិយសាវកោ អបរិមាណានំ សត្តានំ អភយំ ទេតិ អវេរំ ទេតិ អព្យាបជ្ឈំ ទេតិ អបរិមាណានំ សត្តានំ អភយំ ទត្វា អវេរំ ទត្វា អព្យាបជ្ឈំ ទត្វា

លុះឲ្យអភ័យ ឲ្យនូវការមិនមានពៀរ ឲ្យនូវសេចក្តីមិនព្យាបាទ ដល់សត្វទាំងឡាយ មានប្រមាណមិនបានហើយ រមែងជាអ្នកមានចំណែកដោយសេចក្តីមិនមានភ័យ មិនមានពៀរ មិនមានព្យាបាទ មានប្រមាណមិនបាន ម្នាលភិក្ខុទាំងឡាយ នេះ ជាទានទី ១ ជាមហាទាន ដែលបណ្ឌិតដឹងថាជាទានប្រសើរ ដឹងថាមានមកអស់ កាលយូរហើយ ដឹងថាជាវង្សរបស់សប្បុរស ជារបស់នៃបុរសក្នុងកាលមុន ដែលបណ្ឌិតមិនដែលលះបង់ មិនធ្លាប់លះបង់ រមែងមិនលះចោល នឹងមិន លះចោល ដែលសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ មិនបោះបង់ចោលឡើយ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវ័ក លះបង់នូវអទិន្នាទាន ។ បេ ។ លះបង់នូវការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ។ បេ ។ លះបង់នូវមុសាវាទ ។ បេ ។ លះបង់នូវហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ជាអ្នកវៀរស្រឡះ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក វៀរស្រឡះ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យហើយ ឈ្មោះថា ឲ្យនូវអភ័យ ឲ្យនូវការមិនមានពៀរ ឲ្យនូវសេចក្តីមិនព្យាបាទ ដល់សត្វទាំងឡាយ មានប្រមាណមិនបាន លុះឲ្យនូវអភ័យ ឲ្យនូវការមិ មានពៀរ ឲ្យនូវសេចក្តីមិនព្យាបាទ ដល់សត្វទាំងឡាយ មានប្រមាណមិនបានហើយ

អបរិមាណស្ស អភយស្ស អវេរស្ស អព្យាបជ្ឈស្ស ភាគី ហោតិ ឥទំ ភិក្ខវេ បញ្ចមំ ទានំ មហាទានំ អគ្គញ្ញំ រត្តញ្ញំ វំសញ្ញំ បោរាណំ អសង្កិណ្ណំ អសង្កិណ្ណបុព្វំ ន សង្កិយតិ ន សង្កិយិស្សតិ អប្បដិក្កុដ្ឋំ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ ឥមានិ ខោ ភិក្ខវេ បញ្ច ទានានិ មហាទានានិ អគ្គញ្ញានិ រត្តញ្ញានិ វំសញ្ញានិ បោរាណានិ អសង្កិណ្ណានិ អសង្កិណ្ណបុព្វានិ ន សង្កិយន្តិ ន សង្កិយិស្សន្តិ អប្បដិក្កុដ្ឋានិ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ចេតសិកោ ធម្មោ ទានន្តិ ។

(៦៩៨) ន វត្តព្វំ ទេយ្យធម្មោ ទានន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ឥធេកច្ចោ អន្នំ ទេតិ បានំ ទេតិ វត្ថំ ទេតិ យានំ ទេតិ មាលំ ទេតិ គន្ធំ ទេតិ វិលេបនំ ទេតិ សេយ្យំ ទេតិ អាវសថំ ទេតិ បទីបេយ្យំ ទេតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ទេយ្យធម្មោ ទានន្តិ ។

រមែងជាអ្នកមានចំណែក ដោយការមិនមានភ័យ មិនមានពៀរ មិនមានព្យាបាទ មានប្រមាណមិនបាន ម្នាលភិក្ខុទាំងឡាយ នេះ ជាទានទី ៥ ជាមហាទាន ដែលបណ្ឌិតដឹងថាជាទានប្រសើរ ដឹងថាមានមកអស់កាលយូរហើយ ដឹងថាជាវង្សរបស់សប្បុរស ជារបស់នៃបុរសក្នុងកាលមុន ដែលបណ្ឌិត មិនដែលលះបង់ មិនធ្លាប់លះបង់ រមែងមិនលះចោល នឹងមិនលះចោល ដែលពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ មិនបោះបង់ចោលឡើយ ម្នាលភិក្ខុទាំងឡាយ ទាន ៥ យ៉ាងនេះឯង ជាមហាទាន ដែលបណ្ឌិត ដឹងថាជាទានប្រសើរ ដឹងថាមានមក អស់កាលយូរហើយ ដឹងថាជាវង្សរបស់សប្បុរស ជារបស់នៃបុរសក្នុងកាលមុន ដែលបណ្ឌិត មិនដែលលះបង់ មិនធ្លាប់លះបង់ រមែងមិនលះចោល នឹងមិនលះចោល ដែលពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ មិនបោះបង់ចោលឡើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត ចាត់ជាទាន ។

( ៦៩៨ ) បុគ្គលមិនត្រូវនិយាយថា ទេយ្យធម៌ ជាទានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុគ្គលពួកខ្លះ ក្នុងលោកនេះ ឲ្យបាយ ឲ្យទឹក ឲ្យសំពត់ ឲ្យយាន ឲ្យផ្កាកម្រង ឲ្យគ្រឿងក្រអូប ឲ្យគ្រឿងលាប ឲ្យទីដេក ឲ្យទីសំណាក់អាស្រ័យ ឲ្យគ្រឿងប្រទីប ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ទេយ្យធម៌ ចាត់ជាទាន ។

(៦៩៩) ទេយ្យធម្មោ ទានន្តិ ។ អាមន្តា ។ ទេយ្យធម្មោ ឥដ្ឋផលោ កន្តផលោ មនុញ្ញផលោ អសេចនកផលោ សុខុទ្រយោ សុខវិបាកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទានំ ឥដ្ឋផលំ វុត្តំ ភគវតា ចីវរំ ទានន្តិ ។ អាមន្តា ។ ចីវរំ ឥដ្ឋផលំ កន្តផលំ មនុញ្ញផលំ អសេចនកផលំ សុខុទ្រយំ សុខវិបាកន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទានំ ឥដ្ឋផលំ វុត្តំ ភគវតា បិណ្ឌបាតោ ទានំ សេនាសនំ ទានំ គិលានប្បច្ចយភេសជ្ជបរិក្ខារោ ទានន្តិ ។ អាមន្តា ។ គិលានប្បច្ចយភេសជ្ជបរិក្ខារោ ឥដ្ឋផលោ កន្តផលោ មនុញ្ញផលោ អសេចនកផលោ សុខុទ្រយោ សុខវិបាកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ ន វត្តព្វំ ទេយ្យធម្មោ ទានន្តិ ។

ទានកថា ។

## បរិភោគមយបុញ្ញកថា

(៧០០) បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។ អាមន្តា ។

(៦៩៩) ទេយ្យធម៌ ឈ្មោះថាជាទានឬ ។ អើ ។ ទេយ្យធម៌ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ទាន មានផលជាទីប្រាថ្នា (យ៉ាងនេះ) ចុះចីវរ ជាទានឬ ។ អើ ។ ចីវរ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ទាន មានផលជាទីប្រាថ្នា (យ៉ាងនេះ) ចុះ បិណ្ឌបាត ជាទាន សេនាសនៈ ជាទាន គិលានប្បច្ចយភេសជ្ជបរិក្ខារ ជាទានដែរឬ ។ អើ ។ គិលានប្បច្ចយភេសជ្ជបរិក្ខារ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ទេយ្យធម៌ ជាទានទេ ។

ចប់ ទានកថា ។

## បរិភោគមយបុញ្ញកថា

(៧០០) បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។

បរិភោគមយោ ផស្សោ វឌ្ឍតិ វេទនា វឌ្ឍតិ សញ្ញា វឌ្ឍតិ ចេតនា វឌ្ឍតិ ចិត្តំ វឌ្ឍតិ សទ្ធា វឌ្ឍតិ វីរិយំ វឌ្ឍតិ សតិ វឌ្ឍតិ សមាធិ វឌ្ឍតិ បញ្ញា វឌ្ឍតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៧០១) បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។ អាមន្តា ។ លតា វិយ វឌ្ឍតិ មាលុវា វិយ វឌ្ឍតិ រុក្ខោ វិយ វឌ្ឍតិ តិណំ វិយ វឌ្ឍតិ មុញ្ជបុញ្ជោ វិយ វឌ្ឍតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៧០២) បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។ អាមន្តា ។ ទាយកោ ទានំ ទត្វា ន សមន្នាហរតិ ហោតិ បុញ្ញន្តិ ។ អាមន្តា ។ អនាវជ្ជន្តស្ស ហោតិ អនាភោគស្ស ហោតិ អសមន្នាហរន្តស្ស ហោតិ អមនសិករោន្តស្ស ហោតិ អចេតយន្តស្ស ហោតិ អបត្ថយន្តស្ស ហោតិ អប្បណិ-ទហន្តស្ស ហោតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ននុ អាវជ្ជន្តស្ស ហោតិ អាភោគស្ស ហោតិ សមន្នាហរន្តស្ស ហោតិ មនសិករោន្តស្ស ហោតិ ចេតយន្តស្ស ហោតិ បត្ថយន្តស្ស ហោតិ បណិទហន្តស្ស ហោតីតិ ។

ផស្សៈ សម្រេចដោយការបរិភោគ តែងចម្រើន វេទនា តែងចម្រើន សញ្ញា តែងចម្រើន ចេតនា តែងចម្រើន ចិត្ត តែងចម្រើន សទ្ធា តែងចម្រើន វីរិយៈ តែងចម្រើន សតិ តែងចម្រើន សមាធិ តែងចម្រើន បញ្ញា តែងចម្រើនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧០១] បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។ បុណ្យ តែងចម្រើន ដូចជាវល្លិ (ឡើងដើមឈើ) ចម្រើនដូចជាពួរព្រៃ ចម្រើនដូចជាដើមឈើ ចម្រើនដូចជាស្មៅ ចម្រើនដូចជាបាច់នៃស្មៅយាប្លង់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧០២] បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។ ទាយក ឲ្យទាន មិនពិចារណាទេ បុណ្យ មានដែរឬ ។ អើ ។ បុណ្យ របស់បុគ្គល កាលមិននឹកនា មិនអើពើ មិនពិចារណា មិនធ្វើទុកក្នុងចិត្ត មិនគិត មិនប្រាថ្នា មិនតំកល់ចិត្តមាំ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងបុណ្យ របស់បុគ្គល កាលនឹក-នា អើពើ ពិចារណា ធ្វើទុកក្នុងចិត្ត គិត ប្រាថ្នា តំកល់ចិត្តមាំ មានឬ ។

អាមន្តា ។ ហញ្ចិ អាវដ្ដន្តស្ស ហោតិ អាភោគស្ស ហោតិ សមន្នាហរន្តស្ស ហោតិ មនសិករោន្តស្ស ហោតិ ចេតយន្តស្ស ហោតិ បត្ថយន្តស្ស ហោតិ បណិទហន្តស្ស ហោតិ នោ វត រេ វត្តព្វេ បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។

(៧០៣) បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។ អាមន្តា ។ ទាយកោ ទានំ ទត្វា កាមវិតក្កំ វិតក្កេតិ ព្យាបាទវិតក្កំ វិតក្កេតិ វិហឹសាវិតក្កំ វិតក្កេតិ ហោតិ បុញ្ញន្តិ ។ អាមន្តា ។ ទ្វិន្នំ ផស្សានំ ។ បេ ។ ទ្វិន្នំ ចិត្តានំ សមោធានំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វិន្នំ ផស្សានំ ។ បេ ។ ទ្វិន្នំ ចិត្តានំ សមោធានំ ហោតីតិ ។ អាមន្តា ។ កុសលាកុសលា សាវជ្ជានវជ្ជា ហីនប្បណីតា កណ្ហសុក្កសប្បដិភាគា ធម្មា សម្មុខីភាវំ អាគច្ឆន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កុសលាកុសលា សាវជ្ជានវជ្ជា ហីនប្បណីតា កណ្ហសុក្កសប្បដិភាគា ធម្មា សម្មុខីភាវំ អាគច្ឆន្តីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ចត្តារិមានិ ភិក្ខវេ សុវិទូរវិទូរានិ ។ កតមានិ ចត្តារិ ។ នភញ្ច ភិក្ខវេ បថវី ច

បរិភោគមយបុញ្ញកថា

អើ ។ បើបុណ្យ របស់បុគ្គល កាលទឹកនា អើពោ ពិចារណា ធ្វើទុកក្នុងចិត្ត គិត ប្រាថ្នា តំកល់ចិត្តមាំ មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនទេ ។

(៧០៣) បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។ ទាយក ឲ្យទាន ហើយត្រិះរិះនូវកាមវិតក្កៈ ត្រិះរិះនូវព្យាបាទវិតក្កៈ ត្រិះរិះនូវវិហឹសាវិតក្កៈ បុណ្យ មានដែរឬ ។ អើ ។ ការប្រជុំចុះ នៃផស្សៈទាំងពីរ ។ បេ ។ នៃចិត្តទាំងពីរ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការប្រជុំចុះ នៃផស្សៈទាំងពីរ ។ បេ ។ នៃចិត្តទាំងពីរ មានឬ ។ អើ ។ ពួកធម៌ ជាកុសលនិងអកុសល មានទោសនិងមិនមានទោស ថោកទាបនិងឧត្តម មានចំណែកខ្មៅនិងចំណែកស មកកាន់ការៈចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកធម៌ ជាកុសលនិងអកុសល មានទោសនិងមិនមានទោស ថោកទាបនិងឧត្តម មានចំណែកខ្មៅនិងចំណែកស មកកាន់ការៈចំពោះមុខឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មជាតឆ្ងាយក្រៃលែងណាស់នេះ មាន ៤ យ៉ាង ។ ធម្មជាតឆ្ងាយក្រៃលែងណាស់ ទាំង ៤ នោះ តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ មេឃនិងប្រឹថពី

ឥទំ បឋមំ សុវិទូរវិទូរំ ឱរិមញ្ច ភិក្ខវេ តីរំ សមុទ្ទស្ស បារិមញ្ច តីរំ ឥទំ ទុតិយំ សុវិទូរវិទូរំ យតោ ច ភិក្ខវេ វេរោចនោ អព្ភុទេតិ យត្ថ ច អត្ថមេតិ ឥទំ តតិយំ សុវិទូរវិទូរំ សតញ្ច ភិក្ខវេ ធម្មា អសតញ្ច ធម្មា ឥទំ ចតុត្ថំ សុវិទូរវិទូរំ ឥមានិ ខោ ភិក្ខវេ ចត្តារិ សុវិទូរ-វិទូរានីតិ

នភញ្ច ទូរេ បឋវី ច ទូរេ
បារំ សមុទ្ទស្ស តទាហុ ទូរេ
យតោ ច វេរោចនោ អព្ភុទេតិ
បភង្ករោ យត្ថ ច អត្ថមេតិ
តតោ ហវេ ទូរតរំ វទន្តិ
សតញ្ច ធម្មំ អសតញ្ច ធម្មំ
អព្យាយិកោ ហោតិ សតំ សមាគមោ
យាវម្បិ តិដ្ឋេយ្យ តថេវ ហោតិ
ខិប្បំ ហវេតិ អសតំ សមាគមោ
តស្មា សតំ ធម្មោ អសព្ភិ អារកាតិ

នេះ ជាធម្មជាតឆ្ងាយក្រៃលែងណាស់ទី ១ ម្នាលភិក្ខុទាំងឡាយ ត្រើយខាងអាយ និងត្រើយខាងនាយនៃសមុទ្រ នេះ ជាធម្មជាតឆ្ងាយក្រៃលែងណាស់ទី ២ ម្នាលភិក្ខុទាំងឡាយ ព្រះអាទិត្យ រះឡើងអំពីទីណា និងអស្តង្គតទៅក្នុងទីណា នេះ ជាធម្មជាតឆ្ងាយក្រៃលែងណាស់ទី ៣ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយរបស់ពួកសប្បុរស និងធម៌ទាំងឡាយរបស់ពួកអសប្បុរស នេះ ជាធម្មជាតឆ្ងាយក្រៃលែងណាស់ទី ៤ ម្នាលភិក្ខុទាំង-ឡាយ ធម្មជាតឆ្ងាយក្រៃលែងណាស់ មាន ៤ យ៉ាងនេះឯង

ពពក (បិតនៅក្នុងទីឆ្ងាយ) ប្រឹថពី (ក៏បិតនៅ) ក្នុងទីឆ្ងាយពីគ្នា (អ្នកប្រាជ្ញ ពោល) នូវត្រើយសមុទ្រនោះ ថាឆ្ងាយ ព្រះអាទិត្យ រះឡើងអំពីទីណា ព្រះអាទិត្យ អស្តង្គតទៅក្នុងទីណា អ្នកប្រាជ្ញ ពោលនូវទីនោះ ថាជាទីឆ្ងាយក្រៃលែងអំពីទីនោះពិត បុគ្គលអ្នកសំដែង នូវធម៌របស់ពួកសប្បុរស និងធម៌របស់ពួកអសប្បុរស រមែងមាន សមាគម របស់សប្បុរសទាំងឡាយ ឋិតនៅដរាបណា (បុគ្គលអ្នកសំដែង) ក៏រមែងមាន ដរាបនោះ សមាគម របស់អសប្បុរសទាំងឡាយ រមែងសាបសូន្យទៅឆាប់រហ័ស ព្រោះហេតុនោះ ធម៌របស់សប្បុរសទាំងឡាយ ឆ្ងាយអំពីអសប្បុរសទាំងឡាយ

## បរិភោគមយបុញ្ញកថា

អញ្ញេ សុត្តន្តេតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ កុសលាកុសលា សាវជ្ជានវជ្ជា ហីនប្បណីតា កណ្ហសុក្កសប្បដិភាគា ធម្មា សម្មុខីភាវំ អាគច្ឆន្តីតិ ។

(៧០៤) ន វត្តព្វំ បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

អារាមរោបា វនរោបា យេ ជនា សេតុការកា
បបញ្ច ឧទបានញ្ច យេ ទទន្តិ ឧបស្សយំ
តេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ
ធម្មដ្ឋា សីលសម្បន្នា តេ ជនា សគ្គគាមិនោតិ

អញ្ញេ សុត្តន្តេតិ ។ អាមន្តា ។ តេន ហិ បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។

បរិភោគមយបុញ្ញកថា

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គលមិនគួរនិយាយថា ពួកធម៌ ជាកុសលនិងអកុសល មានទោសនិងមិនមានទោស ថោកទាបនិងឧត្តម មានចំណែកខ្មៅនិងចំណែកស មកកាន់ការៈចំពោះមុខទេ ។

